រក្សាសិទ្ធិដោយអង្គការអន្តរជាតិខាងការងារ ឆ្នាំ២០១២
កម្ពុជា "ឆ្ពោះទៅកាន់យុទ្ធសាស្រ្តជាតិមុខរបរនិងការងារដើម្បីកាត់បន្ថយភាពក្រីក្រប្រកប
ដោយនិរន្តរភាព"

អង្គការអន្តរជាតិខាងការងារ ឆ្នាំ២០១២ គំរោងបង្កើនកិច្ចគាំពារសង្គម និងមុខរបរ
ការិយាល័យអន្តរជាតិខាងការងារ ប្រចាំទីក្រុងហ្សឺណែវ ឆ្នាំ២០១២

ISBN 978-92-2-826594-1 (print )
978-92-2-82659-8 (គេហទំព័រ -pdf)

## បោះពុម្ពឆ្នាំ២០១២ នៅកម្ពុជា

ឯកសារនេះ គឺជាការបកប្រែពីឯកសារជាភាសាអង់គ្លេស **"Cambodia: Toward a national employment strategy for sustained poverty reduction "** ដែលបានរៀបចំឡើង ដោយទីប្រឹក្សាជាន់ខ្ពស់នៃអង្គការអន្តរជាតិខាងការងារ ក្នុងគំរោង **ILO-EU** ស្តីពី "ការបង្កើនកិច្ចគាំពារសង្គមនិងមុខរបរ " ក្រោមកិច្ចសហប្រតិបត្តិការជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៏វិស័យកសិកម្ម និងជនបទ និងស្ថាប័នពាក់ព័ន្ធដទៃទៀត។ ការបកប្រែឯកសារនេះមកជាភាសាខ្មែរ និងការប្រើប្រាស់ពាក្យពេជន៏ទាំងឡាយនៅក្នុងឯកសារនេះ ពុំឆ្លុះបញ្ចាំងតំណាងឱ្យគោលជំហររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៏វិស័យកសិកម្មនិងជនបទឡើយ។

ការបោះពុម្ពនេះទទួលបានការឧបត្ថម្ភថវិការពីសហគមន៍អឺរ៉ុប។ ខ្លឹមសារនៃឯកសារនេះជាការទទួល ខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីគោលជំហររបស់សហគមន៍អឺរ៉ុបឡើយ។

ILO/EU/Cambodia/R.8

# កម្ពុជា

# ឆ្ពោះទៅកាន់យុទ្ធសាស្ត្រជាតិមុខរបរនិងការងារ ដើម្បីកាត់បន្ថយភាពក្រីក្រប្រកប ដោយនិរន្តរភាព

ការសិក្សាដោយគម្រោង ILO-EU

" បង្កើនកិច្ចគាំពារសង្គម និងមុខរបរ "

ការិយាល័យអន្តរជាតិខាងការងារ ទីក្រុងហ្សឺណែវ

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងឧបក្ការគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកស្រី Makiko Matsumoto ដែលបានគាំទ្រយ៉ាងពេញទំហឹង និងផ្តល់នូវមូលដ្ឋានទិន្នន័យនិងសំណើជាច្រើនដើម្បីធ្វើឲ្យការសិក្សានេះកាន់តែប្រសើរឡើង។ លោកក៏សូមថ្លែងអំណរគុណដល់លោក Peter Peek លោកស្រី Sukti Dasgupta និង Iyanatul Islam ចំពោះមតិយោបល់ ការណែនាំ និងបានផ្តល់អនុសាសន៍។ ការសិក្សាទទួលបានផលប្រយោជន៍ជាច្រើនពីកិច្ចពិគ្រោះយោបល់ជាមួយនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់នៃក្រសួងជាច្រើន ធនាគារជាតិនៃកម្ពុជា ក្រុមនិយោជក និងនិយោជិត អ្នកស្រាវជ្រាវ និងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) និងភ្នាក់ងារម្ចាស់ជំនួយដទៃទៀត។

ការសិក្សានេះអាចលេចចេញជារូបរាងឡើង តាមរយៈការបំពេញបេសកកម្មរបស់អ្នកនិពន្ធនៅភ្នំពេញ ប្រទេសកម្ពុជា នាខែវិច្ឆិកា ឆ្នាំ២០១០។ លោកសូមថ្លែងអំណរគុណដល់មនុស្សគ្រប់រូប និងដល់លោក ទុន សោភ័ណ និងអ្នកស្រី ឪក ម៉ាលីកា មន្ត្រីអង្គការ ILO ប្រចាំនៅភ្នំពេញចំពោះការសហការ និងការគាំទ្រផ្សេងៗក្នុងអំឡុងពេលបេសកកម្ម។

# មាតិកា


**មាតិកា** ........ 4

សេចក្តីសង្ខេប ........ 6

**១.ការសិក្សា៖ សេចក្តីផ្តើម** ........ 12

**២.បរិបទនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបង្កើតការងារ សម្រាប់ប្រទេសកម្ពុជា** ........ 16

គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងយុទ្ធសាស្ត្រចតុកោណ ........ 16

កំណើន និងភាពក្រីក្រ ........ 18

មុខរបរនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ........ 23

គោលនយោបាយ ក្រលេកមើលប្រទេសខាងកើត? ........ 23

ការពិចារណាឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ក្នុងអំឡុងពេលក្រោយវិបត្តិ ........ 27

ក្របខណ្ឌមូលដ្ឋានរបស់ យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ ........ 29

**៣. ភាពប្រឈមការងារ និងសក្តានុពលទីផ្សារការងារ** ........ 30

ភាពប្រឈមផ្នែកមុខរបរ ........ 31

សក្តានុពលទីផ្សារការងារ ........ 38

**៤. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងមុខរបរ** ........ 41

សូចនាករដែលបានព្រមព្រៀង ........ 42

គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច កំណើន និងមុខរបរ ........ 44

**៥. គោលនយោបាយតាមវិស័យ និងការផ្លាស់ប្តូរតាមលំដាប់** ........ 47

ការអភិវឌ្ឍកសិកម្ម និង ជនបទ ........ 49

ឧស្សាហូបនីយកម្ម និងគោលនយោបាយពាណិជ្ជកម្ម៖ ការពង្រឹងសក្តានុពលបង្កើតការងារ ........ 52

មុខរបរនៅក្នុងវិស័យផ្សេងៗ៖ សំណង់ និងសេវាកម្ម ........ 58

មុខរបរក្នុងវិស័យសេវាកម្ម ........ 60

**៦. គោលនយោបាយទីផ្សារការងារ៖ បញ្ហាមួយចំនួន** ........ 61

ឱកាសមានការងារ និងការអភិវឌ្ឍជំនាញ ........ 62

ទេសន្តប្រវេសន៍ការងារ ........ 64

គោលនយោបាយមុខរបរនិងការងារ ........ 65

**៧. កិច្ចគាំពារសង្គម និងមុខរបរ** ........ 69

សេចក្ដីសន្និដ្ឋាន ........ 77

# សេចក្ដីសង្ខេប

១. ការសិក្សានេះមានគោលបំណងពិចារណាពីបរិបទនៃសារៈសំខាន់ នូវការធ្វើផែនការសំរាប់បង្កើតការងារដែលមានផលិតភាពដែលជាបញ្ហាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព។ ខណៈពេល ដែលកំណើនសេដ្ឋកិច្ចជាលក្ខខណ្ឌដ៏ចាំបាច់មួយ វាមិនអាចទប់ស្កាត់ភាពក្រីក្របានដោយលទ្ធផលគួរអោយពេញចិត្តនោះទេ ពីព្រោះថាទំនាក់ទំនងរវាងវិសាលភាពកំណើនសេដ្ឋកិច្ច និងភាពក្រីក្រមិនតែងតែស៊ីសង្វាក់គ្នាទេ។ មេរៀនសំខាន់មួយដែលជារឿយៗដកស្រង់ពីបទពិសោធន៍ប្រវត្តិសាស្រ្ត និងភស្តុតាងជាក់ស្តែងពីការអភិវឌ្ឍសហសម័យ គឺថាកំណើនសេដ្ឋកិច្ចដែលបង្កើតការងារដែលមានផលិតភាព អាចកាត់បន្ថយភាពក្រីក្របានប្រសើរជាងកំណើនសេដ្ឋកិច្ចតែគ្មានការងារ។ ដើម្បីបន្តយុទ្ធសាស្រ្តកំណើនសេដ្ឋកិច្ចដែលបង្កើនការងារ គឺតម្រូវអោយមានការបញ្ចូល យុទ្ធសាស្រ្តជាតិស្តីពីមុខរបរ ទៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ប្រទេស។

២. ការខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងការសំរេចបាន គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ធានាថាខ្លួនអនុវត្តន៍យុទ្ធសាស្រ្តមួយឆ្ពោះទៅកាន់ការសំរេចបាននូវ ១ខ ដែលជាគោលដៅនៃការងារមានផលិតភាព ពេញលេញ និង ការងារសមរម្យ។ ទាំងនេះផ្តល់នូវហេតុផលសមរម្យមួយសំរាប់ ការបង្កើតនិងរៀបចំនូវយុទ្ធសាស្រ្តជាតិស្តីពីមុខរបរនិងការងារ។

៣. លើសពីនេះទៅទៀត ខណៈពេលដែលយុទ្ធសាស្រ្តជាតិស្តីពីមុខរបរនិងការងារ ជាគោលដៅរយៈពេលមធ្យមមួយ វានឹងទាមទារអោយមានការបន្ថែមនូវយុទ្ធសាស្រ្តមួយនៃការពង្រីកកិច្ចគាំពារសង្គម និង សំណាញ់សុវត្ថិភាពសង្គម(ឧទាហរណ៍ ក្របខណ្ឌអប្បរមបរមារបស់ILOស្តីពីកិច្ចគាំពារសង្គមជាមូលដ្ឋាន) ដើម្បីគាំទ្រការទទួលបានចំនូល និងការងាររបស់ជនក្រីក្រ និងជនងាយរងគ្រោះ។ ការធ្វើផែនការអភិវឌ្ឍនៅពេលមុនពេលមានវិបត្តិនឹងទាមទារអោយផ្លាស់ប្តូរវិធានការគោលនយោបាយដើម្បីដោះស្រាយគោលដៅទាំងពីរ ក្នុងការលើកកម្ពស់ការងារដែលមានផលិតភាព និងបង្កើនកិច្ចគាំពារសង្គម។ ការសិក្សានេះផ្តោតសំខាន់លើភាពជាប់ពាក់ព័ន្ធគ្នា និងការបញ្ចូលនូវយុទ្ធសាស្រ្តជាតិស្តីពីមុខរបរទៅក្នុង ផែនការអភិវឌ្ឍន៍កម្ពុជា។

៤. ប្រទេសកម្ពុជាប្តេជ្ញាចិត្តយ៉ាងរឹងមាំដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (យុទ្ធសាស្រ្តចតុកោណ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣) ជាពិសេសដើម្បីកាត់បន្ថយភាពក្រីក្រ។ កំណើនសេដ្ឋកិច្ចយ៉ាងលឿនរបស់ប្រទេសកម្ពុជាចាប់តាំងពីទសវត្សទី ៩០ រហូតដល់ប្រហែលឆ្នាំ ២០០៧ គឺមានទំនាក់ទំនងជាមួយនឹងការកាត់បន្ថយភាពក្រីក្រយ៉ាងជាក់ស្តែង មិនថាបានកំណត់ដោយខ្សែបន្ទាត់ក្រីក្រជាតិ រឺ ដោយស្តង់ដាសកលដែលមានកំរិត ១.២៥ដុល្លារ ក្នុងមួយថ្ងៃ

នោះទេ។ ចំពោះគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដទៃទៀត ហើយនិងសូចនាករនៃការសំរេចបានគោលដៅទាំងនោះ គឺលទ្ធផលបង្ហាញនូវរូបភាពលាយលំគ្នា។ សូចនាករខ្លះ ដូចជាសមាមាត្រនៃការចុះឈ្មោះចូលរៀនរបស់កុមារា កុមារី នៅថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យត្រូវមានការកើនឡើង ខណៈពេលដែលសូចនាករដទៃទៀតដូចជា សមាមាត្រមរណៈកុមារគឺផ្ទុយពីនេះ។ ការអន្តរាគមន៍ជាសាធារណៈគឺចាំបាច់ដើម្បីធានាអោយសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ទាំងនេះនៅឆ្នាំ២០១៥។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តោតសំខាន់នៃការសិក្សានេះ គឺទៅលើគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ក្នុងការកាត់បន្ថយភាពក្រីក្រ និងការសំរេចបាននូវមុខរបរប្រកបដោយផលិតភាពពេញលេញ និងការងារសមរម្យ។

៥. ភាពជោគជ័យថ្មីៗនេះរបស់ប្រទេសកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ គឺគួរអោយចាប់អារម្មណ៍ តែទោះបីជាយ៉ាងណាក៏ដោយ វាទាមទារអោយមានការកត់សំគាល់ផងដែរថាវិសាលភាព នៃភាពក្រីក្រនៅតែមានកំរិតខ្ពស់ ជាពិសេសនៅទីជនបទនៃតំបន់មួយចំនួន និងក្នុងចំណោមក្រុមប្រជាជនជាក់លាក់មួយចំនួន ដូចជាកសិករដែលមានកសិដ្ឋានផ្ទាល់ខ្លួន និងអ្នកធ្វើកិច្ចការតាមផ្ទះ។ លើសពីនេះទៅទៀត គម្លាតនៃភាពក្រីក្រ បង្ហាញថាប្រជាជនងាយរងគ្រោះមានអត្រាយ៉ាងខ្ពស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសចំពោះអ្នកដែលស្ថិតនៅជិតខ្សែបន្ទាត់ក្រីក្រ។ បន្ថែមលើនេះទៀត នៅពេលថ្មីៗនេះ សេដ្ឋកិច្ចបានជួបប្រទះការកើនឡើងនូវអសមភាពនៃប្រាក់ចំណូល ដែលអាចធ្វើអោយដំណើរការកាត់បន្ថយភាពក្រីក្រមានភាពយឺតយ៉ាវ ប្រសិនបើអត្រាកំណើនសេដ្ឋកិច្ចខ្ពស់មិនបង្កើនប្រាក់ចំណូលសំរាប់ក្រុមងាយរងគ្រោះនោះទេ។

៦.តាមការសង្កេតជាទូទៅ សេដ្ឋកិច្ចបន្តនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលបណ្តាលមកពីកំណើនសេដ្ឋកិច្ច។ នៅទីនេះ ការសិក្សាបង្ហាញពីតម្រូវការសំរាប់ការវិភាគដ៏ម៉ឺងម៉ាត់តាមវិធីមួយ ដែលតាមរយៈវិធីនេះ កំណើនបង្កអោយមានលទ្ធផលភាពក្រីក្រជាវិជ្ជមាន។ លើសពីនេះទៅទៀត កំណើនត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយវិបត្តិសកលលោកកាលពីពេលថ្មីៗនេះ ហើយវិសាលភាពនៃភាពក្រីក្រ និងភាពងាយរងគ្រោះ បានកើនឡើង ហើយភាពមន្ទិលសង្ស័យគឺទៅលើថាតើ និងពេលណា ដែលសេដ្ឋកិច្ចអាចវិលត្រឡប់មកមានកំណើនខ្ពស់ដូចកាលពីពេលមុន។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ បានបញ្ចប់នូវភាពមន្ទិលទាំងនេះ ដែលបញ្ជាក់ថាអត្រាកំណើនធ្លាក់ចុះយ៉ាងលឿន មកត្រឹមជាមធ្យម ៥-៦% ពីកំណើនពីរខ្ទង់ដែលសំរេចបានកាលពីពេលមុន។ នេះអាចធ្វើឱ្យការបង្កើតការងារ និងការកាត់បន្ថយភាពក្រីក្រមានភាពយឺតយ៉ាវផងដែរ។

៧.សំខាន់ជាងនេះទៅទៀត វិបត្តិធ្វើអោយអ្នកធ្វើផែនការគោលនយោបាយផ្អាកក្នុងការឆ្លុះបញ្ចាំងយុទ្ធសាស្ត្រកំណើនរបស់ប្រទេសកម្ពុជា។ ដូចនេះកម្ពុជាគួរតែយកគំរាប់តាមប្រទេសអាស៊ាន ជិតខាង និង អាស៊ីភាគខាងកើត ដោយយកយុទ្ធសាស្ត្រកំណើនពឹងផ្អែកលើកំលាំងពលកម្ម និងការនាំចេញ។ ខណៈពេលដែលការងារនេះ ផ្តល់លទ្ធផលជោគជ័យជាដំបូងខ្លះ ជាឧទាហរណ៍កំណើនឆាប់រហ័សក្នុង

ការនាំចេញសំលៀកបំពាក់ (ដែលនាំអោយមានការងារ និងសហគ្រាស)។ អ្នកវិភាគជឿជាក់ទៅលើកាលៈទេសៈមួយចំនួន (ទីផ្សារដែលមានការធានា ជាពិសេស សហរដ្ឋអាមេរិក និងកំណើនសកលលោក ២០០២-២០០៧) និងមានការផ្តល់ការលើកទឹកចិត្ត គោលនយោបាយ និង ធនធានយ៉ាងលើសលប់ ដើម្បីទាក់ទាញវិនិយោគទុន។ យើងសង្កេតឃើញថា ការវិនិយោគផ្ទាល់ ជាកាតាលីករវិនិយោគសំខាន់ក្នុងវិស័យកាត់ដេរ។ ការសិក្សាចង្អុលបង្ហាញថា កំណើនដោយពឹងផ្អែកលើការនាំចេញនៅអាស៊ីអាគ្នេយ៍ គឺមិនមែនគ្រាន់តែពឹងផ្អែកលើកំលាំងពលកម្មនោះទេ វាត្រូវបានបង្កើតឡើងជាមួយទំនាក់ទំនងពេលមុន និងក្រោយ ជាមួយនឹងគោលនយោបាយដែលកើតឡើងពេលស្របគ្នា ដើម្បីបង្កអោយមានកត្តាប្រើប្រាស់សមរម្យ វិនិយោគទុនក្នុងស្រុក សហគ្រាស និងជំនាញដើម្បីទាញយកទីផ្សារ។ សេដ្ឋកិច្ចទាំងនេះបន្តនូវយុទ្ធសាស្ត្រកំណើនទូលំទូលាយដែលបង្កើតការងារ ហើយត្រូវបានគាំទ្រដោយយុទ្ធសាស្ត្រឧស្សាហូបនីយកម្មដែលពឹងផ្អែកលើការនាំចេញ។ វិស័យនាំចេញនៅក្នុងប្រទេសកម្ពុជា ជាមួយនឹងវត្តមានតិចតួចនៃវិនិយោគទុនក្នុងស្រុក និងកម្មករជំនាញ គឺមិនអាចបង្កើនសក្តានុពលឧស្សាហូបនីយកម្មនេះបានទេ។

៨. ជាការពិតណាស់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ផ្តល់នូវ ការទទួលស្គាល់ដ៏ជាក់លាក់មួយនៃតម្រូវការនៃការឈានឆ្ពោះទៅកាន់យុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ ដោយមិនបោះបង់គោលដៅនៃស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពបើកចំហរនៃសេដ្ឋកិច្ច។ ដូចនេះការផ្តោតសំខាន់ជាងនេះ កំពុងត្រូវបានអនុវត្តទៅលើការអភិវឌ្ឍន៍ជនបទ ដែលនេះជាការផ្លាស់ប្តូរមួយពីការកាត់បន្ថយភាពក្រីក្រដែលគ្រាន់តែជាមុខងារមួយនៃកំណើន ទៅជាទំរង់មួយនៃកំណើន។ យើងនៅតែសង្កេតឃើញរបៀបដែលយុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយវិវត្តន៍នៅក្នុងប្រទេសកម្ពុជា និងរបៀបដែលគោលបំណងនិងគោលដៅកំណត់ទុកផែនការថ្មី ត្រូវអនុវត្តន៍ ដើម្បីនាំមកនូវការផ្លាស់ប្តូរផ្សេងៗគ្នាទៅតាមតម្រូវការចាំបាច់ និងលំដាប់លំដោយ។ ការផ្លាស់ប្តូរនេះ ស្ថិតនៅក្នុងក្របខណ្ឌទស្សនៈអភិវឌ្ឍន៍ថ្មី ដែលយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ អាចរួមបញ្ចូល និងធ្វើអោយប្រសើរឡើងនូវការបង្កើនការងារ។ បន្ទាប់ពីនេះ វានឹងមានកំណើនការងារដែលផ្អែកលើប្រាក់កំរៃ និងការចល័តកំលាំងពលកម្មទៅរកការងារដែលមានផលិតភាពខ្ពស់ជាងមុន ដែលអាចចង្អុលបង្ហាញនូវដំណើរការផ្លាស់ប្តូរតាមលំដាប់នៃសេដ្ឋកិច្ច។

៩. ដើម្បីរៀបចំ និងបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារមួយ វាត្រូវការជាចាំបាច់ក្នុងការយល់ និងវាយតំលៃនូវភាពពិតប្រាកដនៃស្ថានភាពការងារ និងទីផ្សារការងារ។ ការសិក្សាបានប្រមើលលើការប្រឈមផ្នែកមុខរបរក្នុងសេដ្ឋកិច្ច និងទៅលើសក្តានុពលទីផ្សារការងារ។ នៅអំឡុងទសវត្ស ១៩៩៨-២០០៨ មានកំណើនការងារគួរអោយកត់សំគាល់ ជាមួយនឹងការកើនឡើងនូវប្រាក់បៀវត្សនៅក្នុងវិស័យជាក់លាក់មួយចំនួនផងដែរ។ ការសិក្សាបានជំទាស់ថា ដោយសារអត្រាអត់ការងារនាពេលបច្ចុប្បន្ននៅមានកំរិតទាបត្រឹម ១.៦%នោះ ការកាត់បន្ថយអត្រាអត់ការងារ មិនមែនជាគោលដៅគោលនយោបាយមួយដែលសំខាន់នោះទេ។ ចំណុចមួយគួរកត់ចំណាំផងដែរថា មានវត្តមានទាំងអត្រាអត់ការងារទាប ជាមួយនឹងវិសាលភាពខ្ពស់នៃភាពក្រីក្រ និងផលិតភាពមានកំរិតទាប។ នេះបង្កប់ន័យថាការងារភាគច្រើន

ដែលបានបង្កើតក្នុងអំឡុងទសវត្សនេះ មិនបានទទួលកំរៃគ្រប់គ្រាន់ និងមានផលិតភាពនោះទេ។ គោលនយោបាយសំខាន់ៗមួយចំនួន អាចនឹងជំនួសការតាមដានដំណើរការសូចនាករទាំងបួននៃ គោល ដៅអភិវឌ្ឍន៍សហសវត្សរ៍ ១ខ (ដូចជាវិសាលភាពការងារក្រីក្រ សមាមាត្រប្រជាជនដែលមានមុខរបរ សមាមាត្រនៃប្រជាជនងាយរងគ្រោះ និងផលិតភាពការងារ) និង/ឬ សំរបសំរួល និងតាមដានកំណើនការងារ វិស័យផ្លូវការដែលទទួលបានកំរៃនៅក្នុងវិស័យឯកជន និងសាធារណៈ។ ការសិក្សានេះរំលឹកថា យើងត្រូវប្រុងប្រយ័ត្នចំពោះបញ្ហានៃសូចនាករ គោលដៅអភិវឌ្ឍន៍សហសវត្ស ជាពិសេសទាក់ទងនឹងប្រជាជន ងាយរងគ្រោះ និងតម្រូវការបង្កើតសូចនាករនៃគោលដៅ និងដំណើរការ ។ នៅក្នុងករណីបន្ទាប់ ឧទាហរណ៍ កំណើនការងារវិស័យផ្លូវការ នឹងពឹងផ្អែកលើទំរង់កំណើនសេដ្ឋកិច្ច ហើយនិងការផ្លាស់ប្តូរតាមលំដាប់។ បច្ចុប្បន្នទីផ្សារការងារកម្ពុជា ក្នុងវិស័យផ្លូវការនៅមានកំរិត តែការងារភាគច្រើនមាននៅក្នុងសេដ្ឋកិច្ចមិនផ្លូវការ។ យុវជនអត់ការងារធ្វើសរុបមានអត្រាខ្ពស់ ក្នុងនោះសមាមាត្រការងាររបស់ស្ត្រីមានការកើនឡើង ប៉ុន្តែមានគម្លាតគួរអោយកត់សំគាល់នៃលទ្ធភាពទទួលបានវគ្គបណ្តុះបណ្តាល ការអប់រំ និងការងារដែលមានកំរៃខ្ពស់។

១០. ការបង្កើតការងារជាបាតុភូតស្មុគស្មាញមួយ ហើយទទួលឥទ្ធិពលគោលនយោបាយសង្គម និងសេដ្ឋកិច្ចទាំងមូល ដូចនេះការរៀបចំ និងបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរ ទាមទារនូវវិធីសាស្ត្រសមាហរកម្មមួយ ដែលអាចតាមរយៈទម្រង់ជាអន្តរក្រសួង។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសង្គម និងតាមវិស័យកម្មវិធីអភិវឌ្ឍន៍ជំនាញ គោលនយោបាយកិច្ចគាំពារសង្គម និងការងារ ព្រមទាំងកំណែទម្រង់ស្ថាប័ន និងក្របខណ្ឌគតិយុត្តិ ទាមទារអោយមានការត្រួតពិនិត្យយ៉ាងជិតដល់ដើម្បីធ្វើកំណែទម្រង់ចាំបាច់ឆ្ពោះទៅកាន់យុទ្ធសាស្ត្រការងារ និងផែនការសកម្មភាពមួយ។

១១.នៅក្នុងបរិបទខាងលើ ការសិក្សាបានពិនិត្យមើលគោលនយោបាយទាំងនេះមួយចំនួន ហើយជំហរគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានធ្វើឡើងក្នុងក្របខណ្ឌនៃការព្រមព្រៀងគ្នានៅក្រុងវ៉ាស៊ីនតោន Washington Consensus ហើយផ្តោតសំខាន់លើគោលដៅនៃស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ គោលដៅដទៃទៀតជាការបង្កើតការងារ និង/ឬ កិច្ចគាំពារសង្គម មិននៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនោះទេ។ ទោះបីជាលើគោលដៅស្ថេរភាពដោយយោងទៅតាមលក្ខណៈដុល្លារូបនីយកម្មនៃសេដ្ឋកិច្ច ការប្រើប្រាស់នូវឧបករណ៍តាមទំលាប់ត្រូវបានហាមឃាត់។ ការកំណត់ទិសដៅចំពោះអតិផរណា មិនទាន់បានអនុវត្តន៍តាមរយៈវិធីផ្សេងៗគ្នានៅក្នុងគោលនយោបាយនៅឡើយ ចំនែកឯការអន្តរាគមន៍ពីធនាគារជាតិនៅមានកំរិតនៅឡើយ លើកលែងតែតាមរយៈ ការទិញ/លក់ប្រាក់ដុល្លា ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់។ ជារឿយៗជញ្ជីងសារពើពន្ធត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងវិនិយោគទុន និង ប្រើប្រាស់សំរាប់ធ្វើអោយមានស្ថេរភាពនូវតម្លៃ។ ពីព្រោះតែស្ថេរភាពនេះមិនបានបង្កើនវិនិយោគក្នុងស្រុក នៅឡើយ ការសិក្សាអំពាវនាវអោយមានការប្រើប្រាស់ដោយប្រុងប្រយ័ត្ន ចំពោះគោលនយោបាយថវិកា សំរាប់ពង្រីកហេដ្ឋារចនាសម្ព័ន្ធសង្គម និងបុគ្គល ហើយនិងគោលនយោបាយថវិកា/ឥណទានដ៏សមរម្យ មួយសំរាប់ជម្រុញការវិនិយោគ និងបង្កើតការងារ។

១២. ខណៈពេលដែលប្រទេសកម្ពុជាបានបង្ហាញកំណើនមុខរបរយ៉ាងឆាប់រហ័ស ភាគច្រើននៃកំណើននេះកើតមានឡើងនៅក្នុងសកម្មភាពដែលមានប្រាក់កំរៃ និងផលិតភាពទាប។ សូចនាករនៃកំណើននេះគឺថាការងារនៅក្នុងវិស័យឧស្សាហកម្មទំនើបនៅមានកំរិតទាប នេះមានន័យថាទោះបីជាមានកំណើនឆាប់រហ័ស ក៏សេដ្ឋកិច្ចមិនបានស្តែងចេញការផ្លាស់ប្តូរដែលមានលំដាប់នោះទេ។ ការសិក្សាពិនិត្យទៅលើសក្តានុពលនៃវិស័យដែលបានជ្រើសរើស (កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ការសាងសង់ និងសេវាកម្ម) ឆ្ពោះទៅកាន់ការបង្កើតការងារ។ យុទ្ធសាស្ត្រតាមវិស័យទាមទារអោយមានការត្រួតពិនិត្យសារៈសំខាន់សមរម្យនៃសេដ្ឋកិច្ចដូចជាតាមរយៈការប្រើប្រាស់សមត្ថភាព បង្កើនផលិតភាព និងប្រាក់ចំណូលក្នុងផលិតកម្មដែលពឹងផ្អែកលើដីធ្លី និងការនាំចេញ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម នៅក្នុងបរិបទនេះ បានទទួលកញ្ចប់ថវិកាសំរាប់អភិវឌ្ឍន៍ជនបទដែលអាចបង្កើនប្រាក់ចំណូល និងការងារចំពោះជនក្រីក្រនៅជនបទ។ ការសិក្សានេះបញ្ជាក់ថា ខណៈពេលដែលកំណើនកសិកម្មបានកំពុងតែកើនឡើងក្នុងពេលថ្មីៗនេះ ប្រសិទ្ធភាពនៃកំណើននេះនៅតែមានកំរិតទាប បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាអាចបង្កើនផលិតភាព និងការស្រូបយកកម្លាំងការងារនៅក្នុងវិស័យទាំងពីរ គឺតាមរយៈការអភិវឌ្ឍកសិកម្មខ្នាតតូច និងកសិកម្មផលិតកម្មខ្នាតធំ រួមមានការអភិវឌ្ឍព្រៃឈើ និងដំណាំ ដែលនេះទាមទារអោយមានដំណោះស្រាយចំពោះឧបសគ្គមួយចំនួនដូចជាចាប់យកប្រពលវប្បកម្ម ប្រើប្រាស់ពូជដែលមានទិន្នផលខ្ពស់ គោលនយោបាយសាធារណៈដែលអនុគ្រោះ និងចំណាយលើការពង្រីកប្រព័ន្ធធារាសាស្ត្រ លទ្ធភាពក្នុងការទទួលបានប្រាក់កម្ចី ជាតុចូល និងវត្ថុបណ្តុះបណ្តាល។

១៣.វិស័យឧស្សាហកម្មក្នុងប្រទេសកម្ពុជាកំពុងតែរីកចំរើន ជាពិសេសដោយសារកំណើនយ៉ាងឆាប់រហ័សនៅក្នុងវិស័យកាត់ដេរ។ ទោះបីជាយ៉ាងណាក៏ដោយ ការកើនឡើងនូវការងារនៅតែមានកំរិតទាបដដែរគឺ (៨%) ដើម្បីរួមចំនែកការផ្លាស់ប្តូរដែលមានលំដាប់ណាមួយ ជាឧទាហរណ៍ការផ្លាស់ប្តូរពីការងារដែលមានផលិតភាពទាប ទៅជាវិស័យដែលមានផលិតភាពខ្ពស់។ វិស័យឧស្សាហកម្មនឹងទាមទារអោយមានពិពិត្តកម្ម(diversification) ដែលជាការចាំបាច់សំរាប់ការនាំចេញដោយសម្បូរបែប ដែលនេះទាមទារអោយមានការយកចិត្តទុកដាក់យ៉ាងខ្លាំងខ្លា ក្នុងការលើកទឹកចិត្តវិនិយោគិនក្នុងស្រុក ជាពិសេសគឺសហគ្រាសខ្នាតតូច និងមធ្យម។ សមាមាត្រពលករបរទេសមានកំរិតខ្ពស់នាពេលបច្ចុប្បន្ននៅក្នុងវិស័យការងារបច្ចេកទេស និងក្នុងឧស្សាហកម្មនាំចេញ ដែលនេះទាមទារអោយមានថយចុះតាមរយៈកម្មវិធីសមស្របមួយនៃកម្ពុជារូបនីយកម្ម ទៅលើជំនាញដែលជាគោលដៅ។ ការសិក្សានេះបង្ហាញថាសមត្ថភាពប្រកួតប្រជែងនាំចេញរបស់ប្រទេសកម្ពុជា មិនមែនពឹងផ្អែកលើកម្លាំងពលកម្មថោកនោះទេ តែទៅលើការមានផលិតភាពនិងជំនាញ។ គួរតែមានការជម្រុញកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ សំរាប់សហគ្រាសក្រៅផ្លូវការនិងខ្នាតតូច ហើយឧបសគ្គមួយចំនួន(របស់បញ្ញាំ)ត្រូវលុបបំបាត់ គួរតែមានលទ្ធភាពទទួលបានឥណទាន និងមានបច្ចេកវិទ្យាព្រមទាំងវគ្គបណ្តុះបណ្តាល។ គោលនយោបាយជំនាញទាមទារអោយមាន

ភាពបត់បែនមួយ ដើម្បីកាត់បន្ថយភាពមិនស៊ីសង្វាក់ទៅនឹងទីផ្សារការងារ ហើយគាំទ្រយុវជន និងស្ត្រី ដើម្បីទទួលបានការងារដែលមានប្រាក់ចំណូលល្អប្រសើរ។

១៤.ការសិក្សានេះបានបញ្ជាក់ថាប្រទេសកម្ពុជាត្រូវតែកែសំរួល និង ធ្វើអោយប្រសើរឡើងនូវគោលនយោបាយការងារដែលមានស្រាប់ ក្នុងគោលបំណងលើកកម្ពស់ យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។ គួរតែមានការពង្រឹង និងពង្រីកក្របខណ្ឌគតិយុត្តទីផ្សារការងារដែលមានច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧ ជាមាគ៌ា និងទាមទារអោយមានស្ថាប័នអនុវត្តបទប្បញ្ញត្តិ រួមទាំងការពង្រឹងអង្គការនិយោជក និងនិយោជិតផងដែរ។ ចំពោះគោលនយោបាយទីផ្សារការងារសកម្ម(Active Labour Market Policies-ALMPs) មានសមាសធាតុជាច្រើន ដូចជាការអន្តរាគមន៍ការងារ (ការងារសំណង់សាធារណៈ) ការបង្កើតអោយមានការបណ្តុះបណ្តាលជាផ្លូវការ និងក្រៅផ្លូវការ និងសេវាកម្មមុខរបរសាធារណៈថ្មី។ ការកំណត់ និងសម្របសម្រួលនៃALMPs (ដូចជា គោលនយោបាយមុខរបរសកម្មក្នុងប្រទេសចិន) ត្រូវបានធានា។

១៥. ប្រទេសមានបទពិសោធន៍នៅអឺរ៉ុបបានបង្ហាញថា គោលនយោបាយចំពោះការងារពេញលេញ និងកិច្ចគាំពារសង្គមត្រូវតែស្របគ្នាក្នុងការអភិវឌ្ឍន៍ និងបង្កើតរបបសន្តិសុខសង្គម។ នៅក្នុងប្រទេសកម្ពុជា មានសមាមាត្រទាបក្នុងការបង្កើតការងារក្នុងវិស័យផ្លូវការ និងមានបញ្ហាប្រឈមធ្ងន់ធ្ងរចំពោះថវិកា ដែលធ្វើអោយមានការលំបាកក្នុងការបញ្ចូលគោលនយោបាយទាំងនេះទៅក្នុងក្របខណ្ឌផែនការ។ កិច្ចគាំពារសង្គម នៅក្នុងន័យប្រពៃណី គឺជាជំហានដំបូងដែលទាមទារអោយការព្យាយាមខ្លាំងក្លាមានធនធាននៅថ្នាក់ស្ថាប័ន និងការកសាងសមត្ថភាពផងដែរ។ យុទ្ធសាស្ត្រជាតិគាំពារសង្គម ត្រូវបានរៀបរៀងឡើងពេលថ្មីៗនេះ ប៉ុន្តែមិនទាន់មានស្ថាប័ន និងយន្តការហិរញ្ញវត្ថុសំរាប់អនុវត្តនៅឡើយ។ ការសិក្សាសង្កេតថាជាគុបនាប់បន្សំរបស់យុទ្ធសាស្ត្រជាតិគាំពារសង្គម អាចត្រូវបានបញ្ចូលគ្នាតាមរយៈការបង្កើតទំនាក់ទំនងទៅវិញទៅមករវាងកម្មវិធីការងារ និងកម្មវិធីកិច្ចគាំពារសង្គម។ តាមរយៈគោលការណ៍សាមគ្គីភាព និងបែងចែក នឹងទាមទារអោយបង្កើនធនធាន និងបង្កើតយន្តការអនុវត្ត ដើម្បីអាចបន្តអាណត្តិក្នុងការពង្រីកកិច្ចគាំពារសង្គមដល់ពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះ។ ការសិក្សានេះ បង្ហាញទៀតថា វានឹងល្អប្រសើរក្នុងបរិបទសេដ្ឋកិច្ច សំរាប់រដ្ឋាភិបាលដើម្បីសំរេចបានភាពចន្លោះនៃសារពើពន្ធ និងពង្រីកចំណាយសាធារណៈក្នុងគោលបំណងបង្កើនការងារ និងកិច្ចគាំពារសង្គម។

១៦.ជាសន្និដ្ឋាន ការសិក្សានេះបញ្ជាក់ពីសារៈសំខាន់នៃយុទ្ធសាស្ត្រដែលអាចបង្កើតមុខរបរនិងការងារ គឺមិនត្រឹមតែសំរាប់កាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាពនោះទេ ប៉ុន្តែអាចអោយមានការផ្លាស់ប្តូរតាមលំដាប់នៅក្នុងសេដ្ឋកិច្ច។ នេះទាមទារអោយមានកំណែទម្រង់គោលនយោបាយ និងការផ្លាស់ប្តូរគោលនយោបាយឆ្ពោះទៅកាន់យុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ ដែលរួមបញ្ចូលការងាររបស់ពលរដ្ឋក្រីក្រក្នុងវិធីសាស្ត្រ ដែលមានផលិតភាព និងមានចំណូលច្រើន។ យុទ្ធសាស្ត្រនេះទាមទារអោយមានកិច្ចគាំពារសង្គម និងវិធានសំណាញ់សុវត្ថិភាពសង្គម ដើម្បីគាំទ្រជនងាយរងគ្រោះ ធានានូវកំណើនការងារ និងប្រាក់ចំណូល និងឆ្ពោះទៅកាន់សង្គមដែលប្រកបដោយការងារ។ រដ្ឋាភិបាលកម្ពុជា តាមរយៈ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ បានទទួលស្គាល់តម្រូវការនូវក្របខណ្ឌថ្មីនៃកំណើន និងការកាត់បន្ថយភាពក្រីក្រ។ ការសិក្សាបញ្ជាក់ថាយុទ្ធសាស្ត្របង្កើតការងារ ត្រូវរួមបញ្ចូលក្នុងក្របខណ្ឌឈានទៅការសំរេចនូវគោលដៅអភិវឌ្ឍន៍សហសវត្ស ដែលរដ្ឋាភិបាលបានប្តេជ្ញាយ៉ាងពេញទំហឹង។

# ១.ការសិក្សាៈ សេចក្តីផ្តើម

អ្នករៀបចំគោលនយោបាយនៅក្នុងប្រទេសអភិវឌ្ឍន៍តាមទំលាប់ជឿទៅលើកំណើនសេដ្ឋកិច្ច ដើម្បីសំរេចបាននូវការកាត់បន្ថយភាពក្រីក្រ។ ធនាគារពិភពលោក តាមរយៈការប្រើប្រាស់នូវវិធីឆ្លងប្រទេស ដើម្បីបង្កើតទំនាក់ទំនងរវាងប្រទេសទាំងពីរ បានរកឃើញថា "កំណើនគឺល្អប្រសើរ សំរាប់ភាពក្រីក្រ"។[1] ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលអន្តរវិស័យមិនមានសារៈសំខាន់សំរាប់ប្រទេសមួយនោះទេ ពីព្រោះដោយសារគ្មានទំនាក់ទំនងច្បាស់លាស់ និងស៊ីសង្វាក់គ្នារវាងកំណើន និងការកាត់បន្ថយភាពក្រីក្រ។[2] ជាការពិតណាស់ កំណើនជាលក្ខខណ្ឌមួយចាំបាច់ ប៉ុន្តែថាតើកំណើននេះអាចដោះស្រាយភាពក្រីក្របានកំរិតណាគឺពឹងផ្អែកទៅលើទម្រង់នៃកំណើន និងយុទ្ធសាស្ត្របែងចែកគ្នា លើវិសាលភាពនៃសំណាញ់សុវត្ថិភាពសង្គម និងការឧបត្ថម្ភសង្គម (ឧទាហរណ៍ ទម្រង់នៃចំណាយសាធារណៈ) លើស្ថាប័ន និងទស្សនៈ។ ជាឧទាហរណ៍ដូចដែលបានបញ្ជាក់ដោយស្ថិតិ គឺកំណើនអាចផ្តល់ផលល្អចំពោះពលរដ្ឋក្រីក្រ ប៉ុន្តែវាផ្តល់នូវភាពប្រសើរជាងចំពោះក្រុមដែលមានប្រាក់ចំណូលខ្ពស់ ដូចនេះ វិសមភាពនៅតែមាន។ ទោះបីជានៅក្នុងប្រទេសឥណ្ឌា និងប្រទេសចិន ដែលមានកំណើនខ្ពស់ ក៏នៅតែមានការជជែកវែកញែក និងមន្ទិលថាតើកំណើននេះអាចជួយដោះស្រាយភាពក្រីក្របានកំរិតណា នៅក្នុងសេដ្ឋកិច្ចប្រទេសទាំងពីរ។ អ្នកវិភាគសន្និដ្ឋានថាវិសមភាពមានការកើនឡើង ខណៈពេលដែលការកាត់បន្ថយភាពក្រីក្រមិនទទួលបានលទ្ធផលល្អដូចអត្រាខ្ពស់នៃកំណើនទេ។[3]

បទពិសោធន៍អន្តរជាតិបញ្ជាក់យ៉ាងច្បាស់ថា គ្មានទំនាក់ទំនងដែលមិនផ្លាស់ប្តូររវាងកំណើន និងភាពក្រីក្រនោះទេ។ ប្រសិនបើប្រទេសមួយពឹងផ្អែកទៅលើការកាត់បន្ថយភាពក្រីក្រដោយពឹងលើ កំណើន តើប្រទេសត្រូវរង់ចាំយូរយ៉ាងណាដើម្បីទទួលបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ? ដូចនេះ ប្រទេសនេះត្រូវតែត្រួតពិនិត្យមិនត្រឹមតែទម្រង់នៃកំណើននោះទេ ប៉ុន្តែទៅលើវិធីដែលផ្សារភ្ជាប់រវាងកំណើន និងភាពក្រីក្រ និងអ្វីជាដំណើរការគោលនយោបាយ និង ផែនការអន្តរាគមន៍របស់រដ្ឋាភិបាលដែលចេញជាលទ្ធផលក្នុងការផ្លាស់ប្តូរភាពក្រីក្រតាមរយៈកំណើន។

[1] Dollar និង Kray (2002) បានលើកឡើងពីបញ្ហាខាងលើដោយផ្អែកលើការសិក្សាឆ្លងវិស័យក្នុងប្រទេសចំនួន ៩២ ។

[2] មើល ការសិក្សាពីប្រទេសផ្សេងៗនៅក្នុង R. Islam ed. (2006)

[3] មើល J. Ghose (2010) សម្រាប់ការសិក្សាប្រៀបធៀបថ្មីៗស្តីអំពីភាពក្រីក្រ និងវិសមភាព នៅប្រទេសឥណ្ឌា និងចិន។

ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ត្រូវតែបង្ហាញថា ខ្លួនមិនត្រឹមតែជំរុញ និងពង្រឹងយន្តការនៃកំណើនទេ ប៉ុន្តែត្រូវជានាការពារពលរដ្ឋក្រីក្រ និងងាយរងគ្រោះពីការផ្លាស់ប្តូរនៃកំណើន។ ប្រទេសភាគច្រើនតែងតែជួបប្រទះបញ្ហាក្នុងប្រទេស (ទិន្នផលត្រូវបានបំផ្លាញ និងបាតុភូតធម្មជាតិ) និង/ឬ បញ្ហាដូចជាវិបត្តិសេដ្ឋកិច្ចសកលលោក ដែលនេះអាចទាញកម្លាំងការងារមួយចំនួនធំអោយស្ថិតនៅក្រោមបន្ទាត់ក្រីក្រ[4] ហើយប្រទេសដែលមានចន្លោះសារពើពន្ធតិច អាចប្រឈមមុខនឹងការងារដ៏ធ្ងន់ធ្ងរដើម្បីត្រលប់ទៅវិសាលភាពស្តង់ដានៃភាពក្រីក្រវិញ។

ក្នុងពេលថ្មីៗនេះ កំណើនលំអៀងទៅរកភាពក្រីក្រ (Pro-Poor Grown) អ្នករៀបចំគោលនយោបាយ បានចាប់ផ្តើមឆ្លុះបញ្ចាំងកំណើនដែលគាំទ្រជនក្រីក្រ។ តើហេតុអ្វីចាំបាច់មានយុទ្ធសាស្ត្រ PPG ប្រសិនបើ កំណើនគឺល្អសំរាប់ជនក្រីក្រ? ជាការពិតភ្នាក់ងារផ្តល់ជំនួយមួយចំនួន រួមមានធនាគារពិភពលោក បានរៀបចំករណីសិក្សាយ៉ាងម៉ត់ចត់ទៅលើប្រទេសចំនួន១៤ ក្នុងគោលបំណងយល់ពីទម្រង់នៃកំណើន ដែលអាចកាត់បន្ថយភាពក្រីក្របានល្អប្រសើរ។[5] ការសិក្សាទាំងនេះបង្ហាញឱ្យឃើញទំនាក់ទំនងរវាង PPG និងកត្តាមួយចំនួន ពីទម្រង់ម៉ាក្រូសេដ្ឋកិច្ច ទៅគោលនយោបាយ និងការអន្តរាគមន៍ឆ្ពោះទៅកាន់កសិកម្ម សកម្មភាពជនបទដែលមិនមែនជាកសិកម្ម គោលនយោបាយ និងការឧបត្ថម្ភសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ មានការជជែកវែកញែកលើ PPG ចំពោះបញ្ហាពីរយ៉ាង ដែលទីមួយ ទាក់ទងទៅនឹងថាតើវាត្រូវបានវាស់វែងដោយវិធីណា (ប្រហាក់ប្រហែល ឬ ដាច់ខាត) និងម្យ៉ាងទៀតតើយុទ្ធសាស្ត្រអ្វីដែលសេដ្ឋកិច្ចគួរតែជ្រើសយកដើម្បីសំរេចបាននូវស្តង់ដារនេះ។[6] យើងអាចនិយាយបានម្យ៉ាងទៀតថា ការសិក្សានៅតែមិនច្បាស់ថា អ្វីដែលជាកត្តាកណ្តាលដែលអាចកាត់បន្ថយ ភាពក្រីក្រនៅពេលមានកំណើន។

នៅក្នុងបរិបទនេះ សមាសធាតុសាមញ្ញជាក់ស្តែងមួយ ដែលយើងអង្កេតឃើញទាំងក្នុងបរិបទសេដ្ឋកិច្ចរីកចំរើនអំឡុងមុនសង្គ្រាម និងពេលបច្ចុប្បន្ននៅក្នុងប្រទេសអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ គឺមានទំនាក់ទំនងជិតគ្នា រវាងកំណើននៃការងារដែលមានផលិតភាព និងការកាត់បន្ថយភាពក្រីក្របានដោយជោគជ័យ។ សេដ្ឋកិច្ចរីកចំរើនអំឡុងទសវត្ស ១៩៥០ និង១៩៦០ បន្តនូវគោលបំណងការងារពេញលេញដែលជាគោលបំណងសំខាន់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ពួកគេ។ ស្រដៀងគ្នានេះដែរ នៅក្នុងសេដ្ឋកិច្ចអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ ទម្រង់ស្មើភាពនៃកំណើន (យោងទៅតាមកម្មវិធីនៃកំណែទម្រង់ដីធ្លីនៅក្នុងករណីមួយចំនួន) ដែលគាំទ្រដោយឧស្សាហូបនីយកម្មដែលពឹងផ្អែកលើការ នាំចេញ និងកម្លាំងការងារធន់ធ្ងន់ ត្រូវបានចាត់ទុកថាជាចលករសំខាន់ ឈានឆ្ពោះទៅកាន់ ការងារស្ទើរតែពេញលេញ និងការកាត់បន្ថយភាពក្រីក្រ។ ប្រទេសមួយចំនួន ជាពិសេសប្រទេសក្នុងទ្វីបអឺរ៉ុប ក៏បន្តការអភិវឌ្ឍស្ថាប័នសង្គម និងប្រព័ន្ធគាំពារសង្គម (ទោះបីជាមានភាពលំអិតផ្សេងគ្នាក៏ដោយ) ដែលថាសង្គម

---

[4] ជាឧទាហរណ៍ មើល CDRI (2010) ករណីផលប៉ះពាល់នៃវិបត្តិលើប្រទេសកម្ពុជា

[5] ការសិក្សាធ្វើឡើងតាមរយៈភាពជាដៃគូរវាងធនាគារពិភពលោក, GTZ, AFD និង DFID

[6] មើល Ravallion (2004)

ដែលមានសាមគ្គីភាព អាចទទួលខុសត្រូវចំពោះអ្នកអត់ការងារធ្វើ ពេលដែលសេដ្ឋកិច្ចធ្លាក់ក្នុងកំរិតដែលគ្មានការងារពេញលេញ។

ផែនការគោលនយោបាយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពេលបច្ចុប្បន្ននេះ ដែលប្រឈមនឹងភាពក្រីក្រខ្ពស់ និងការផ្លាស់ប្តូរឆាប់រហ័សនៃកំនើន និងភាពងាយរងគ្រោះក្នុងចំណោមជនក្រីក្រ មានទំនោរឆ្ពោះទៅវត្ថុបំណងពីរ គឺការបង្កើនមុខរបរនិងការងារ និងបង្កើនកិច្ចគាំពារសង្គម។ យើងសង្កេតឃើញមានការចូលរួមយ៉ាងខ្លាំងខ្លាទៅលើការធ្វើផែនការឆ្ពោះទៅយុទ្ធសាស្រ្តPPGដើម្បីសំរេចបានវត្ថុបំណងទាំងពីរ។ យុទ្ធសាស្រ្តPPG នេះត្រូវបានគាំទ្រ ដើម្បីផ្តល់ឥទ្ធិពលដល់ការប្តេជ្ញាចិត្តរបស់ពួកគេដើម្បីសំរេចបាន គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ជាពិសេសគោលដៅដែលបានកំណត់នៃការកាត់បន្ថយភាពក្រីក្រត្រឹមពាក់កណ្តាលនៅឆ្នាំ២០១៥ និងដំណើរការដែលមិនបានកំណត់ឆ្ពោះទៅគោលបំណងនៃការងារពេញលេញ និង មានផលិតភាព និងការងារសមរម្យ (គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ 1b )។ ខណៈពេលដែលការបង្កើតការងារប្រកបដោយផលិតភាព ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងថា ជាដំណើរការដ៏សំខាន់មួយសំរាប់ការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព ប្រទេសភាគច្រើនចាត់ទុកថា ការងារជាសំណល់នៃកំណើន។ មេរៀនពីប្រទេសមានបទពិសោធន៍នៃការអនុវត្តការងារប្រកបដោយភាពជោគជ័យទាមទារអោយមានការរៀបចំ និងបញ្ចូលយុទ្ធសាស្រ្តជាតិស្តីពីមុខរបរនិងការងារ ទៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ប្រទេស។

ខណៈពេលដែល យុទ្ធសាស្រ្តជាតិស្តីពីមុខរបរ ត្រូវតែជាគោលការណ៍នៅក្នុងយុទ្ធសាស្រ្តរយៈពេលមធ្យមមួយ ហើយដើម្បីគាំទ្រប្រជាពលរដ្ឋភាគច្រើនដែលស្ថិតក្នុងភាពងាយរងគ្រោះ គឺទាមទារអោយបញ្ចូលវិធានការដទៃមួយចំនួន ដើម្បីរួមបញ្ចូល ក្នុងចំណោមយុទ្ធសាស្រ្តនៃការពង្រីកកិច្ចគាំពារសង្គម និង ប្រព័ន្ធសំណាញ់សន្តិសុខសង្គម។ ពេលបច្ចុប្បន្ន មានកម្មវិធីសេដ្ឋកិច្ចប្រភេទនេះជាច្រើននៃការអន្តរាគមការងារ និងទីផ្សារការងារ និងកម្មវិធីនៃការឧបត្ថម្ភសង្គមមិនមានភាគទាន។ ដែលនេះភាគច្រើនផ្តល់ប្រសិទ្ធភាពភ្លាមៗ និងបណ្តោះអាសន្ន និង មានឧបសគ្គសំរាប់ការពង្រីកកម្មវិធីមួយសំរាប់ការបង្កើនកម្លាំងពលកម្ម ដោយសារតែថវិកាតិច។

ផែនការអភិវឌ្ឍន៍ ស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងតែង ជាពិសេសបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចសកលលោក កាលពីពេលថ្មីៗនេះ។ ដែលនេះទាមទារអោយមានការកើនឡើងនូវការយល់ស្របមួយដែលបញ្ជាក់ថា វាមានហានិភ័យខ្ពស់សំរាប់ផែនការអភិវឌ្ឍន៍ពេលអនាគត ដែលមិនបញ្ចូលយុទ្ធសាស្រ្តកំណើនដែលបង្កើតការងារ និង ទម្រង់កិច្ចគាំពារសង្គមអប្បរមាមួយ។ គោលបំណងទាំងពីរនេះមិនដាច់ចេញពីគ្នានោះទេ ប៉ុន្តែមានទំនាក់ទំនងទៅវិញទៅមក និងទាមទារអោយមានការជំរុញនៅក្នុងវិធីសាស្រ្តសមាហរណកម្មមួយ។ ការអនុវត្តគោលនយោបាយពេលថ្មីៗនេះ នៅក្នុងប្រទេស ឥណ្ឌា ប្រេស៊ីល ចិន និងប្រទេសអាហ្វ្រិកខាងត្បូង លើការសំរេចបានគោលបំណងភ្លោះនេះ គឺផ្តល់ចំណេះដឹង។

ការសិក្សានេះមានបំណងដើម្បីបង្កើតតម្រូវការសំរាប់ និងប្រយោជន៍ នៃ យុទ្ធសាស្ត្រការងារជាតិនៅក្នុងប្រទេសកម្ពុជា ជាពិសេសទាក់ទងនឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការសំរេចបាននូវគោលដៅក្រោម គោលដៅអភិវឌ្ឍន៍សហសវត្ស ដែលរួមមានការកាត់បន្ថយភាពក្រីក្រ និងការទទួលបាននូវការងារប្រកបដោយផលិតភាពពេញលេញ និងការងារសមរម្យ។ ការសិក្សាឆ្លុះបញ្ចាំងនូវវិធីដែលភ្ជាប់ ទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងវិធីសាស្ត្ររួមក្នុងការធ្វើគោលនយោបាយមានភាពចាំបាច់ សំរាប់ កសាងគំនិតស្របមួយ និងបង្កើតនូវយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។ ការសិក្សានេះមិនមែនជាយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារនោះទេ ប៉ុន្តែវាផ្តល់នូវធាតុផ្សំ និងទ្រង់ទ្រាយនៃយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។ ការរកឃើញមួយចំនួននៃរបាយការណ៍ និងបញ្ហាគោលនយោបាយដែលបានលើកឡើងទាមទារមានការបញ្ជាក់អោយបានពិស្តារ។ ដូចនេះការសិក្សានេះ ផ្តោតសំខាន់លើវិសាលភាពយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ នៃក្របខណ្ឌដែលបានបញ្ជាក់ខាងលើ ទោះបីជាការឆ្លុះបញ្ចាំងលើការរួមបញ្ចូលជាសំខាន់រវាងការងារ និងកិច្ចគាំពារសង្គមក៏ដោយ។

ការសិក្សានេះបានរៀបចំដូចខាងក្រោមដែលផ្នែកទី២ ផ្តល់នូវការវាយតម្លៃមួយនៃការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ដើម្បីបន្តនូវគោលដៅអភិវឌ្ឍន៍សហសវត្ស ជាពិសេសការកាត់បន្ថយភាពក្រីក្រ។ វាផ្តល់នូវមូលដ្ឋានមួយនូវតម្រូវការនៃការរួមបញ្ចូល យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលពឹងផ្អែកលើការងារសំរាប់ការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព និងដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ នៃការសំរេចបានការងារដែលមានផលិតភាពពេញលេញ និងការងារសមរម្យ។ ផ្នែកទី៣ និងសង្កេតទៅលើការប្រឈមរបស់ការងារ និងទីផ្សារការងារនៅក្នុងសេដ្ឋកិច្ច ជាពិសេសពេលដែលគោលបំណងគោលនយោបាយកាត់បន្ថយភាពអត់ការងារធ្វើ និង/ឬ ការបង្កើនសមាមាត្រការងារដល់ពលរដ្ឋ មិនមានប្រសិទ្ធិភាព។ ចរិតលក្ខណៈទីផ្សារមួយចំនួនក៏ត្រូវបានអង្កេតផងដែរ ពីព្រោះយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារពាក់ព័ន្ធទាំងស្រុងទៅគោលនយោបាយសេដ្ឋកិច្ច និងទីផ្សារការងារ។ ផ្នែកទី៤ នឹងបង្ហាញជំហរគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និងចំនុចដែលទាមទារ សំរាប់ការបញ្ចូលគោលបំណងការងារទៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ហើយក៏លើកឡើងនូវបំរាមមួយចំនួន ដែលទាក់ទងទៅនឹងឧបករណ៍នៃផែនការម៉ាក្រូសេដ្ឋកិច្ច។ ផ្នែកទី៥ នឹងពិនិត្យទៅលើគោលនយោបាយ និងការងារតាមវិស័យដែលអាចផ្តល់នូវលទ្ធភាពបង្កើតការងារ ជាឧទាហរណ៍ នៅក្នុងកសិកម្ម ពាណិជ្ជកម្ម និងឧស្សាហូបនីយកម្ម សេវាកម្ម និងសំណង់។ ផ្នែកទី៦ ពិភាក្សាលើផ្នែកផ្គត់ផ្គង់ទីផ្សារការងារ ជាពិសេសអាទិភាពខ្ពស់នៃការអភិវឌ្ឍជំនាញ និងភាពមានការងារធ្វើ នៅគ្រប់វិស័យនៃសេដ្ឋកិច្ច ហើយនឹងត្រួតពិនិត្យទៅលើគោលនយោបាយទីផ្សារការងារ ដើម្បីលើកទឹកចិត្តក្រុមអសមត្ថភាព និងការបង្កើតអោយមានគោលនយោបាយទីផ្សារការងារសកម្ម(ALMP)។ នៅក្នុងផ្នែកទី៧ នឹងមានការត្រួតពិនិត្យទៅលើសារៈសំខាន់នៃការផ្សារភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយកិច្ចគាំពារសង្គម និងគោលនយោបាយមុខរបរនិងការងារ ក៏ដូចជាតម្រូវការអភិវឌ្ឍយុទ្ធសាស្ត្រមួយសំរាប់រៀបចំការរួមបញ្ចូលគោលនយោបាយទាំងពីរ។
សេចក្តីសន្និដ្ឋាន នឹងមានបញ្ជាក់នៅក្នុងផ្នែកទី ៨។

## ២.បរិបទនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបង្កើតការងារ សម្រាប់ប្រទេសកម្ពុជា

### គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងយុទ្ធសាស្ត្រចតុកោណ

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញយ៉ាងច្បាស់នូវការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងសេដ្ឋកិច្ច និងដើម្បីសំរេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលបានកំណត់ត្រឹមឆ្នាំ២០១៥។ ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ បានសំដែងនូវការប្តេជ្ញាចិត្តនេះ និងវិធីសាស្ត្រដែលយុទ្ធសាស្ត្រអភិវឌ្ឍន៍អាចត្រូវបានកំណត់ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។[7] ដូចដែលអស់លោក លោកស្រីជាអ្នកអានបានជ្រាបនូវសេដ្ឋកិច្ច និងផែនការរបស់កម្ពុជា ជ្រុងនយោបាយសំខាន់នៃយុទ្ធសាស្ត្រចតុកោណគឺ ១.ការសំរេចបាននូវវិស័យកសិកម្ម ២.ហេដ្ឋារចនាសម្ព័ន្ធប្រទេស ៣.ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស និង ៤.ការអភិវឌ្ឍវិស័យឯកជន និងការងារ។ ផែនការសំខាន់គឺ ការរួមបញ្ចូល និងការគាំទ្រតាមរយៈអភិបាលកិច្ចល្អ និងកំណែទម្រង់ផ្សេងៗដែលនឹងមានបញ្ជាក់នៅពេលក្រោយ[8] (សូមពិនិត្យមើលរូបខាងក្រោម)។

**រូបភាពទី ២.១**

ដ្យាក្រាមយុទ្ធសាស្ត្រចតុកោណ




[7] ជាការពិត យុទ្ធសាស្ត្រចតុកោណបន្ថែមបញ្ចូលនៅក្នុង *ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ឆ្នាំ 2009-2013* ដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗនេះ។ ចំណងជើងឯកសាររបស់រាជរដ្ឋាភិបាលនេះគឺ "ដើម្បីកំណើន ការផ្តល់ការងារ សមភាព និងប្រសិទ្ធភាព ត្រូវសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស"

[8] Cf. ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ឆ្នាំ 2006-2010

អាចមានការលើកឡើងថា ជាមួយនឹងជោគជ័យផ្នែកសេដ្ឋកិច្ចពេលថ្មីៗនេះរបស់ប្រទេស ដំណើរការសង្គមនៃរដ្ឋាភិបាលកម្ពុជាដើម្បីបន្តក្របខណ្ឌយុទ្ធសាស្ត្រចតុកោណ អាចត្រូវបានឆ្លុះបញ្ចាំងដោយដំណើរការរបស់ប្រទេសឆ្ពោះទៅកាន់ គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា។ តួលេខសង្ខេប នៃការសំរេចបាន និង ការមិនទាន់សំរេចបានទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា មានបង្ហាញនៅក្នុងតារាងទី ២.១។

## តារាងទី ២.១

## គោលដៅអភិវឌ្ឍន៍សហសវត្ស និងស្ថានភាពវិវត្ត

| សូចនាករ | | ស្ថាពភាពដំនើរការ | ឆ្នាំដំបូងបំផុត | ឆ្នាំពាក់ កណ្តាល | ឆ្នាំចុងក្រោយបំផុត |
|---|---|---|---|---|---|
| *គោលដៅ១* | | | | | |
| | ភាពក្រីក្រ (% តិចជាង ១.២៥ដុល្លារ/ថ្ងៃ) | មានដំណើរការយឺត | 48.6 (1994) | 40.2 (2004) | 25.8 (2007) |
| | ការងារងាយរងគ្រោះ(%នៃការងារសរុប) | .... | 86.8 (1998) | .. | 79.0 (2008) |
| | ភាពក្រីក្រការងារ (%) | .... | | 38.4 (2003) | |
| | សមាមាត្រពលរដ្ឋមានការងារ(%) | ...... | 73.0 (1998) | .. | 77.0 (2008) |
| *គោលដៅ ២* | ការចុះឈ្មោះចូលរៀនបឋមសិក្សា(%) | មានដំណើរការយឺត | 72.2 (1991) | 87.3 (2000) | 88.6 (2008) |
| | កុមារបញ្ចប់ថ្នាក់បឋមសិក្សា(%) | មានដំណើរការយឺត | 47.9 (1998) | 55.0 (2002) | 54.4 (2007) |
| *គោលដៅ ៣* | សមាមាត្រកុមារា និង កុមារីចុះឈ្មោះចូលរៀនបឋមសិក្សា(%) | មានដំណើរការ | 81.1 (1991) | 87.2 (2000) | 93.6 (2008) |
| | សមាមាត្រកុមារា និង កុមារីចុះឈ្មោះចូលរៀនអនុវិទ្យាល័យ(%) | មានដំណើរការ | 43.0 (1991) | 54.7 (2000) | 81.6 (2007) |
| | សមាមាត្រកុមារា និង កុមារីចុះឈ្មោះចូលរៀនមហាវិទ្យាល័យ(%) | មានដំណើរការយឺត | 33.5 (2000) | 46.2 (2004) | 53.6 (2008) |
| | ចំនួនសមាជិកសភាជាស្ត្រី | .. | 6.0 (1997) | 7.0 (2003) | 16.3 (2009) |
| *គោលដៅ ៤* | អត្រាមរណៈនៃកុមារអាយុក្រោម ៥ ឆ្នាំ (ក្នុងចំនោម 1000 នាក់) | មានដំណើរការយឺត | 116.7 (1990) | 106.4 (2000) | 89.5 (2008) |
| | អត្រាមរណៈនៃទារក (ក្នុងចំនោម ១000 នាក់) | មានដំណើរការយឺត | 85.3 (1990) | 79.6 (2000) | 69.3 (2008) |
| | ការឆ្លងជំងឺកញ្ជ្រិលចំពោះកុមារអាយុ១ ឆ្នាំ(%) | .. | 34.0 (1990) | 65.0 (2000) | 89.0 (2008) |
| *គោលដៅ ៥* | សមាមាត្រមរណៈមាតា (ក្នុងចំនោម ១000 00នាក់) | .. | .. | .. | 540 (2005) |
| | ការសំរាលកូនដោយគ្រូពេទ្យជំនាញ(%) | មានដំណើរការយឺត | 34.0 (1998) | 31.8 (2000) | 43.8 (2005) |
| | ការផ្តល់កំនើតដោយដោយមានការថែទាំវេជ្ជសាស្ត្រយ៉ាងតិចម្តង(%នៃការផ្តល់កំនើត) | .. | | | 69.0 (2005) |
| *គោលដៅ ៦* | ការឆ្លងជំងឺអេដស៍(%នៃពលរដ្ឋ ១៥-៤៩) | មានដំណើរការ | 0.7 (1990) | 1.6 (2000) | 0.8 (2007) |
| | ការទទួលបានការព្យាបាល (%នៃពលរដ្ឋដែលផ្ទុកមេរោគអេដស៍ដំណាក់កាលធ្ងន់ធ្ងរ) | .. | | 54.0 (2006) | 67.0 (2007) |
| | វិសាលភាពនៃជំងឺរបេង(ក្នុងចំណោមប្រជាជន ៖ ១00 000) | មានដំណើរការ | 585 (1990) | 530 (2000) | 490 (2008) |
| *គោលដៅ ៧* | តំបន់ព្រៃឈើ(%នៃផ្ទៃដី) | មានដំណើរការយឺត | 73.3 (1990) | 65.4 (2000) | 56.7 (2007) |
| | ធនធានទឹកដែលល្អ(%នៃពលរដ្ឋដែលមានលទ្ធភាព) | មានដំណើរការ | 19.0 (1995) | 38.0 (2000) | 65.0 (2006) |
| | សេវាអនាម័យដែលល្អ(%នៃពលរដ្ឋដែលមានលទ្ធភាព | មានដំណើរការយឺត | 8.0 (1995) | 16.0 (2000) | 28.0 (2006) |

*ប្រភព៖ WDI លើកលែងការងារងាយរងគ្រោះនិងសមាមាត្រប្រជាជនមានការងារធ្វើ ដែលយកចេញពីNIS (2010)ផ្អែកទៅលើជំរឿនប្រជាជននិងទិន្នន័យ LFS សំរាប់ប្រជាជនអាយុ១៥ឆ្នាំឡើង។ ដំណើរការដកស្រង់ពីការវាយតំលៃដោយ UNESCAP, ADB, UNDP (2010) ការសំរេចបានMDG ក្នុងយុគ្គសម័យមិនជាក់លាក់នៃសកលលោក៖ របាយការណ៍តំបន់ Asia Pacific 2009/10 តារាង១-3។ ដំណើរការ=សង្ឃឹមសំរេចបានគោលដៅក្នុងឆ្នាំ ២០១៥ ដំណើរការយឺត= សង្ឃឹមសំរេចបានគោលដៅក្រោយឆ្នាំ ២០១៥ គ្មានដំណើរការ=នៅដដែល ឬ ថយក្រោយ។*

តារាងបង្ហាញថាខណៈពេលដែលប្រទេសកំពុងតែមានដំណើរការល្អប្រសើរជាទូទៅ លទ្ធផលមានភាពលាយឡំគ្នា ទាក់ទងទៅ នឹងសូចនាករច្បាស់លាស់។ សេដ្ឋកិច្ចកំពុងមានដំណើរការទាក់ទងទៅនឹងគោលបំណងកាត់បន្ថយវិសាលភាពនៃភាពក្រីក្រត្រឹមពាក់កណ្តាលនៅឆ្នាំ ២០១៥ ក៏ដូចជា គោលដៅអភិវឌ្ឍន៍សហសវត្សទី៣ លើការសំរេចបានសមាមាត្រចុះឈ្មោះចូលរៀនរបស់កុមារា និងកុមារី នៅក្នុងបឋមសិក្សា និងអនុវិទ្យាល័យ។ ក្រៅពីគោលដៅទាំងនេះ គោលដៅដទៃទៀតមានដំណើរការយឺត ជាពិសេសទំហំនៃជនងាយរងគ្រោះ និងជនក្រីក្រដែលកំពុងប្រកបការងារ (ចង្អុលបង្ហាញនៅក្នុងចំនុច ១.ខ របស់គោលដៅ) ទោះបីជាមានការធ្លាក់ចុះ ក៏នៅតែមានកំរិតខ្ពស់ដែលមិនអាចទទួលយកបានដែរ។ នៅក្នុងករណីដទៃទៀត ជាឧទាហរណ៍គោលដៅអត្រាមរណៈកុមារ ដំណើរត្រូវបានផ្អាក និង/ឬ ត្រលប់ក្រោយ។ មានរយៈពេលត្រឹមតែ ៥ឆ្នាំទៀត ដើម្បីអនុវត្តអោយកាន់តែប្រសើរឡើងជាមួយនឹងការពង្រឹងកម្មវិធីអន្តរាគមន៍ ក៏ដូចជាពង្រីកចំណាយសាធារណៈ ដើម្បីបន្តសកម្មភាពជាមួយគោលដៅដទៃទៀត។ ពេលជាមួយគ្នាផងដែរ កត្តាស្ថាប័ន និងវប្បធម៌សង្គមក៏ទាមទារអោយមានដំណោះស្រាយផងដែរដើម្បីរំកិលខិតជិតគោលដៅដទៃទៀតដូចជា ដោះស្រាយការបោះបង់ការសិក្សា។

ទោះបីជាឱនភាព គោលដៅអភិវឌ្ឍន៍សហសវត្ស មានលទ្ធផលមិនល្អប្រសើរ វាជាការសំខាន់ណាស់ក្នុងការសួរសំនួរថាតើលទ្ធផលសំរេចបានកន្លងមកនៃគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ផ្តល់នូវតួលេខពិតប្រាកដនៃដំណើរការសេដ្ឋកិច្ច និងសង្គមច្បាស់លាស់សំរាប់សេដ្ឋកិច្ចកម្ពុជា និងថាតើការលទ្ធផលដែលសំរេចបាននេះមាននិរន្តរភាព និងកើនឡើងបានកំរិតណា? ប៉ុន្តែយើងត្រូវទទួលស្គាល់ការពិតថាផែនការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាទើបតែចាប់ផ្តើម និងដាច់ដោយឡែកពីសេដ្ឋកិច្ចក្នុងពេលសង្គ្រាម និងភាពរឹករេ សេដ្ឋកិច្ចទើបចាប់ផ្តើមរកដំណោះស្រាយដើម្បីរំកិលឆ្ពោះទៅកាន់ការផ្លាស់ប្តូរទាំងស្រុងជាសេដ្ឋកិច្ចទីផ្សារ។[9] ស្ថាប័ន និងការកសាងសមត្ថភាព ច្បាប់ និងក្របខណ្ឌនៃអភិបាលកិច្ចដើម្បីគាំទ្រផែនការអភិវឌ្ឍន៍ គឺស្ថិតនៅក្នុងជំហានពិសោធន៍នៅឡើយ។

## កំណើន និងភាពក្រីក្រ

ដូចដែលបានរៀបរាប់នៅក្នុងផ្នែកមុន សូចនាករសំខាន់ទូទៅនៃដំណើរការសេដ្ឋកិច្ច និងសង្គម គឺការកើនឡើងនូវ ផលិតផលក្នុងស្រុកសរុប និងការកាត់បន្ថយភាពក្រីក្រ (សូមពិនិត្យមើលរូបភាពទី ២.២)។

**រូបភាពទី ២.២**

[9] ចំពោះការទទួលយកកលម្អិតនៃប្រវត្តិសេដ្ឋកិច្ចទំនើបរបស់កម្ពុជា មើល

## អត្រាកំណើនគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ពិតប្រាកដ និងភាពក្រីក្រ (%)




*ប្រភព៖ អត្រាកំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដ ដកស្រង់ពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣, តារាងទី ៨ និង ៩។ អត្រាភាពក្រីក្រ ដកស្រង់ពី NIS (២០១០)។*

កំណើន ផលិតផលក្នុងស្រុកសរុប ពិតប្រាកដនៅក្នុងប្រទេសកម្ពុជាអំឡុងទសវត្ស ១៩៩៨-២០០៧ ជាមធ្យមខ្ពស់ជាង ៩% ដែលជាកំណើនខ្ពស់បំផុតទី៦ លើពិភពលោក។[10] ក្នុងអំឡុងដំហានស្តារឡើងវិញ (១៩៩៩-២០០៣) ប្រទេសកម្ពុជាកត់សំគាល់ កំណើនជិត ៨.៨%នៅក្នុងផលិតផលក្នុងស្រុកសរុប ដែលបានកើនឡើង ទៅដល់ ១០.៣%ក្នុងអំឡុង "ដំហានវិវត្តន៍" (២០០៤-២០០៨)។ អ្នកវិភាគតែងតែអោយតម្លៃលើកំណើនដែលគួរអោយចាប់អារម្មណ៍បែបនេះ ដែលចាប់ផ្តើមពីមូលដ្ឋានដែលទាប។[11] ទោះបីជាយ៉ាងណាក៏ដោយ កំណើនខ្លាំងក្លានៅក្នុងសេដ្ឋកិច្ចជាកត្តាមួយក្នុងការធ្លាក់ចុះនូវវិសាលភាពក្រីក្រ ពី៤៨% ក្នុងឆ្នាំ១៩៩៤ (១.២៥ដុល្លារ ក្នុងមួយថ្ងៃ) មកប្រហែល២៦% ក្នុងឆ្នាំ ២០០៧ (សូមមើលតារាងទី ២.២ ខាងក្រោម)។

[10] Cf. ធនាគារពិភពលោកមានដកស្រង់យោងនៅក្នុង ជួន ណារុន (2010)

[11] Jahilian និង Reyes (2010)

**តារាងទី ២.២៖ អត្រាក្រីក្រ៖ ១.២៥ $ ក្នុងមួយថ្ងៃ  ២$ ក្នុងមួយថ្ងៃ និងខ្សែបន្ទាត់ក្រីក្រថ្នាក់ជាតិ**

| ខ្សែបន្ទាត់ក្រីក្រ | 1994 | 2004 | 2007 |
|---|---|---|---|
| សមាមាត្រតាមចំនួនជាក់ស្តែង(%នៃប្រជាជន) | | | |
| ១.២៥ ដុល្លារ (PPP)ក្នុង១ថ្ងៃ(%) | 48.6 | 40.2 | 25.8 |
| ២ ដុល្លារ (PPP)ក្នុង១ថ្ងៃ(%) | 77.9 | 68.2 | 57.8 |
| ខ្សែបន្ទាត់ ក្រីក្រជាតិ(%) | 39.0 | 34.7 | 30.1 |
| គម្លាតក្រីក្រ(%) | | | |
| ១.២៥ ដុល្លារ (PPP)ក្នុង១ថ្ងៃ(%) | 13.5 | 11.3 | 6.1 |
| ២ ដុល្លារ (PPP)ក្នុង១ថ្ងៃ(%) | 33.3 | 28.0 | 20.1 |

*ប្រភព៖ធនាគារពិភពលោក WDI ១.២៥ ដុល្លារ និង២ ដុល្លារ (PPP) ក្នុងមួយថ្ងៃ។ តារាងភាពក្រីក្រជាតិដក់ស្រង់ពី NIS (2010)*

ដោយសារមិនមានពេលវេលាប៉ាន់ស្មានភាពក្រីក្រ វាជាការលំបាកណាស់ក្នុងការអះអាងពីអត្រាថយចុះនៃភាពក្រីក្រ ដូចជាការបត់បែនភាពក្រីក្រនៃកំណើន។ ទោះបីជាមានទិន្នន័យនៅមានកំរិតក៏យើងត្រូវសង្កេតលើចំនុចខាងក្រោមដែរ៖

- ខណៈពេលដែលមិនមានការប៉ាន់ប្រមាណភាពក្រីក្រអោយបានត្រឹមត្រូវ កំណើនខ្ពស់អាចមានទំនាក់ទំនងខ្លាំងជាមួយនឹងការកាត់បន្ថយភាពក្រីក្រ ដូចជាក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៧ ជាពិសេសភាពក្រីក្រខ្លាំងបានធ្លាក់ចុះ។
- ដូចដែលតារាង ២.១ បង្ហាញថាគ្មានទំនាក់ទំនងដូចគ្នារវាងកំណើន និងការកាត់បន្ថយភាពក្រីក្រនោះទេ និងមិនមានការពន្យល់បកស្រាយណាមួយ ពីទំនាក់ទំនងច្បាស់លាស់រវាងកំណើន និងភាពក្រីក្រនោះដែរ ជាឧហរណ៍ថាតើកំណើនអាចកាត់បន្ថយភាពក្រីក្របានកំរិតណា។ ដូចនេះកំណើនខ្ពស់មិនតែងតែអាចកាត់បន្ថយភាពក្រីក្រ ទៅតាមអត្រាដែលបានបង្ហាញនោះទេ។
- វិធានគម្លាតភាពក្រីក្រ បង្ហាញថាមានភាគរយជាច្រើននៃពលរដ្ឋងាយរងគ្រោះ នៅក្នុងប្រទេសកម្ពុជា( សូមពិនិត្យមើលតារាង២.១ខាងលើ)។ ប្រសិនបើកំរិតភាពក្រីក្រមានអត្រា ២ដុល្លារក្នុងមួយថ្ងៃ នោះវិសាលភាពនៃភាពក្រីក្រកើនឡើងដល់៥៨% ហើយភាពក្រីក្រនិងភាពងាយរងគ្រោះគឺនៅតែខ្ពស់។
- វិបត្តិសេដ្ឋកិច្ចសកលលោកកាលពីពេលថ្មីៗនេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អត្រាកំណើនដែលពេលបច្ចុប្បន្ននេះកំពុងតែថយចុះ និងមូលដ្ឋានគ្រឹះជំរុញ កំណើនក៏ត្រូវបានគិតគូរផងដែរ។[12] ដូចនេះ តារាង ២.២ បង្ហាញ អត្រាកំណើនរបស់ប្រទេសធ្លាក់ចុះយ៉ាងខ្លាំងក្លា ដែលនេះអាចបង្កើនវិសាលភាពនៃភាពក្រីក្រ ប្រសិនបើយើងពឹងផ្អែកតែទៅលើកំណើនតែមួយមុខគត់។

[12] មើលរាជរដ្ឋាភិបាលកម្ពុជា (2010)

លទ្ធផលរបស់ការអង្កេតនេះគឺថាទំនាក់ទំនងរវាងកំណើន និងភាពក្រីក្រមិនតែងតែស៊ីសង្វាក់គ្នានេះទេ ដែលកំណើនជាភាពចាំបាច់ ប៉ុន្តែមិនតែងតែជាលក្ខខណ្ឌដ៏មានប្រសិទ្ធភាពសំរាប់ការកាត់បន្ថយភាពក្រីក្រនោះទេ។ លើសពីនេះទៅទៀត ពីព្រោះគំរោងកំណើនបានធ្លាក់ចុះ ដូចនេះយើងត្រូវរង់ចាំសង្កេតមើលថាតើគោលដៅអភិវឌ្ឍន៍សហសវត្ស លើភាពក្រីក្រដែលកំពុងតែមានដំណើរការ អាចសំរេចបានដែរឬទេ។ ដូចនេះវាជាការសំខាន់ណាស់ដើម្បីស្វែងយល់ និងធ្វើយ៉ាងណាឱ្យកំណើនផ្តល់ ផលប្រយោជន៍ដល់ជនក្រីក្រ។ ប្រសិនបើយន្តការបែងចែកផលប្រយោជន៍មានបញ្ហា គួរតែមានការ កំណត់និងវាយតម្លៃលើដំណើរការច្បាស់លាស់នៃការបែងចែកទ្រព្យសម្បត្តិ និងប្រាក់ចំណូល ការឧបត្ថម្ភសង្គមនិង ការចំណាយសាធារណៈ។ ទស្សនៈដែលថាប្រសិនបើ រចនាសម្ព័ន្ធបែងចែកនៅដដែល (ឧទាហរណ៍ មេគុណ Gini) ដូចនេះកំណើនខ្ពស់អាចឈានទៅដល់ការកាត់បន្ថយភាពក្រីក្រមាន ប្រសិទ្ធជាង បើមិនដូចនោះទេវាមិន អាចទ្រទ្រង់កម្ពុជាបាននោះទេ។

**តារាងទី ២.៣៖ វិធានការវិសមភាព៖ មេគុណ Gini**

| តំបន់ | 1993/94 | 1997 | 2004 | 2007 |
|---|---|---|---|---|
| ភ្នំពេញ | 0.39 | 0.46 | 0.37 | 0.34 |
| តំបន់ទីក្រុង | 0.44 | 0.44 | 0.44 | 0.47 |
| តំបន់ជនបទ | 0.27 | 0.33 | 0.34 | 0.36 |
| ប្រទេសកម្ពុជា | 0.38 | 0.42 | 0.30 | 0.43 |

*ប្រភព៖ NIS (2010) តារាង៣.៥*

ដូចដែលតារាង ២.៣ បង្ហាញថា វិសមភាពដែលបានបង្ហាញដោយ Gini បានកើនឡើងជានិរន្តន៍ក្នុងអំឡុងពេលថ្មីៗនេះ។ កំណើនខ្ពស់នៅក្នុងស្ថានភាពមួយដែលវិសមភាពកើនឡើង អាចកាត់បន្ថយភាពក្រីក្រប្រសិនបើប្រាក់ចំណូលរបស់គ្រួសារក្រីក្រកើនឡើង។ វាជាការប្រថុយប្រថានក្នុងការសន្និដ្ឋានថាចំណូលគ្រួសារក្រីក្រកើនឡើងដោយសារឥទ្ធិពលនៃកំណើន ដូចនេះគួរតែមានភ្នាក់ងារដែលគួរអោយទុកចិត្តមួយដែលអាចប្រែក្លាយកំណើនទៅជាការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តភាព ហើយភ្នាក់ងារដ៏សំខាន់នេះដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីផ្តើម គឺគួរតែការបង្កើតនូវការងារដែលមានផលិតភាព។ ជាដដែលៗ មានភស្តុតាងច្បាស់លាស់ដែលថាប្រទេសកម្ពុជាកំពុងមានដំណើរការ លើគោលដៅអភិវឌ្ឍន៍សហសវត្ស ដែលដំណើរការនេះយឺតជាងប្រទេសដទៃទៀត។ ហើយអ្វីដែលប្រទេសកម្ពុជាអាចអនុវត្តន៍បានល្អប្រសើរគឺ ដំណើរលើ ផលិតផលក្នុងស្រុកសរុបមួយ គោលដៅទី១ ទៅលើការកាត់បន្ថយភាពក្រីក្រពាក់កណ្តាលនៅក្នុងសេដ្ឋកិច្ចត្រឹមឆ្នាំ ២០១៥។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលការពិភាក្សាខាងលើបានបង្ហាញ ការបង្ហាញថាភាពក្រីក្របានថយចុះដោយគ្រាន់តែពឹងផ្អែកលើអត្រាកំណើន ដែលពេលថ្មីៗនេះទទួលផលប៉ះពាល់ដោយវិបត្តិសកលលោក គឺប្រហែលជាការប្រថុយប្រថាន។ នៅក្នុងបរិបទនេះ

វាមានភាពចាំបាច់ដូចគ្នាដើម្បីស្វែងយល់  ពីភាពផ្សេងគ្នានៅក្នុងវិសាលភាពក្រីក្រ  ក្នុងចំណោមក្រុមផ្សេងគ្នានៃប្រជាពលរដ្ឋ និងតំបន់ផ្សេងៗគ្នា។[13]

ជាពិសេសរូបភាពដែលមិនសរុបមួយបង្ហាញថាភាពក្រីក្រក្នុងប្រទេសកម្ពុជា  ជាបាតុភូតជនបទ និងមានភាពខុសគ្នាយ៉ាងខ្លាំងក្លារវាងវិសាលភាពនៃភាពក្រីក្រក្នុងចំណោមតំបន់ជនបទ និងទីក្រុង (សូមពិនិត្យមើល រូបភាព ២.៣) និងក្នុងចំណោមក្រុមមុខរបរផ្សេងៗគ្នា (សូមពិនិត្យរូបភាព ២.៤)។

**រូបភាពទី ២.៣៖ ភាគរយប្រជាជនជនបទ-ក្នុងក្រុង ទាបជាងខ្សែបន្ទាត់ក្រីក្រថ្នាក់ជាតិ**




*ប្រភព៖ NIS (2010)*

**រូបភាពទី ២.៣៖ ភាពក្រីក្របែងចែកតាមសកម្មភាពសេដ្ឋកិច្ច និងមុខរបររបស់មេគ្រួសារ ឆ្នាំ ២០០៤**




[13] ចំពោះការតេស៊ូមតិ មើល NIS-ILO (2010)

ដូចនេះខណៈពេលដែលវិសាលភាពនៃភាពក្រីក្រសរុបបានធ្លាក់ចុះមកត្រឹម ២៦% វាមិនមែនមានន័យថាសំរាប់គ្រប់តំបន់ និងគ្រប់កំរិតប្រាក់ចំណូលនោះទេ ជាពិសេសកសិករដែលមានកសិដ្ឋានផ្ទាល់ខ្លួន និងអ្នកធ្វើកិច្ចការផ្ទះ។ វិធានអន្តរាគមន៍ជាក់លាក់ មានភាពចាំបាច់ណាស់ដើម្បីដោះស្រាយភាពក្រីក្រនៅតំបន់ទីក្រុង ជាយក្រុង និងតំបន់ជនបទ ក៏ដូចជាគាំទ្រក្រុមដែលមានមុខរបរដូចជា កសិករតូចតាច អ្នកមានអាជីវកម្មផ្ទាល់ខ្លួន អ្នកធ្វើកិច្ចការផ្ទះ និងក្រុមងាយរងគ្រោះដទៃទៀត នៅក្នុងវិស័យការងារមិនផ្លូវការ។ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយសង្គមច្បាស់លាស់និងសមធម៌មួយ គឺការផ្តល់ជូនសាធារណៈ និងកម្មវិធីពិសេសដែលផ្តល់ប្រាក់ចំណូល និងការងារទៅដល់ពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ តែទោះជាយ៉ាងណាក៏ដោយទាំងនេះមិនមានការសម្របសម្រួលត្រឹមត្រូវ បណ្តោះអាសន្ន និងមាននិរន្តរន៍ភាពអាស្រ័យលើអ្នកផ្តល់ជំនួយ។[14]

យើងអាចរំលឹកឡើងវិញ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីផ្តើមគោលដៅអភិវឌ្ឍន៍សហសវត្សនៃការកាត់បន្ថយភាពក្រីក្រ គឺមានទំនាក់ទំនងជាមួយនឹងគោលដៅសំរេចបាននូវ ការងារដែលមានផលិតភាពពេញលេញ និងការងារសមរម្យ (គោលដៅអភិវឌ្ឍន៍សហសវត្សរ៍១ខ)។ ដើម្បីអោយសេដ្ឋកិច្ចឈានឆ្ពោះទៅកាន់រដ្ឋមួយដែលមានការងារពេញលេញ វាទាមទារអោយមានការបង្កើត និងធ្វើអោយមាននិរន្តរភាពកំណើន ដែលមាននាំមកវិញនូវការងារដែលមានផលិតភាព។ កម្មវិធីសំណង់សាធារណៈដើម្បីផ្តល់ការងារ និងប្រាក់ចំណូលទៅដល់ប្រជាពលរដ្ឋក្រីក្រ និង/ឬ អ្នកដែលអត់ការងារធ្វើ ដូចដែលបានរៀបរាប់ខាងលើអាចនាំមកនូវភាពធូរស្បើយជាបណ្តោះអាសន្ន។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីសំរេច បាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ខាងលើ គឺត្រូវតាមរយៈយុទ្ធសាស្ត្រការអភិវឌ្ឍន៍ដែលបង្កើតការងារ។

## មុខរបរនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា

## គោលនយោបាយ ក្រលេកមើលប្រទេសខាងកើត?

កំណើនសេដ្ឋកិច្ចខ្លាំងក្លារបស់ប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៧ មានទំនាក់ទំនងជាមួយនឹងកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ចជំនាន់ទីមួយ ឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀង ទីក្រុងវ៉ាស៊ីនតោន (Washington Consensus) និងគោលនយោបាយសេរីផ្សេងៗ ឆ្ពោះទៅកាន់សមាហរណកម្មយ៉ាងខ្លាំងក្លាជាមួយនឹងសេដ្ឋកិច្ចសកលលោក។[15] មានការលេចឡើងនូវគោលគំនិតសេដ្ឋកិច្ច ដែលឈានឆ្ពោះទៅការបើកចំហរសេដ្ឋកិច្ចទាំងមូល និងផ្តោតទៅលើដំណើរការកំណើនដែលពឹងផ្អែកលើការនាំចេញ។ វាមិនមែនជាការលំបាកដើម្បីឈានទៅដល់កំណែទម្រង់គោលនយោបាយផ្សេងៗ រចនាសម្ព័ន្ធលើកទឹកចិត្ត (រួមមានការបន្ធូរពន្ធ និងការផ្ញើរប្រាក់ចំនេញទៅប្រទេសកំណើតវិញ) ក្របខណ្ឌបទប្បញ្ញត្តិ និងធនធានដើម្បីឆ្ពោះទៅកាន់យុទ្ធសាស្ត្រ ទីផ្សារសេដ្ឋកិច្ចសេរីមួយ។ សេដ្ឋកិច្ចរបស់ប្រទេសអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ភាគច្រើន ក្នុងអំឡុង ជំហានដំបូងរបស់ពួកគេនៃកំណើន គឺអនុវត្តនូវយុទ្ធសាស្ត្រកំណើនដែល

---

[14] CDRI (2010); មើលការរួមចំណែកផ្សេងៗនៅក្នុងការត្រួតពិនិត្យការអភិវឌ្ឍប្រចាំឆ្នាំឡើងវិញ

[15] មើល CDRI (ឆ្នាំ2010 , op.cil)

ពឹងផ្អែកកម្លាំងពលកម្មធន់ធ្ងន់ និងការនាំចេញប្រកបដោយភាពជោគជ័យ ហើយអាចទាញផល ប្រយោជន៍បានពីការរីកចំរើនពាណិជ្ជ កម្មក្នុងអំឡុងពេលនោះ។ ប្រទេសកម្ពុជាក៏អនុវត្តដំណើរការ ស្រដៀងគ្នា ហើយទទួលបាននូវលទ្ធផល ស្រដៀងគ្នានេះផងដែរ ដែលជាការពិតណាស់ដែលការរីកចំរើន សេដ្ឋកិច្ចសកលលោក រួមនឹងតម្លៃពលកម្មទាបនៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា ជាការរួមចំនែកក្នុងការ ទទួលបានភាគផលកំណើនយ៉ាងសំខាន់។ ការបង្កើតការងារ ជាពិសេសនៅក្នុងមុខរបរផ្លូវការទទួលបាន ភាពជោគជ័យនៅក្នុងវិស័យជាក់លាក់មួយចំនួនដូចជា កាត់ដេរ សណ្ឋាគារ និងទេសចរណ៍ និងសំណង់។ ក្នុងនាមជាយុទ្ធសាស្ត្រការងារ ដែលកំណើនពឹងផ្អែកលើការលើកទឹកចិត្តការងារ និងការនាំចេញ ប្រសិនបើលក្ខខណ្ឌខាងក្រៅមាន អំណោយផល នោះអាចនាំមកនូវការបង្កើតការងារប្រកបដោយ និរន្តរភាព។ ទោះបីជាយ៉ាងណាក៏ដោយ ពេលដែលលក្ខខណ្ឌខាងក្រៅផ្ទុយ នោះសេដ្ឋកិច្ចដែលពឹងផ្អែក លើការនាំចេញត្រូវប្រឈមមុខនឹងការ ធ្លាក់ចុះដូចដែលយើងសង្កេតឃើញក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចសកល លោកឆ្នាំ២០០៨-២០០៩។ ការងារនៅក្នុងកាលៈទេសៈនេះ មានការលំបាកក្នុងការផ្លាស់ប្តូរថ្លៃផលិត ដែលពាក់ព័ន្ធ ជាពិសេសក្នុងចំណោម ប្រទេសដែលនាំចេញ និងផលិត ផលិតផលស្រដៀងគ្នា។ កម្មករ និងលក្ខខណ្ឌការងារត្រូវបានប៉ះ ពាល់នៅពេល ដែលមានការដាក់កំរិតទៅលើប្រាក់ខែ និងសកម្មភាព សហជីព។ នៅក្នុងប្រទេសកម្ពុជា ការងារ និងប្រាក់ខែរបស់កម្មករ ទទួលរងនូវផលប៉ះពាល់ក្នុងអំឡុង ពេលមានវិបត្តិ និងធ្ងន់ធ្ងរជាងនេះទៅ ទៀត ដោយសារតែការគ្រប់គ្រងអត្រាប្តូរប្រាក់នៅមានកំរិត បើមិនដូចនេះទេប្រហែលជាអាចមាន លទ្ធភាពប្រកួតប្រជែងខ្ពស់ក្នុងការនាំចេញសំលៀកបំពាក់។[16]

ភាពខុសគ្នាសំខាន់គឺប្រហែលជារវាង យុទ្ធសាស្ត្រកំណើនដែលពឹងផ្អែកលើការនាំចេញ របស់ ប្រទេសកម្ពុជា និងប្រទេសនៅអាស៊ីអាគ្នេយ៍ និងអាស៊ីភាគខាងកើតដែលគេបានបញ្ចូលយុទ្ធសាស្ត្រនេះ ទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាទូទៅមួយ ជាមួយនឹងការផ្សារភ្ជាប់ច្បាស់លាស់រវាងរចនាសម្ព័ន្ធក្នុងស្រុកនៃ ការផលិត និងទីផ្សារការងារ។ គោលនយោបាយ និងតម្លៃត្រូវបានកំណត់រួចជាស្រេចសំរាប់សហគ្រាស ក្នុងស្រុក និង រចនាសម្ព័ន្ធធនធានដែលរួមមានជំនាញក្នុងការឆ្លើយតបទៅនឹងឱកាសនាំចេញ សំរាប់ ទំនិញដែលទាមទារកម្លាំងពលកម្មធន់ធ្ងរ។ នៅក្នុងប្រទេសកម្ពុជា វិស័យនាំចេញសំខាន់ គឺសំលៀកបំពាក់ មានទំនាក់ទំនងចុះឡើងនៅក្នុងកំរិតមួយជាមួយនឹងសេដ្ឋកិច្ចក្នុងស្រុក។ លើសពីនេះទៅទៀត មិនដូច ប្រទេសអាស៊ានជិតខាង វិស័យនេះពឹងផ្អែកយ៉ាងខ្លាំងក្លាលើវិនិយោគទុនផ្ទាល់ ដែលនេះមានការធ្លាក់ ចុះយ៉ាងខ្លាំងនៅក្នុងអំឡុងវិបត្តិ។

មិនមែនជារឿងមិនល្អនោះទេដែលយើងបញ្ជាក់ថាការទាក់ទាញវិនិយោគទុនផ្ទាល់ជាផ្នែកមួយនៃ យុទ្ធសាស្ត្រវិនិយោគទូទៅរបស់សេដ្ឋកិច្ច។ ផ្ទុយមកវិញ ប្រទេសអាស៊ីភាគខាងកើត និងអាស៊ីអាគ្នេយ៍នៅ ពេលអតីតកាល និងប្រទេស វៀតណាម និងចិនពេលថ្មីៗនេះដែលពង្រីកវិនិយោគទុនផ្ទាល់បានដោយ ជោគជ័យលើការអនុវត្តការនាំចេញ និងឧស្សាហកម្មដ៏គួរអោយចាប់អារម្មណ៍របស់ខ្លួន។ ទោះបីជាយ៉ាង

[16] ចំពោះករណីសង្ខេបនៃផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោក ឆ្នាំ 2008-2009 លើប្រាក់ឈ្នួល និងការងារនៅកម្ពុជា មើល ចាន់ ដារ៉ារ័ត្ន (2009)

ណាក៏ដោយ ការពឹងផ្អែកដោយចំហលើ វិនិយោគទុនផ្ទាល់ដែលផ្តល់ការបន្ថែមតម្លៃ និងទំនាក់ទំនងចុះឡើងដែលមានកំរិត ទៅលើការលើកទឹកចិត្តការងារ និងវិនិយោគក្នុងស្រុក អាចបង្ហាញនូវការធ្លាក់ចុះ និងភាពងាយរងគ្រោះរបស់សេដ្ឋកិច្ច។ បទពិសេធន៍ពី គោលនយោបាយ ក្រលេកមើលលោកខាងកើត ទាមទារអោយឃើញនូវក្របខណ្ឌទូលាយជាងករណីដូចក្នុងផែនការអភិវឌ្ឍន៍របស់កម្ពុជា។

លើសពីនេះទៀត ក្នុងសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ អាចរក្សានិរន្តភាពនូវតំរូវការការងារ ការផ្លាស់ប្តូរការងារ ពីមានផលិតភាពទាប និងការងារគ្មានជំនាញទៅការងារដែលមានផលិតភាពខ្ពស់ ដែលនេះអាចនាំមកនូវការផ្លាស់ប្តូរតាមលំដាប់ក្នុងសេដ្ឋកិច្ច។[17] នេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងទូលាយនៅក្នុងចំណែក ដែលប្តូរនៅក្នុងវិស័យផ្សេងៗក្នុងការងារសរុបជាមួយនឹងការធ្លាក់ចុះនូវចំណែកក្នុងវិស័យកសិកម្ម និងការកើនឡើងនូវចំនែកក្នុងវិស័យផលិតទំនើប និងសេវាកម្ម។ សេដ្ឋកិច្ចរីកចំរើននៅលោកខាងលិច ក៏ដូចជានៅក្នុងសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍មានបទពិសោធន៍ដែលហៅថាការប្រែប្រួល Lewisian ពេលដែល វិស័យទំនើបដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការងារដែលមានផលិតភាព។ សេដ្ឋកិច្ចប្រភេទនេះ ភាគច្រើនដូចជា កូរ៉េខាងត្បូង តៃវ៉ាន់ និងសិង្ហបូរី វិស័យផលិតទំនើបរួមចំនែកជាង២៥% នៃកម្លាំងពលកម្មសរុប។ ប្រៀបធៀបបញ្ហានេះ ប្រទេសកម្ពុជាត្រូវខិតខំបន្ថែមទៀត មុននឹងការផ្លាស់ប្តូរតាម លំដាប់នេះអាចលេចចេញជារូបរាង (សូមមើលរូប ២.៥)។

[17] និយាយជារួម ការផ្លាស់ប្តូររបស់ Lewisian បានកើតមានឡើង នៅពេលដែលពលកម្មហួសប្រមាណនៅក្នុងវិស័យកសិកម្មផ្ទុះឡើង និងទាញយកដោយវិស័យ (កម្មន្តសាល) ទំនើបដែលកំពុងតែរីកលូតលាស់។

**រូបភាពទី ២.៥៖ សមាសភាពវិស័យនៃតម្លៃបន្ថែម និងមុខរបរពិត (គិតជាភាគរយ)**




*ប្រភព៖ NIS (២០១០); ស្បៀកៅស្ថតប្រជាធ្នារបស NIS ឆ្នា ២០០៥; ទន្នន័យគណនេថ្នាកជាតរបស NIS ឆ្នា ២០០៨ មានបង្ហោះនៅលើទំព័រ [http://www.nis.gov.kh/index.php/statistics/national-accounts](http://www.nis.gov.kh/index.php/statistics/national-accounts)*

រូបភាពខាងលើបង្ហាញថាខណៈពេលដែលចំណែកតាមវិស័យនៃ ផលិតផលក្នុងស្រុកសរុប មានការផ្លាស់ប្តូរដែលលេចចេញជារូបរៀង (ឧទាហរណ៍ ផលិតផលក្នុងស្រុកសរុប ការផលិតកើនពី ១៧ ទៅដល់ ២៧.៥% ក្នុងអំឡុង ឆ្នាំ១៩៩៨-២០០៨) ការបែងចែកការងារនៃវិស័យមិនឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរតាមលំដាប់នោះទេ។ ជាពិសេស ការបែងចែកនៃកសិកម្មក្នុងការងារ នៅតែដដែលក្នុងអំឡុងពេលទសវត្សនេះ។ ខណៈពេលដែលការបែងចែកក្នុងវិស័យផលិតក្នុងការងារ កើនឡើងពីរដងក្នុងអំឡុងពេលនេះ វានៅតែមានកំរិតទាប(៨.៦%) ដើម្បីស្រូបយកកម្លាំងពលកម្មពីវិស័យដែលមានផលិតភាពទាប។ ដូចនេះ ជាតុល្លោះនៃផែនការសេដ្ឋកិច្ចកម្ពុជា ដូចជាកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច ប្រពៃណីដើម្បីជានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការបើកចំហរលឿនឆ្ពោះទៅការអនុវត្ត សមាហរណកម្មខ្លាំងក្លាឡើង និងកំណើនដែលពឹងផ្អែកលើការនាំចេញ ដូចដែលឥឡូវនេះយើងអាចសង្កេតឃើញជាមួយនឹងផលប្រយោជន៍នៃព្រឹត្តការណ៍នេះ មិនទាន់ផ្តល់លទ្ធផលការផ្លាស់ប្តូរតាមលំដាប់បានជាដុំកំភួននោះទេ។ យើងត្រូវសំគាល់សេដ្ឋកិច្ចកម្ពុជាអំឡុងចុងទសវត្ស១៩៩០ ពេលដែលផែនការអភិវឌ្ឍន៍និងកំណែទម្រង់

ចាប់ផ្តើមចាក់ឫស គឺមិនត្រឹមតែព្យាយាមស្តារពីការខូចខាតដោយសង្គ្រាមរយៈពេលវែងនោះទេ ប៉ុន្តែនៅក្នុងអន្តរកាលដែលឈានទៅកាន់សេដ្ឋកិច្ចពឹងផ្អែកលើទីផ្សារ។

ដូចដែលបទពិសោធន៍អន្តរជាតិនៃអន្តរកាលបែបនេះ និងកំណែទម្រង់សេរីបានចង្អុលបង្ហាញឧទាហរណ៍ដូចជាក្នុងប្រទេសចិន និងវៀតណាមពេលថ្មីៗនេះ អ៊ឺរ៉ុបខាងកើត និងអ៊ឺរ៉ុបកណ្តាលអំឡុងទសវត្សរ៍១៩៩០ ដែលនេះទាមទារអោយមានលំដាប់លំដោយ ការគ្រប់គ្រង និងការតាមដាន ប្រុងប្រយ័ត្ននៃកម្មវិធីកំណែទម្រង់។ ខណៈពេលដែលវិស័យឯកជនលេចឡើង ជាប្រភពនៃកំណើនការងារ កំណែទម្រង់គោលនយោបាយ និងស្ថាប័ន សំរាប់ទីផ្សារការងារមានសារៈសំខាន់ដូចកំណែទម្រង់ក្នុងវិនិយោគវិស័យឯកជនផងដែរ។ ដូចនេះវាជាការចាំបាច់ណាស់ក្នុងការរៀបចំបង្កើតគោលនយោបាយ ក្របខណ្ឌបទប្បញ្ញត្តិ ការលើកទឹកចិត្ត និងស្ថាប័នដើម្បីធានាការស្តារសេដ្ឋកិច្ចជាបណ្តើរៗ និងការផ្លាស់ប្តូរតាមលំដាប់នៅក្នុងសេដ្ឋកិច្ច ហើយនៅពេលជាមួយគ្នានេះផងដែរ ធានានូវមុខងារដ៏រលូននៃទីផ្សារការងារ និងកំណើនការងារក្នុងកំរិតខ្ពស់។

## ការពិចារណាឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ក្នុងអំឡុងពេលក្រោយវិបត្តិ

វិបត្តិសេដ្ឋកិច្ចពិភពលោក ដែលមិនត្រឹមតែរាំងសេដ្ឋកិច្ចកម្ពុជានោះទេ ប៉ុន្តែប៉ះពាល់ដល់រាជរដ្ឋាភិបាលក្នុងការផ្តួចផ្តើមវិធានការពិសេសដើម្បីទប់ស្កាត់ផលប៉ះពាល់ទៅលើកំណើន និងប្រជាជនងាយរងគ្រោះ។[18] ប្រហែលជាផលប៉ះពាល់វិជ្ជមានដែលវិបត្តិបាននាំមកគឺការផ្លាស់ប្តូរជាជុំ កំភួនក្នុងវិធីសាស្ត្ររាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រឆ្ពោះទៅកាន់ការអភិវឌ្ឍន៍។ នេះត្រូវឆ្លុះបញ្ចាំងនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលទោះបីជាយើងត្រូវសង្កេតគោលដៅ ដែលប៉ងទុក និងគោលដៅនៃផែនការថ្មីដែលត្រូវបានអនុវត្តក៏ដោយ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្ននៅក្នុងវិបត្តិ និងលទ្ធភាពរបស់វាក្នុងការរក្សាភាពរឹករវខាងក្រៅ បានកែសំរួលឡើងវិញនូវអត្រា កំណើនដែលថយចុះ និងធ្វើផែនការដើម្បីឆ្ពោះទៅកាន់យុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ ដែលផ្លាស់ប្តូរ ពីយុទ្ធសាស្ត្រកំណើនដែលពឹងផ្អែកលើការនាំចេញតែមួយមុខគត់។ នៅបច្ចុប្បន្នភាពដែលបានកែសំរួល យុទ្ធសាស្ត្រចតុកោណ (ជំហានទី២) នឹងត្រូវបានអនុវត្តបន្ត ហើយអាទិភាពខ្ពស់បំផុត គឺការបន្តកាត់បន្ថយភាពក្រីក្រ។ ដោយមិនបោះបោលនូវគោលដៅនៃស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពបើកចំហរនៃសេដ្ឋកិច្ច ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម មានការផ្លាស់ប្តូរនៅក្នុងគំរូអភិវឌ្ឍន៍ៈ

- ការកាត់បន្ថយភាពក្រីក្រ មិនមែនត្រឹមតែដើរតួនាទីនៃកំណើនប៉ុណ្ណោះទេ ប៉ុន្តែជាទម្រង់នៃកំណើនជាពិសេសតាមរយៈការផ្តោតសំខាន់លើ ការអភិវឌ្ឍជនបទ
- ឧបសគ្គលើកំណើនទូលំទូលាយ មិនត្រូវបានបំបាត់តាមរយៈស្ថេរភាព និងសេរីភាពនោះទេ គឺទាមទារអោយមានការខិតខំប្រឹងប្រែងឆ្ពោះទៅកាន់ការផ្លាស់ប្តូរតាមលំដាប់ ការអភិវឌ្ឍជំនាញ និងការបង្កើតការងារ។

---

[18] Cf. CDRI (2010); ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ 2009-2013

ដូចនេះការចំណាយម្តងហើយម្តងទៀតលើកសិកម្មដែលមានគំរោងបង្កើតពី ៧៨ ពាន់លានរៀល ក្នុងឆ្នាំ ២០០៩ ដល់ ១២៨ ពាន់លានរៀលក្នុងឆ្នាំ២០១៣ ស្រដៀងគ្នានេះដែរការបែងចែកការអភិវឌ្ឍន៍ជនបទ នឹងកើនឡើងពី ៥៤.៥ ពាន់លានរៀល ទៅដល់ ១២១.៧ ពាន់លានរៀលក្នុងអំឡុងពេលដូចគ្នានេះ។ប្រសិនជាបានបញ្ចូល នឹងអនុវត្តបានសមរម្យ សំណើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ននឹងផ្លាស់ការផ្តោតការយកចិត្តទុកដាក់ពីការពឹងផ្អែកខ្លាំងក្លាលើកំណើនដែលពឹងផ្អែកលើការនាំចេញទៅជំហរខ្លាំងមួយលើការអនុវត្តជនបទ។ ពីព្រោះភាពក្រីក្រក្នុងប្រទេសកម្ពុជាគឺបាតុភូតជនបទ យើងអាចកាត់បន្ថយភាពក្រីក្របានលឿន។ ស្រដៀងគ្នានេះដែរ គោលនយោបាយផ្តោតលើកសិកម្ម សមិទ្ធផលកសិកម្ម ក៏ដូចជាកសិឧស្សាហកម្ម ត្រូវបានគេសង្ឃឹមថា នឹងផ្តល់នូវកំណើនជាដុំកំភួន អាចលើសពីតម្រូវការ និងបង្កើតការងារនៅក្នុងសេដ្ឋកិច្ច។ កំណើនដែលពឹងផ្អែកលើដីធ្លី ប្រសិនត្រូវបានគាំទ្រដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជំនាញ និងបច្ចេកវិទ្យាសមរម្យអាចទាក់ទាញវិនិយោគ និងគាំទ្រការនាំចេញកសិឧស្សាហកម្ម។

ការផ្លាស់ប្តូរស្រដៀងគ្នានេះនៅក្នុងអាទិភាពគោលនយោបាយ ក៏ឆ្លុះបញ្ចាំងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ ដូចដែលមានភស្តុតាងបញ្ជាក់នៅក្នុងករណីនៃប្រទេសអាស៊ីខាងកើតក្នុងជំហានដំបូងនៃការអភិវឌ្ឍរបស់ពួកគេ។ ការវិនិយោគកសិកម្ម កំណែទម្រង់ដីធ្លី និងការអភិវឌ្ឍន៍ជំនាញនៅក្នុងប្រទេសទាំងនេះធានានូវប្រសិទ្ធភាព និងចំណូលខ្ពស់នៅក្នុងវិស័យ និងអាចលើសពីតំរូវការដែលអាចឈានដល់កំណើនឧស្សាហកម្ម។[19] ប្រទេសកម្ពុជាមានគុណសម្បត្តិក្នុងកំណើនដែលពឹងផ្អែកខ្លាំងលើដីធ្លី និងការនាំចេញ ដែលអាចនាំមកនូវការផ្លាស់ប្តូរតាមលំដាប់វិធីជាច្រើន។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយមួយជាមួយគ្នានឹងការអភិវឌ្ឍន៍ដោយមានប្រសិទ្ធភាពនៃគោលនយោបាយវិសហមជ្ឈការអាចបង្កើតការងារច្រើនជាងក្នុងអំឡុងពេលថ្មីៗនេះ។ ជាមួយនឹងក្របខណ្ឌ នៃទស្សនៈអភិវឌ្ឍន៍ថ្មី យុទ្ធសាស្ត្រជាតិស្តីពីមុខរបរអាចបញ្ចូល និងសំរេចបាននូវបង្កើនការងារនៃកំណើន។

យុទ្ធសាស្ត្រកំណើនដែលបង្កើតការងារផ្តល់សារៈសំខាន់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជាមួយចំនួនដូចជា៖

- ការបង្កើតការងារដែលមានប្រាក់ចំណូលខ្ពស់ និងមានផលិតភាព ភាគច្រើនតាមរយៈវិនិយោគឯកជន មិនត្រឹមតែគាំទ្រការកាត់បន្ថយភាពក្រីក្រដោយនិរន្តរភាពនោះទេ ប៉ុន្តែអាចកាត់បន្ថយឧបសគ្គសារពើពន្ធនៃរដ្ឋាភិបាលដើម្បីគាំទ្រកម្មវិធីសំរាប់ជនក្រីក្រ អ្នកអត់ការងារធ្វើ និងជនងាយរងគ្រោះ។

[19] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម op. cil, តារាងទី ១៤ ទំព័រទី ៥៨

- ការបង្កើតការងារដោយមានផលិតភាពដើម្បីស្រូបយកអ្នកគ្មានការងារធ្វើ ឬមានការងារមិនជាប់លាប់ អាចបង្កើនផលិតភាពការងារ ប្រាក់ចំនូលខ្ពស់ និងភាពចល័តនៃការងារ និង នាំអោយមានការផ្លាស់ប្តូររចនាសម្ព័ន្ធ។
- ការបង្កើតការងារវិស័យផ្លូវការ ទោះបីជាក្នុងសហគ្រាសឯកជន និងសាធារណៈក៏ដោយក៏អាចជានានូវកិច្ចសន្យាការងារដល់កម្មករដែលអាចផ្តល់មូលដ្ឋានមួយដើម្បីបន្តទៅការងារសមរម្យ។

លើសពីនេះទៀត តម្រូវការអោយមាន យុទ្ធសាស្រ្តជាតិស្តីពីមុខរបនិងការងារ និងការបញ្ចូលផែនការ គោលនយោបាយបង្កើតការងារទៅក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គឺអ្វីៗដែលបានបង្ហាញដោយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ដែលពេលនេះដូចដែលបានបង្ហាញខាងលើ ត្រូវបានដាក់ចូលក្នុងការសំរេចបាននូវការងារមានផលិតភាពពេញលេញ និងការងារសមរម្យ ដែលត្រលប់មកវិញអាចធ្វើអោយមានការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរកាល (គោលដៅអភិវឌ្ឍន៍សហសវត្សទី 1)។ យុទ្ធសាស្រ្តជាតិស្តីពីមុខរបរ មួយក៏ជាឧបករណ៍សំខាន់ដើម្បីតាមដាន និងរាយការណ៍ លើការងាររបស់ប្រទេស និងការអនុវត្តទីផ្សារការងារ ដែលបានធានាដោយការប្តេជ្ញាចិត្តចំពោះអនុសញ្ញារបស់ILO លេខ១២២ ដែលរាជរដ្ឋាភិបាលបានផ្តល់សច្ចាប័ន។

## ក្របខណ្ឌមូលដ្ឋានរបស់ យុទ្ធសាស្រ្តជាតិស្តីពីមុខរបរនិងការងារ

វត្ថុបំណងសំខាន់របស់ យុទ្ធសាស្រ្តជាតិស្តីពីមុខរបរនិងការងារ គឺផ្តល់នូវការគាំទ្រដល់អ្នករៀបចំគោលនយោបាយ ដៃគូសង្គម និងភាគីពាក់ព័ន្ធដទៃទៀតក្នុងការបង្កើតនូវក្របខណ្ឌរួមគ្នានៃគោលនយោបាយ និងកម្មវិធីឈានទៅដល់ដំណាក់កាលនៃការងារពេញលេញ ដែលមានការគោរពសិទ្ធនិយោជក និងនិយោជិតពេញលេញ។ ក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ថ្នាក់ជាតិមួយអាចជួយដល់រាជរដ្ឋាភិបាល ដើម្បីដាក់ការងារនៅចំនុចកណ្តាលនៃការធ្វើគោលនយោបាយសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ និងផ្តល់សារជាតុដល់ការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការលើកកម្ពស់គោលបំណងនៃការងារពេញលេញ និងសមភាព នៃការងារតាមរយៈជំរើសសមស្របមួយនៃគោលនយោបាយសង្គម និងសេដ្ឋកិច្ច ក៏ដូចជាតាមរយៈការបង្កើតស្ថាប័នមានប្រសិទ្ធភាព និងក្របខណ្ឌគតិយុត្តចាំបាច់។

ការគូសវាស នូវការប្រឈមរបស់ការងារ ក្នុងន័យបរិមាណ និងគុណភាព តាមរយៈស្តង់ដារ និងការប្រមើមើល (ក្រោមការសន្និដ្ឋានផ្សេងនៃកំណើនសរុប និងតាមវិស័យ និង កំណើនការងារ) អាចផ្តល់មូលដ្ឋានបឋមនៃ ១. វាយតម្លៃថាតើ គោលនយោបាយពេលបច្ចុប្បន្ន តាមវិស័យនិងថ្នាក់ជាតិ អាចសំរេចបានគោលដៅដែលបានកំណត់ក្នុង ការប្រមើមើលបានកំរិតណា និង ២. រៀបចំក្របខណ្ឌគោលនយោបាយបង្កើតការងារដើម្បីសំរេចបាននូវសក្តានុពលបង្កើតការងារនៃកំណើន។ ការប្រមើមើល លើជ្រុងនៃ

តំរូវការអាចទាមទារអោយមានការឆ្លើយតបនឹងការគិតគូរពីជ្រុងនៃការផ្គត់ផ្គង់ ដូចជាភាពមានការងារធ្វើនៃកម្លាំងពលកម្ម នៅក្នុងផែនការការងារដែលបានបង្កើត។

យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ ត្រូវបានគាំទ្រដាងឯកសារគោលនយោបាយសំលឹងទៅខាងមុខ ស្របគ្នានឹងផែនការអភិវឌ្ឍន៍ជាតិ ដែលដាក់ចេញក្នុងឥរិយាបថគ្រប់ជ្រុងជ្រោយ និងពិស្តារ និងគោលបំណងទាក់ទងនឹងការងារសំរាប់រយៈពេលមធ្យម(និយាយចំពោះអំឡុងផែនការ ៥ឆ្នាំ)។ នេះគួរតែត្រូវបានបន្ថែមដោយផែនការ/កម្មវិធីនៃសកម្មភាព ដើម្បីទទួលបានគោលបំណងដែលបានកំណត់ ជាសន្និដ្ឋាន យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារអាចផ្តល់៖

- ការវាយតម្លៃនៃការប្រឈមសំខាន់ៗរបស់ការងារ និងអត្តសញ្ញាណនៃអាទិភាព
- កំណត់ដោយពិស្តារ ជាមួយនឹងក្របខណ្ឌច្បាស់លាស់មួយនៃការផ្តួចផ្តើមគោលនយោបាយ និងវិធានការគ្រឹះដែលអាចទទួលយក(បន្ថែមលើ ឬជំនួសអោយវិធានដែលមានស្រាប់) ដើម្បីដោះស្រាយការប្រឈមជាអាទិភាព
- គំនិតដែលអាចនៃបញ្ហាខាងលើដើម្បីផ្តល់ជាថវិកា និងយន្តការហិរញ្ញវត្ថុ (ជាមួយនឹងការយល់នៃលំដាប់អាទិភាពដោយតម្លៃរបស់ពួកគេ និង (សង្គម) ប្រយោជន៍ពីការវិនិយោគ។[20]

ការរៀបចំ និងការបង្កើតនៃ យុទ្ធសាស្ត្រជាតិស្តីពីមុខរបរ ទាមទារអោយឃើញមាននូវវិធីសាស្ត្ររួម និងស្របជាមួយ និង បញ្ចូលទៅក្នុង ក្របខណ្ឌផែនការជាតិ។ ដោយមិនចាំបាច់បញ្ជាក់ ការបង្កើតការងារអាចត្រូវបានជះឥទ្ធិពលដោយគោលបំណង តាមរយៈគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាគោលនយោបាយវិមជ្ឈការ និងតំបន់។ គុណភាពនៃការងារត្រូវបានត្រួតពិនិត្យជារឿយៗតាមរយៈ ក្របខណ្ឌបទប្បញ្ញត្តិ និងគោលនយោបាយស្ថាប័នដែលសមរម្យ និងគោលនយោបាយសង្គម។ ដូចនេះ យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ ដែលគ្រប់ជ្រុងជ្រោយ និងផែនការសកម្មភាពចំបងទាមទារអោយមានការសិក្សាពិស្តារដើម្បីបញ្ជាក់លទ្ធផលការងារនៃគោលនយោបាយផ្សេងៗគ្នា និងការពិគ្រោះយោបល់ ក្នុងចំណោមក្រសួង និងភ្នាក់ងារផ្សេងគ្នា និងភាគីពាក់ព័ន្ធដទៃទៀត[21] លើគោលនយោបាយចម្បង និងកំណែទម្រង់កម្មវិធី។

ក្នុងផ្នែកខាងក្រោម ការសិក្សាផ្តល់ចំនុចទូលំទូលាយនៃធាតុសំខាន់នៃ យុទ្ធសាស្ត្រជាតិស្តីពីមុខរបរ សំរាប់កម្ពុជា ដូចជាវិធីសាស្ត្រដើម្បីពង្រីកគោលនយោបាយ បញ្ហាប្រឈមការងារ និងគោលនយោបាយផ្សេងទៀតដែលអាចទទួលបាននូវគុណភាព និងបរិមាណនៃការងារ។

## ៣. ភាពប្រឈមការងារ និងសក្តានុពលទីផ្សារការងារ

[20] Cf. Hausmann, Rodrik និង Velasco, <ការទទួលបានសិទ្ធិរោគវិនិច្ឆ័យ>។ *ហិរញ្ញវត្ថុ និងការអភិវឌ្ឍ,* ខែមីនា ឆ្នាំ ២០០៦

[21] វេទិកាអន្តរក្រសួងត្រូវបានបង្កើតឡើង នៅក្នុងប្រទេសជាច្រើនដែលមានបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរ

ការផ្តល់នូវចំនុចសំខាន់នៃគោលនយោបាយបង្កើតការងារ និង ទីផ្សារការងារ នៅក្នុងយុទ្ធសាស្រ្តកំណើនដែលគាំទ្រអ្នកក្រីក្រ វាជាការចាំបាច់ណាស់ដើម្បីស្វែងយល់ និងវាយតម្លៃការប្រឈមការងារ និងទីផ្សារការងារនៃសេដ្ឋកិច្ច។ វាកាន់តែមានសារៈសំខាន់ទៀតក្នុងសេដ្ឋកិច្ចដូចជាប្រទេសកម្ពុជា ដែលកំពុងឈានឆ្ពោះទៅកាន់តួនាទីដែលពឹងផ្អែកលើទីផ្សារការងារ។ គោលនយោបាយការងារ និងគោលនយោបាយទីផ្សារការងារ ដែលមានប្រសិទ្ធភាព អាចត្រូវបានបរិយាយ ប្រសិនបើមូលដ្ឋានដែលផ្អែកលើបទពិសោធន៍ និងការប៉ាន់ប្រមាណ ការប្រឈមការងារ ត្រូវបានបង្កើតដោយសមរម្យ។ នេះជានានូវការបង្កើតប្រព័ន្ធទិន្នន័យ និងការកសាងចំនេះដឹងដែលមានសារៈសំខាន់សំរាប់ការសំរេចចិត្តលើការធ្វើគោលនយោបាយ និងការតាមដានសូចនាករការងារ និងទីផ្សារការងារ ក៏ដូចជាទាមទារអោយមានការស្ទង់មតិនិងការវិភាគទិន្នន័យដូចដែលបានធ្វើនៅក្នុងប្រទេសភាគច្រើនសំរាប់អនុវត្តនៅប្រទេសកម្ពុជា។[22]

## ភាពប្រឈមផ្នែកមុខរបរ

តើការប្រឈមការងារគួរត្រូវដោះស្រាយដោយវិធីណាក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា? តើវាត្រូវបានកំណត់បរិមាណដោយវិធីណា? អវត្តមាននៃទិន្នន័យជាប្រព័ន្ធលើទីផ្សារការងារ និងការងារ គឺវាមានការលំបាក ដែលទាមទារអោយមានការទាញសេចក្តីសន្និដ្ឋាន និងការពឹងផ្អែកលើស្តង់ដាចាស់។ ត្រូវតែមានការទទួលស្គាល់ថាការបង្កើតការងារ មិនមែនជារឿងងាយស្រួលនោះទេ និងត្រូវបង្ហាញតាមរយៈមុខងារនៃសក្តានុពលទីផ្សារការងារ។ នៅក្នុងប្រទេសកម្ពុជា មុខងារនៃសក្តានុពលទីផ្សារការងារមានភាពស្មុគស្មាញដោយសារការចែកជាផ្នែកនៃទីផ្សារការងារ ដែលមានការបាត់បង់ទីផ្សារ និងវិស័យមិនផ្លូវការមានចំនួនច្រើន។[23]

នៅក្នុងសេដ្ឋកិច្ចរីកចំរើន ទីផ្សារការងារ មានការរីកចំរើនខ្លាំង និងមុខងារទីផ្សារការងារមានភាពរលូន ការពិចារណាដំបូងលើគោលនយោបាយនៅក្នុងសេដ្ឋកិច្ចទាំងនេះគឺ ការកាត់បន្ថយនូវភាពអត់ការងារធ្វើ នៅពេលណាដែលអត្រាអត់ការងារធ្វើកើនឡើងដល់ចំនុចដែលមិនអាចទទួលយកបាន។[24] ជាចំនេះដឹង និង សំរាប់ដែនកំណត់នៃការប៉ាន់ប្រមាណភាពអត់ការងារធ្វើភាពអត់ការងារធ្វើក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនមានកំរិតទាប។ នៅក្នុងប្រទេសកម្ពុជាផងដែរ អត្រានៃភាពអត់ការងារធ្វើមានកំរិតទាបយ៉ាងខ្លាំង សូម្បីតែទាបជាងដែលមិនអាចទទួលយកបាន ក្នុងន័យនៃអត្រាអត់ការងារធ្វើ (សូមពិនិត្យមើលរូបភាពទី ៣.១ ខាងក្រោម)។

[22] បច្ចុប្បន្ននេះ NIS ត្រូវបានចាប់អនុវត្តនៅក្នុងការអភិវឌ្ឍទិន្នន័យជាប្រព័ន្ធ ជាពិសេសតាមរយៈការណែនាំឡើងវិញនូវការស្រង់មតិ LF

[23] Cf. Godfrey et al (2001) ចំពោះការឆ្លុះបញ្ចាំងមានប្រយោជន៍ស្តីពីការកំណត់ចរិកលក្ខណៈ និងការប្រព្រឹត្តទៅនៃទីផ្សារការងារនៅកម្ពុជា

[24] នៅអឺរ៉ុប ផ្តោតទៅលើការបង្កើនសមាមាត្រប្រជាជនទៅនឹងមុខរបរ; នៅក្នុងសន្ធិសញ្ញា Lisbon

**រូបភាពទី ៣.១៖ អត្រាអត់ការងារធ្វើ (គិតជាភាគរយ) ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨**




ដូចនេះ យើងកត់សំគាល់ថាអត្រាអត់ការងារធ្វើដែលបានកត់ត្រានៅឆ្នាំ ២០០៨ គឺ ១.៦% ដែលថយចុះពី ៥.៣%ក្នុងឆ្នាំ ១៩៩៨។ នៅក្នុងបរិបទនេះ ការកាត់បន្ថយភាពអត់ការងារធ្វើ ដោយចំហរជាគោលដៅ គោលនយោបាយ/ការអភិវឌ្ឍន៍មួយដែលខុសឆ្គង។ អ្នកវិភាគភាគច្រើនបង្ហាញថាសេដ្ឋកិច្ចមានចំណូលទាបតែងតែមានបញ្ហាជាមួយកម្លាំងពលកម្មលើសតម្រូវការ ដែលជារឿយត្រូវបានចាត់ទុកថាមិនមានការងារគ្រប់គ្រាន់។ នៅក្នុងអវត្តមាននៃ ភាពអត់ការងារធ្វើ និងជានារ៉ាប់រងសង្គម នាំអោយមានការបែងចែកការងារឆ្លុះបញ្ចាំងនូវការងារដែលមានផលិតភាពទាប និងភាពអត់ការងារធ្វើខ្ពស់ ដែលនេះជាពិសេសនៅក្នុងវិស័យកសិកម្ម (និងជនបទជាទូទៅ) និងនៅក្នុងសេដ្ឋកិច្ចមិនផ្លូវការភាគច្រើន។ រូបភាពខាងលើពន្យល់ពីភាពខុសគ្នានូវភាពអត់ការងារធ្វើដែលបានកត់ត្រាជាផ្លូវការ(១.៦%)និងវិសាលភាពនៃភាពក្រីក្រ(៣០%) នៅក្នុងសេដ្ឋកិច្ច។ សូមកត់សំគាល់ថា ភាពមិនទាក់ទងនឹងការប៉ាន់ស្មានកំរិតអត់ការងារធ្វើ តែងតែមានការធ្លាក់ចុះដែលអាចកត់សំគាល់បាន នៅក្នុងកំរិតដែលបានស្មាន ជាពិសេសភាពអត់ការងាររបស់យុវវ័យ។ យើងត្រូវសង្កេតផងដែរថា ទោះបីជាមានការធ្លាក់ចុះយ៉ាងលឿននូវភាពអត់ការងារធ្វើ ក៏អត្រាអត់ការងារធ្វើរបស់យុវជននៅតែចាត់ទុកថាមានសមាមាត្រយ៉ាងខ្ពស់ ធៀបនឹងកម្លាំងពលកម្មដែលអត់មានការងារសរុប។[25]

ប្រសិនបើរដ្ឋាភិបាលនៅតែផ្តោតលើការសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី ១.ខ នៃការងារពេញលេញ និងការងារសមរម្យ ការប្រឈមការងារអាចត្រូវបានកើតឡើងខុសៗគ្នា។ នៅក្នុង

[25] មើល NIS (2010)

អវត្តមាននៃសូចនាករមួយ សូចនាករចំរុះអាចត្រូវបានប្រើប្រាស់ដើម្បីតាមដានការអនុវត្តការងារ។ នៅក្នុងបរិបទនេះ ដំណើរការគោលដៅអភិវឌ្ឍន៍សហសវត្សទី១.ខ អាចត្រូវបានតាមដាននៅក្នុងសូចនាករទាំងបួនដែលបានស្នើរឡើងដោយUN។ យើងត្រូវកត់ចំនាំថា គ្មានចំនុចកំណត់ដែលបានយល់ស្របណាមួយនៃគោលដៅ ដែលត្រូវតែទទួលបាននោះទេ តែមានដំណើរការជាក់ស្តែងក្នុងគោលដៅនីមួយៗ។ ដូចនេះសូមក្រលេកមើលស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជាលើសូចនាករទាំងនេះ។

១.*សមាមាត្រប្រជាជនទៅនឹងការងារ (EPR)៖* ជាវិធានដែលប្រើដើម្បីចង្អុលបង្ហាញ សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ ហើយមានការងារធ្វើ។ សំរាប់ករណីប្រទេសកម្ពុជា រូបភាពទី៣.២ ផ្តល់សមាមាត្រ មិនបូកសរុបនូវភេទ ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨។[26]

**រូបភាពទី ៣.២៖ សមាមាត្រប្រជាជនទៅនឹងការងារតាមពលករដែលមានអាយុចាប់ពី ១៥ ឡើងទៅ (គិតជាភាគរយ)**




ដូចដែលរូប ៣.២ បង្ហាញ EPR ទាំងមូលកើនឡើងពី ៧៣% ទៅ ៧៧% ក្នុងអំឡុងពេលដែលបានកំណត់។ ខណៈពេលដែលគម្លាតយេនឌ័រ បានធ្លាក់ចុះEPR របស់ស្ត្រីនៅតែទាបជាងបុរស។ ទោះបីជាយ៉ាងណាក៏ដោយ តម្លៃ EPR បង្ហាញកំរិតខ្ពស់ល្មមនៃការអនុវត្តការងារ ជាមួយនឹងអត្រាកំណើនការងារជិត ៣.៦% ក្នុងទសវត្ស ដែលខ្ពស់ជាង កំណើនកម្លាំងពលកម្មដែលមាន ៣.៣%។ និន្នាការនេះចង្អុលបង្ហាញនូវការធ្លាក់ចុះនូវភាពអត់ការងារធ្វើដូចដែលយើងសង្កេតខាងលើ។ ឧបសគ្គចំបងនៃសូចនាករនេះ គឺថាខណៈពេលដែលការងារបានកើនឡើង យើងមិនច្បាស់ថាតើវាមានផលិតភាព និងមានប្រាក់ចំណូលខ្ពស់កំរិតណា និងតើវាទាក់ទងដល់ការកាត់បន្ថយភាពក្រីក្រ និង/ឬភាពងាយរងគ្រោះនៃកម្លាំងពលកម្មដោយវិធីណា។

[26] មើល NIS (2010) សម្រាប់ព័ត៌មានលម្អិតបន្ថែម

២.*ប្រជាជនងាយរងគ្រោះ៖* ILO អោយនិយមន័យប្រជាជនងាយរងគ្រោះថាអ្នកដែលធ្វើការក្នុងគ្រួសារដែលមិនទទួលបានប្រាក់កំរៃ និងពលករដែលពឹងផ្អែកលើខ្លួនឯង។ សំរាប់ប្រទេសកម្ពុជា ជនងាយរងគ្រោះមានដល់ទៅ ៨២.៥% ដែលធ្លាក់ចុះពី ៨៦.៨% នៅក្នុងឆ្នាំ ១៩៩៨( សូមមើលរូបភាពទី ៣.៣ )។

**រូបភាពទី ៣.៣៖ ស្ថានភាពមុខរបរ ( គិតជាភាគរយតាមអាយុ ) ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨**




*ប្រភព៖ NIS (2010), តារាងទី ១៨។ មុខរបរងាយរងគ្រោះ = "កម្មករដែលពឹងផ្អែកលើខ្លួនឯង" + "កម្មករជួយការងារគ្រួសារដែលមិនបានទទួលកម្រៃ"*

ការធ្លាក់ចុះនេះគឺដោយសារការធ្លាក់ចុះ នូវកម្មករដែលពឹងផ្អែកលើខ្លួនឯង ខណៈពេលដែលការរួមចំនែករបស់កម្មករជួយគ្រួសារដោយមិនទទួលប្រាក់កំរៃ បានកើនឡើង២% តែចំនួនស្ត្រីក្នុងការងារប្រភេទនេះធ្លាក់ចុះទោះបីជាក្នុងកំរិតទាប។

ដូចនេះ ខណៈពេលដែលប្រជាជនងាយរងគ្រោះមានតួលេខច្បាស់លាស់ យើងអាចសង្កេតឃើញថា វាមានចំនួនច្រើនទោះបីជាមាន EPR ខ្ពស់ក៏ដោយ។ ភាពងាយរងគ្រោះអាចមានទម្រង់ផ្សេងគ្នា៖ ប្រាក់ចំណូលតិច ឱកាសការងារទាប លទ្ធភាពក្នុងការទទួលបានប្រាក់កម្ចី ក៏ដូចជាអសន្តិសុខខ្ពស់ និងកង្វះនូវកិច្ចគាំពារសង្គមជាប្រព័ន្ធ ឬសំណាញ់សុវត្ថិភាពសង្គម។ សូចនាករដែលសក្តិសមបំផុតគឺការស្វែងរកចំណូល និងនិន្នាការរបស់ពួកគេ ដែលរូបភាពត្រូវបានបង្ហាញក្នុងរូបភាពទី ៣.៤។

## រូបភាពទី ៣.៤៖ ការទទួលបានចំណូលប្រចាំថ្ងៃជាមធ្យមពិតប្រាកដរបស់កម្មករងាយរងគ្រោះ (ខែវិច្ឆិកា ឆ្នាំ ២០០០ = ១០០) ក្នុងអំឡុងឆ្នាំ ២០០៤-២០១០




*ប្រភព៖ ទិន្នន័យចាប់ពីខែសីហា ឆ្នាំ ២០០៩ បានពី CDR វ៉ុល ១៤, ចេញលើកទី ២ សម្រាប់ខែមេសា ដល់ ខែមិថុនា ឆ្នាំ ២០១០; ទិន្នន័យមុនរយៈពេលនេះបានពី CDR វ៉ុល ១៣ ចេញលើកទី ៤ សម្រាប់ខែតុលា ដល់ ខែវិច្ឆិកា ឆ្នាំ ២០០៩*

ដូចដែលបានបង្ហាញក្នុងរូបភាពខាងលើ ទិន្នន័យការស្ទង់មតិបង្ហាញថាប្រាក់ចំណូលមធ្យមពិតប្រាកដ នៃក្រុមកម្មករងាយរងគ្រោះ(លើកលែងនៅក្នុងការងារសាងសង់) ធ្លាក់ចុះជាប្រចាំចាប់តាំងពីឆ្នាំ ២០០៨ បន្ទាប់ពីមានការកើនឡើងពី ឆ្នាំ ២០០៤ ដល់ ២០០៧។ ប្រាក់ចំណូលពិតប្រាកដបានធ្លាក់ចុះជាលំដាប់ ដែលនាំអោយមានការកើនឡើងក្នុង CPI។

៣.*ជនក្រីក្រដែលប្រកបការងារ៖* មានបញ្ហាលំបាកក្នុងទិន្នន័យ ក្នុងការប៉ាន់ប្រមាណជនក្រីក្រដែលប្រកបការងារ នៅក្នុងប្រទេសកម្ពុជា។ ជនក្រីក្រដែលប្រកបការងារ គឺជាសមាមាត្រដ៏សំខាន់នៃប្រជាជនដែលបំរើការងារ ហើយធ្វើម៉ោងការងារធម្មតា(ឬលើសម៉ោងការងារធម្មតា) ក្នុងមួយថ្ងៃ ប៉ុន្តែមិនអាចរកប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីឆ្លងផុតពី ខ្សែបន្ទាត់ក្រីក្រ។ ទាមទារអោយមាន កម្លាំងពលកម្មសមរម្យ និងការស្ទង់មតិប្រាក់ចំណូលគ្រួសារ និងការចំណាយគ្រួសារ ដើម្បីដឹងពីចំនួនជនក្រីក្រដែលប្រកបការងារ។[27] ផ្អែកទៅលើទិន្នន័យស្ទង់មតិ[28]ដែលមានស្រាប់មួយចំនួន សូចនាករមួយចំនួនអាចត្រូវបានប្រមូលអំពីជនក្រីក្រដែលប្រកបការងារ នៅក្នុងប្រទេសកម្ពុជា។ (សូមពិនិត្យមើលរូបភាពទី ៣.៥)។

[27] មើល N. Majid (2001) សម្រាប់ព័ត៌មានបន្ថែមពីនីតិវិធី និងការប៉ាន់ប្រមាណឆ្លងប្រទេសអំពីជនក្រីក្រដែលប្រកបការងារ

[28] មើល SES 2004 ឆ្នាំ ២០០៩

**រូបភាពទី ៣.៥៖ ជនក្រីក្រដែលប្រកបការងារ (1.25$ ក្នុងមួយថ្ងៃ) តាមស្ថានភាពការអប់រំ និងមុខរបរ ឆ្នាំ ២០០៤ (គិតជាភាគរយ)**




*ប្រភព៖ EMP/TRENDS (ទិន្នន័យដែលមិនបានផ្សព្វផ្សាយ)*

រូបភាពបង្ហាញការប៉ាន់ប្រមាណមួយចំនួននៃជនក្រីក្រដែលប្រកបការងារ ( ១.២៥ ដុល្លារក្នុង ១ ថ្ងៃ) ដែលដាច់ដោយឡែកពី ស្ថានភាពការអប់រំ និងមុខរបរ។ នៅក្នុងន័យស្ថានភាពការអប់រំ ជាភស្តុតាង អ្នកដែលមានចំនេះដឹងទាបជាងបឋមសិក្សា មានអត្រាខ្ពស់(៤១%)។ ក្នុងចំណោមប្រភេទការងារផ្សេងៗគ្នា ពលករពឹងផ្អែកលើខ្លួនឯង (៣៦%) និងអ្នកជួយកិច្ចការគ្រួសារដែលមិនបានទទួលប្រាក់កំរៃ (៤១.៤%) ដែលជាចំនួនច្រើនបំផុតនៃជនក្រីក្រដែលប្រកបការងារ។ ប្រភេទពលករដែលទទួលបានប្រាក់កំរៃក៏បង្ហាញនូវសមាមាត្រខ្ពស់នៃ ជនក្រីក្រមានការងារផងដែរ (៣៤%)។ ដូចនេះខណៈពេលដែលនិយមន័យទូទៅ (ILO) នៃប្រជាជនងាយរងគ្រោះ មានចំនួន ៨២% ដែលច្រើនជាងពាក់កណ្ដាលនៃប្រជាជនទាំងអស់អាចត្រូវបានចាត់ទុកថាជាជនក្រីក្រដែលប្រកបការងារ។ ដោយសារកង្វះនៃទិន្នន័យ និងប្រភេទច្បាស់លាស់ គឺអាចមានភាពខុសគ្នាបន្តិចបន្តួចក្នុងការប៉ាន់ប្រមាណភាពក្រីក្រ ជនក្រីក្រដែលប្រកបការងារ និងប្រជាជនងាយរងគ្រោះ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានភាពមន្ទិលណាមួយដែលថាការងារមិនទៀតទាត់ និង/ឬ ខ្វះផលិតភាព និងមានប្រាក់ចំណូលទាប នៅមានកំរិតខ្ពស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា។

***៤.ផលិតភាពការងារ៖*** ការប្រើប្រាស់កម្លាំងពលកម្មមិនបានពេញលេញ និងការងារដែលមានប្រាក់ចំណូលទាបនាំអោយមានផលិតភាពទាបនៅក្នុងសេដ្ឋកិច្ច។ នៅក្នុងករណីកម្ពុជា ក្នុងអំឡុងពេលថ្មីៗពី ១៩៩៨-២០០៨ បានបង្ហាញនូវអត្រាកំណើនគួរអោយចាប់អារម្មណ៍ នៅក្នុងវិស័យភាគច្រើននៃសេដ្ឋកិច្ច។ ផលិតភាពការងារ (គិតជាដុល្លារ) បានកើនឡើងប្រហែល ៥%ជាសរុប (កំនត់ចំណាំ៖

ការងារបានកើនឡើង ៣.៦% ក្នុងអំឡុងពេលដូចគ្នានេះ)។[29] ផលិតភាពការងារមិនមានភាពស្មើគ្នា នៅតាមវិស័យនោះទេ។ (សូមពិនិត្យមើលតារាងទី ៣.១)។

**តារាងទី ៣.១៖ អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃតម្លៃបន្ថែមពិតក្នុងពលករមួយនាក់ (គិតជារៀល) ក្នុងអំឡុងឆ្នាំ ១៩៩៤-២០០៨**

| | 1994-1997 | 1998-2004 | 2005-2008 | Period average 1994-2008 |
|---|---|---|---|---|
| សរុប | **1.8** | **1.6** | **6.9** | **2.9** |
| កសិកម្ម | -2.2 | -0.9 | 3.9 | 0.6 |
| ការផលិត | 16.1 | -8.0 | 11.3 | 2.8 |
| រ៉ែ | 0.0 | 6.5 | 10.5 | 7.2 |
| ផ្សេងៗ | 8.9 | -3.4 | 5.2 | 0.9 |

*ប្រភព៖ គណនាដោយធនាគារពិភពលោក ទិន្នន័យសេដ្ឋកិច្ចកម្ពុជា*

ផលិតភាពរយៈពេលវែងក្នុងកសិកម្ម (១៩៩៤-២០០៨) មានត្រឹមតែ ០.៦ ទោះបីជាមានការកើនឡើង ៣.៩ នៅក្នុងឆ្នាំ ២០០៥-០៨ ក៏ដោយ។ វិស័យនេះដែលស្រូបយកច្រើនជាង ២/៣ នៃកម្លាំងការងារ ទាមទារអោយមានការរក្សាផលិតភាពការងារខ្ពស់ ដើម្បីលើកកំពស់ចំណូល និងជីវភាពរស់នៅ និងកាត់បន្ថយជនក្រីក្រដែលប្រកបការងារ។ នេះកាន់តែមានសារៈសំខាន់ដើម្បីជានាការផ្លាស់ប្តូរតាមលំដាប់នៅក្នុងសេដ្ឋកិច្ច តាមរយៈការកើនឡើង នូវផលលើសតម្រូវការនៅក្នុងវិស័យកសិកម្ម។ យើងឃើញមានការកើនឡើងជាបណ្តើរៗនូវប្រាក់កំរៃការងារ ការកើនឡើងប្រាក់កំរៃក្នុងវិស័យកសិកម្ម និងផ្លាស់ប្តូរកម្លាំងពលកម្មពីវិស័យផលិតភាពទាប ទៅផលិតភាពខ្ពស់។[30] ទម្រង់កំណើននៅថ្ងៃអនាគត ជាពិសេស បន្ទាប់ពីវិបត្តិ នឹងទាមទារអោយអនុវត្តការអភិវឌ្ឍន៍ទាំងនេះតាមរយៈកំណើនដែលបង្កើនការងារ និងសំរេចបានផលិតភាពនៅក្នុងសេដ្ឋកិច្ច។

ភាពប្រឈមការងារនៅក្នុងប្រទេសកម្ពុជា ដូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន នឹងមានភាពមិនច្បាស់លាស់នៅក្នុងពេលអនាគត ជាពិសេស ពេលកាត់បន្ថយភាពអត់ការងារធ្វើ (ដែលមានអត្រាទាប១.៦%) ឬក៏បង្កើនសមាមាត្រប្រជាជនដែលមានការងារធ្វើ (មានអត្រាខ្ពស់ប្រហែលជា ៨០%) ដែលនាំអោយមានភាពប្រឈមគោលនយោបាយ។

*ទាក់ទងនឹងសូចនាករទាំង៤ នៃគោលដៅអភិវឌ្ឍន៍សហសវត្ស (គោលដៅទី ១.ខ) នៃការសំរេចបាននូវ "ការងារមានផលិតភាពពេញលេញ និងការងារសមរម្យ" គឺគ្មានគោលដៅកំណត់ក្នុងការសំរេច*

[29] មើល NIS (2010) សម្រាប់ព័ត៌មានលម្អិតបន្ថែម, op.cit.

[30] មើល Godfrey et al. (2001)

*បាននោះទេ ដែលយើងអាចតាមដានដំណើរការនៃសូចនាករនីមួយៗ។* លើសពីនេះទៅទៀត ដំហានទៅកាន់ការងារដែលមានផលិតភាពពេញលេញ គឺមានទំនាក់ទំនងទៅនឹងកំណើននៃការងារដែល មានប្រាក់កំរៃ និង/ឬ ការងារវិស័យផ្លូវការនៅក្នុងសេដ្ឋកិច្ច មិនថាការងារដែលទទួលប្រាក់កំរៃក្នុងវិស័យ កសិកម្ម និងវិស័យជនបទ វិស័យឧស្សាហកម្មទំនើប ឬវិស័យសាធារណៈនោះទេ។ ដូចបទពិសោធន៍ជា ប្រវត្តិសាស្រ្ត បានបង្ហាញថាកំណើនការងារវិស័យផ្លូវការ គឺជាភាពប្រឈមដែលទាក់ទងទៅ នឹងការផ្លាស់ប្តូរតាមលំដាប់នៅក្នុងសេដ្ឋកិច្ច និងការផ្លាស់ប្តូរការងារពីវិស័យមានផលិតភាពទាបទៅវិស័យដែលមានផលិតភាពខ្ពស់។ ការផ្លាស់ប្តូរផលិតភាពការងារនេះជានាំនូវការតាមដានកំណើនការងារ ហើយមានភាពបត់បែនការងារក្នុងវិស័យផ្សេងៗ អោយបានពិស្តារដូចដែលអាចធ្វើទៅបាន ដែលនេះទាមទារអោយមានការបង្កើតនូវការស្ទង់មតិកម្លាំងការងារជាទៀតទាត់ និងប្រព័ន្ធទិន្នន័យដែលពាក់ព័ន្ធ។

អវត្តមាននៃប្រព័ន្ធទិន្នន័យត្រឹមត្រូវមួយ និងក្របខណ្ឌតាមដានការងារ ការប្រឈមនៅក្នុងប្រទេសកម្ពុជាគឺការបង្កើតការងារបន្ថែមសំរាប់កម្លាំងពលកម្មដែលអត់ការងារ (១.៦%) និងកំណើនកម្លាំងការងារបន្ថែម (៣.៣%)។ កំណើនការងារ ៣.៧% ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨ ( NIS ២០១០) អាចគ្រប់គ្រាន់ដើម្បីដោះស្រាយជាមួយកំនើនកម្លាំងការងារ។ យើងត្រូវកត់ចំណាំថានេះអាចធ្វើទៅបានពេលដែលកំណើន ផលិតផលក្នុងស្រុកសរុបជិត ៩%។ ពេលបច្ចុប្បន្ននេះ ផលិតផលក្នុងស្រុកសរុបកើនឡើងក្នុងកំរិត ៦%ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (រួមបញ្ចូលអត្រាភាពបត់បែននៃការងារ និងកម្លាំងពលកម្ម) ដែលកំណើនការងារប្រហែលជា ២.២% ដែលទាបជាងអត្រាកំណើនកម្លាំងពលកម្ម។ លើសពីនេះទៀត ដូចដែលយើងបានដឹង ការងារភាគច្រើន គឺមិនមានផលិតភាពសមរម្យ និងប្រាក់កំរៃទាប ដែលនាំអោយមានសមាមាត្រខ្ពស់នៃ អ្នកក្រីក្រដែលកំពុងប្រកបការងារ (ពិនិត្យមើលខាងលើ)។ ភាពប្រឈមការងារ ទាមទារអោយមានការបញ្ចូល ការបង្កើតការងារដែលមានផលិតភាពសំរាប់កម្លាំងពលកម្មប្រភេទនេះ។

## សក្តានុពលទីផ្សារការងារ

ការប្រឈមការងារមិនអាចឃើញតាមរយៈ ចំនួនសរុប និងគោលដៅបន្ទាប់បន្សំនោះទេ។ ការបង្កើតការងារ(យុទ្ធសាស្រ្តការងារ) អាចត្រូវបានរកឃើញអំពីការស្វែងយល់នូវសក្តានុពលទីផ្សារការងារ។ និន្នាការ និងការផ្លាស់ប្តូរ ក្នុងការអនុវត្តការងារអាចលេចចេញតាមវិធីសាស្រ្តជាច្រើន ជាពិសេស អាចយោងទៅលើស្ថានភាពនៃក្រុមមុខរបរដាច់ដោយឡែកផ្សេងៗ បរិមាណ និងគុណភាព នៃការងារដែលក្រុមទាំងនោះមាន។ ការណ៍នេះអាចត្រូវបានឆ្លុះបញ្ចាំងតាមរយៈ ប្រាក់ឈ្នួល និងចំណូលផ្សេងៗ កំរិតជំនាញ និងការអប់រំ ភាពចល័ត(ជាលក្ខណៈបុគ្គល និងវិស័យ) ធម្មជាតិនៃការរើសអើង សុវត្ថិភាពប្រាក់ចំណូល/ការងារ និង កង្វះការងារសមរម្យផ្សេងៗដែលក្រុមនីមួយៗអាចជួបប្រទះ។

នៅក្នុងប្រទេសកម្ពុជា មានរបាយការណ៍ និងការសិក្សាជាច្រើន ដែលផ្តល់ការឆ្លុះបញ្ចាំងលើទស្សនៈជាច្រើននៃសក្តានុពលទីផ្សារការងារ។[31] អវត្តមាននៃទិន្នន័យស្តង់មតិជាប្រចាំ ដូចជាការស្ទង់មតិកម្លាំងពលកម្ម វាមានការលំបាកចំពោះការសង្កេត និងនិន្នាការច្បាស់លាស់។[32] សក្តានុពលទីផ្សារការងារវិជ្ជមាន អាចសង្កេតឃើញក្នុងលក្ខខណ្ឌនៃការផ្លាស់ប្តូរវិជ្ជមានដែលកើតមានក្នុងទីផ្សារការងារ។ សូចនាករខ្លះនៅក្នុងដំហានដំបូងនៃការអភិវឌ្ឍន៍ប្រទេស ជាឧទាហរណ៍ គឺការពង្រីកកំណើនការងារក្នុងវិស័យផ្លូវការ ការបែងចែកប្រាក់កំរៃក្នុងវិស័យកសិកម្ម ផលិតភាពពលកម្មក្នុងវិស័យផ្សេងៗជាពិសេសក្នុងចំណោមអ្នកមានមុខរបរខ្លួនឯងក្នុងវិស័យកសិកម្ម និងវិស័យមិនផ្លូវការ ការផ្លាស់ប្តូរប្រាក់កំរៃ និងការកេប្រាក់ចំណូល និងឥទ្ធិពលក្នុងការចល័តនៃការងារតាមវិស័យ ការអភិវឌ្ឍជំនាញ ការផ្លាស់ប្តូរជាវិជ្ជមានក្នុងលក្ខខណ្ឌការងារ។ យើងត្រូវកត់សំគាល់ថាសក្តានុពលនៃទីផ្សារការងារទាំងនេះ ទាក់ទងទៅនឹងទម្រង់នៃកំណើន និងការផ្លាស់ប្តូរតាមលំដាប់ក្នុងសេដ្ឋកិច្ច។

ដូចបានបង្ហាញខាងលើ ការយល់ដឹងសមស្របមួយនូវសក្តានុពលទីផ្សារការងារ គឺមានសារៈសំខាន់សំរាប់ការបង្កើតយុទ្ធសាស្រ្ត និងគោលនយោបាយទីផ្សារការងារ។ ការសិក្សាមួយចំនួនផ្តល់ការយល់ដឹងខ្លះនៃសក្តានុពលទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា។

ជាឧទាហរណ៍ការផ្តោតការយកចិត្តទុកដាក់ និងការពិនិត្យបន្ថែម៖

- កំណើនការងារក្នុងវិស័យផ្លូវការគឺគួរអោយចាប់អារម្មណ៍ក្នុងអំឡុង ១៩៩៨-២០០៧ ប៉ុន្តែយើងត្រូវកត់ចំនាំថាកំណើននេះត្រូវបានកត់ត្រាចាប់ពី មូលដ្ឋានតូចបំផុត និងមួយភាគក្នុងវិស័យកាត់ដេរ សំណង់ សណ្ឋាគារ និងវិស័យទេសចរណ៍។ ការងារក្នុងវិស័យទាំងនេះបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយវិបត្តិសេដ្ឋកិច្ចពិភពលោក ហើយវិស័យសាធារណៈ មិនផ្តល់ក្តីសង្ឃឹមច្រើនសំរាប់ការងារក្នុងអនាគតភ្លាមៗនោះទេ។ កំណើនការងារក្នុងវិស័យផ្លូវការ ដែលមានសារៈសំខាន់ចំពោះការផ្លាស់ប្តូរទីផ្សារការងារ ទាមទារអោយមានការបើកទូលាយថែមទៀត។
- ប្រាក់កំរៃការងារក្នុងវិស័យកសិកម្មនូវតែមានកំរិតទាប។ កំណើននៃផលិតភាពកសិកម្ម ដែលសមហេតុផល(៣.៩%) ក្នុងឆ្នាំ២០០៥-០៨ ទាមទារអោយនិរន្តន៍ភាព/ការកើនឡើង និងសកម្មភាពពាណិជ្ជកម្មខ្លាំងក្លាឡើង និងឧស្សាហូបនីយកម្មជនបទពាក់ព័ន្ធនឹងកសិឧស្សាហកម្ម គឺមានសារៈសំខាន់ណាស់ក្នុងការបង្កើនប្រាក់កំរៃការងារក្នុងវិស័យកសិកម្មជាពិសេស និងតំបន់ជនបទជាទូទៅ
- ការផ្លាស់ប្តូរជាវិជ្ជមានក្នុងការទទួលបានប្រាក់កំរៃ និង ប្រាក់ចំណូលពិតប្រាកដ ជារឿយៗបង្ហាញការកើនឡើងនៃតំរូវការកម្លាំងពលកម្ម និងជំរុញអោយមានភាពចល័តនៃការងារ ទោះបីជាអោយមានការលុបបំបាត់នូវកង្វះជំនាញក៏ដោយ។ នេះឆ្លុះបញ្ចាំងសញ្ញាមួយនៃការផ្លាស់ប្តូរតាមលំដាប់

[31] មើល Morris (2005); NIS (2010); Godfrey et al (2001); EIC (2007) សម្រាប់ទស្សនវិស័យផ្សេងៗទៅលើសក្តានុពលការងារ។

[32] ដូចជាប្រាក់ឈ្នួល និងចលភាពនៃការងារ; Cf. Godfrey et al (2001)

ក្នុងទីផ្សារការងារ និងសេដ្ឋកិច្ច។ នៅក្នុងប្រទេសកម្ពុជា ខណៈពេលដែលការផ្លាស់ប្តូរជាវិជ្ជមានខ្លះអាចជឿជាក់បាន ( Godfrey២០០១) វាឆាប់រហ័សពេកក្នុងការសន្និដ្ឋានថាការផ្លាស់ប្តូរតាមលំដាប់នេះ កំពុងមានដំណើរការ ជាពិសេសការផ្លាស់ប្តូរការងារចេញពីវិស័យមានផលិតភាពទាប។ ដូចដែលយើងបានសំគាល់ពីមុខមក ប្រាក់កំរៃ និងប្រាក់ខែ (លើកលែងចំពោះកម្មករសំណង់) កើនឡើងរហូតដល់ឆ្នាំ ២០០៨ ហើយបន្ទាប់មកធ្លាក់ចុះយ៉ាងខ្លាំង។

- ការចល័តរបស់បុគ្គលក្នុងការងារជារឿយៗ ដោយសារកត្តាជំរុញ ដែលខុសគ្នាពីការចល័តដោយកត្តាទាក់ទាញ។ នៅក្នុងប្រទេសកម្ពុជា មានចំណាកស្រុកក្នុងប្រទេសច្រើន ជាមួយនឹងការផ្លាស់ប្តូរការងារទៅកាន់តំបន់រុងរឿងជាង និងទៅតំបន់ទីប្រជុំជន ដើម្បីរកការងារ និងប្រាក់ចំណូលប្រសើរជាង។[33] ក្នុងករណីជាច្រើន ពួកគេធ្លាក់ខ្លួនក្នុងសេដ្ឋកិច្ចមិនផ្លូវការ ឬក៏បន្ថែមទៅលើទម្រង់មិនផ្លូវការ នៃការប្រើប្រាស់កម្លាំងពលកម្ម។ ចំណាកស្រុកទៅក្រៅប្រទេសបានកើនឡើង ក៏ដូចជាប្រាក់បញ្ញើរពីពលករទេសន្តប្រវេសន៍(សូមពិនិត្យមើលរូបភាពទី ៣.៦)។ ទោះបីជាយ៉ាងណាក៏ដោយ ចំណាកស្រុកទៅក្រៅប្រទេស នៅមានកំរិតទាបបើប្រៀបធៀបទៅប្រទេសជិតខាងដែលនាំចេញកម្លាំងពលកម្ម នៅក្នុងតំបន់។[34]

**រូបភាពទី ៣.៦៖ ប្រាក់បញ្ញើរបស់ពលករទេសន្តប្រវេសន៍ ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨**




*ប្រភព៖ WDI*

- មានក្រុមជាក់លាក់មួយចំនួន ក្នុងទីផ្សារការងារដែលតែងតែជួបប្រទះជាមួយនឹងឧបសគ្គច្រើននៅក្នុងការងារ ឧទាហរណ៍ ស្ត្រី និងយុវជន។ ខណៈពេលដែល EPR របស់ស្ត្រី ដូចដែលបានធ្វើការ

---

[33] មើល CDRI (2007) ជាពិសេសពាក់ព័ន្ធនឹងគំរូ និងផលវិបាកនៃទេសន្តប្រវេសន៍យុវជនខាងក្នុងប្រទេស។

[34] មើល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ/អង្គការពលកម្មពិភពលោក (2010)

អង្កេតពីមុន ពួកគាត់គ្របដណ្តប់ការងារដែលមានប្រាក់កំរៃទាបនៅក្នុងសង្វាក់ការងារ។[35] ភាពអត់ការងារធ្វើរបស់យុវជន គឺនៅមានកំរិតខ្ពស់ ហើយចំនែក យុវជនដែលអត់មានការងារធ្វើ ទោះបីជាកំពុងធ្លាក់ចុះ ក៏នៅតែមានជាង ៥០ % នៅក្នុងឆ្នាំ ២០០៨ ដែរ( សូមពិនិត្យមើលតារាងទី ៣.២ )

**តារាងទី ៣.២៖ ចំណែកយុវជនដែលគ្មានការងារធ្វើនៅក្នុងភាពគ្មានការងារសរុប ( គិតជាភាគរយ)**

| អាយុពី 15-24 | 1998 | 2000 | 2001 | 2004 | 2008 |
|---|---|---|---|---|---|
| ទាំងពីរភេទ | **58.3** | **60.8** | **59.6** | **58.6** | **52.3** |
| បុរស | 62.4 | 69.5 | 73.1 | 66.7 | 57.8 |
| ស្ត្រី | 55.2 | 54.6 | 51.0 | 50.8 | 47.9 |

*ប្រភព៖ NIS (២០១០)*

- ការអភិវឌ្ឍន៍ទីផ្សារការងារជាវិជ្ជមាន អាចមានទំនាក់ទំនងជាមួយ មិនត្រឹមតែជាការរកប្រាក់ចំណូលអោយបានច្រើនប៉ុណ្ណោះទេ ប៉ុន្តែជាលក្ខខណ្ឌការងារល្អប្រសើរ និងការងារប្រកបដោយគុណភាពផងដែរ។ កំណើនការងារក្នុងវិស័យផ្លូវការ ជាពិសេស ការរឹតបន្តឹងទីផ្សារការងារ អាចដើរតួនាទីជាបុរេលក្ខខណ្ឌដើម្បីលើកកំពស់ និងតួនាទីក្នុងការចរចាររបស់កម្មករនិយោជិត ជាពិសេស ទាក់ទងស្តង់ដារការងារស្នូល និងសន្តិសុខការងារ/ប្រាក់ចំណូល។ នាពេលកន្លងមក ការផ្តល់សេវាគាំពារសង្គមនៅប្រទេសកម្ពុជា នៅមានកំរិតនៅឡើយ ទោះបីជានៅក្នុងវិស័យឯកជនផ្លូវការក៏ដោយ ការផ្តល់អោយមានតែនៅក្នុងវិស័យខ្លះក្នុងការងារវិស័យសាធារណៈ និងឯកជនមួយចំនួនប៉ុណ្ណោះ។[35]

# ៤. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងមុខរបរ

គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច មានតួនាទីយ៉ាងសំខាន់ក្នុងការជជែកវែកញែក ជាពិសេសក្នុងអំឡុងទសវត្សន៍ឆ្នាំ ១៩៨០ និង ១៩៩០ ពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ដែលនៅក្រោមលក្ខខណ្ឌកម្ចីនៃវិទ្យាស្ថានប្រេតតុនវូត (Bretton Woods) ត្រូវបានជំរុញឲ្យអនុវត្តវិធានច្បាស់លាស់ ដើម្បីអោយមានស្ថេរភាព និងសេរីភាព ដែលជាចំនុចកណ្តាលក្នុងការបង្កើតក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។[36] គោលគំនិតនៃគោលនយោបាយដែលត្រូវបានបង្កើតមាន តួនាទីយ៉ាងសំខាន់មួយគត់

[34] NIS/ILO (2001)

[35] ករណីគោលការណ៍នៅពីក្រោយកំណែទម្រង់ទាំងនេះ សូមមើល របាយការណ៍អភិវឌ្ឍន៍ពិភពលោក ឆ្នាំ ១៩៩១ និងមើល Williamson (1997)

នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺការរក្សាស្ថេរភាពតម្លៃ (វាក្យស័ព្ទថ្មីហៅថា "ការផ្តោតសំខាន់លើអតិផរណា") និងជាឧបករណ៍សំខាន់ ក្នុងការសំរេចបាននូវគោលបំណងនេះគឺ គោលនយោបាយអត្រាការប្រាក់។[37] ដើម្បីអោយតម្លៃមានភាពត្រឹមត្រូវ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដែលស្ថិតក្រោមឥទ្ធិពលនៃ Washington Consensus ត្រូវបានជំរុញអោយរក្សាវិធានសារពើពន្ធ និងគណនីចរន្តអោយបានតឹងតែង។ លើសពីនេះ ដើម្បីរក្សានិរន្តន៍ភាពស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច សមាមាត្រ បំណុលផលិតផលក្នុងស្រុកសរុបរបស់ប្រទេស ត្រូវបានកំនត់ជាស្ថេរភាពបន្ថែម(ជាទូទៅតិចជាង៥០%)។[38]

កម្មវិធីកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមយ៉ាងម៉ឺងម៉ាត់ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៣ ដូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដែលជាគោលគំនិតម៉ាក្រូសេដ្ឋកិច្ចនៃវិទ្យាស្ថាន Bretton Woods។[39] កំណែទម្រង់ដំបូងត្រូវបានធ្វើឡើងនៅពេលបញ្ចប់ការហ៊ុមព័ទ្ធផ្នែកសេដ្ឋកិច្ចនៅឆ្នាំ ១៩៩៣។ មុនពេលនេះ កម្ពុជាបានធ្វើហិរញ្ញប្រទានថវិកាចំពោះឱនភាពចំណាយរបស់ខ្លួន ដែលធ្វើអោយមានអតិផរណាយ៉ាងខ្ពស់ (១២១% ក្នុង ១៩៩១)។[40]

ជាចៃដន្យ នៅក្នុងអំឡុងពេល នេះក៏យើងសង្កេតឃើញ ដុល្លាររូបនីយកម្មនៃសេដ្ឋកិច្ចបានកើនឡើងជាមួយនឹងការបាត់បង់នូវទំនុកចិត្តជាសាធារណៈ និងអន្តរជាតិ លើរូបិយប័ណ្ណក្នុងស្រុក។ សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកលើប្រាក់ដុល្លារ ទាំងលើការប្តូរប្រាក់ និងការរក្សាតម្លៃដែលជាង៩៧%នៃទ្រព្យសកម្មរបស់ធនាគារត្រូវបានគិតជាដុល្លារ ខណៈពេលដែលការអនុវត្តសេដ្ឋកិច្ចកម្ពុជាជារឿយៗ ត្រូវបានវិនិច្ឆ័យក្នុងគោលបំណងដែលបានបង្ហាញ (ពោលគឺ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច) ការវាយតម្លៃមួយផ្សេងទៀតនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាមធ្យោបាយទប់ស្កាត់ ជាពិសេសក្រោមឧបសគ្គនៃសេដ្ឋកិច្ចដែលគ្រប់គ្រងដោយប្រាក់ដុល្លារ។

## សូចនាករដែលបានព្រមព្រៀង

ស្ថេរភាពម៉ាក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជាមានស្ថេរភាពល្អមុនពេលដែលការកើនឡើងនូវតម្លៃអាហារ និងប្រេង នៅឆ្នាំ ២០០៧ និង ២០០៨ (សូមពិនិត្យរូបភាពទី ៤.១)។

---

[37] ចំពោះការទទួលស្គាល់របស់ IMF ពីតំណែងនេះ សូមមើល Blanchard (2010)

[38] កំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវបានណែនាំតាមរយៈកម្មវិធីការធ្វើឲ្យមានស្ថេរភាពដែលមានផលប៉ះពាល់យ៉ាងសម្បើមទៅលើសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ មិនត្រូវបានលើកទឹកចិត្តឲ្យអនុវត្តទេ។ មើល Easterly (2002); Muqtada (2010)

[39] មើល ជួន ណារុន(2010)

[40] មើល ជួន ណារុន(2010) ទំព័រទី ៥៣

### រូបភាពទី ៤.១៖ អតិផរណា ឱនភាពថវិកា និងតុល្យភាពគណនីចរន្ត (គិតជាភាគរយ) ក្នុងអំឡុងឆ្នាំ ១៩៩៣-២០០៨




*ប្រភព៖ គណនាដោយ IMF ឆ្នាំ ២០១០ ចំពោះអត្រាអតិផរណាជាមធ្យម ទិន្នន័យសេដ្ឋកិច្ចកម្ពុជារបស់ ADB ចំពោះតុល្យភាពគណនីចរន្ត និងការលើសនៃ/ឱនភាពថវិកាទាំងមូល*

ការរំកិលនៃអត្រាអតិផរណាមធ្យមក្នុងអំឡុងពេល៣ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៩ គឺមានចំនួនមួយខ្ទង់ (រវាង ០ ដល់ ៦ %)។ អត្រានេះបានកើនឡើងជាខ្លាំងនៅឆ្នាំ ២០០៧ និងបន្តកើនឡើង (ដល់ប្រហែលជា១៩% ក្នុងឆ្នាំ២០០៨)[41] ពេលដែលវិបត្តិសេដ្ឋកិច្ចសកលលោកជះឥទ្ធិពលដល់ប្រទេសកម្ពុជា និងជាពេលដែល មានវិបត្តិចំណីអាហារ និងប្រេង។ ស្រដៀងគ្នានេះដែរ ឱនភាពសារពើពន្ធត្រូវបានទប់ស្កាត់ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៧ តាមរយៈការគ្រប់គ្រងការចំណាយសាធារណៈតាមទំលាប់ ហើយបន្ទាប់ពីនេះឱនភាព ថវិកាចាប់ផ្តើមកើនឡើង។ នៅក្នុងឆ្នាំ ២០០៨ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកទាមទារអោយមានការចំណាយច្រើន ដែលនាំអោយមានឱនភាពថវិកាយ៉ាងធ្ងន់ធ្ងរ។ ឱនភាពគណនីចរន្តដែលមានកំរិតទាប (ជាការពិត លើសពីតម្រូវការនៅឆ្នាំ ២០០៦) ក៏មានការកើនឡើង ដល់ ១២%នៃ ក្នុងឆ្នាំ ២០០៨ ដែលការនាំចូលច្រើនជាងការនាំចេញដែលបានធ្លាក់ចុះ)។

ជាតុល្យភាព គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលផ្តោតលើស្ថេរភាពតាមទំលាប់ អាចរក្សាស្ថេរភាពតម្លៃដោយសមហេតុផលជាពិសេសក្នុងអំឡុងឆ្នាំ១៩៩៩-២០០៧ និងឱនភាពចំណាយត្រូវបានទប់ស្កាត់តាមរយៈការកំរិតសមស្របលើការចំណាយសាធារណៈ ហើយសេដ្ឋកិច្ចមានតុល្យភាពគណនីចរន្ត ដោយសារការកើនឡើងនូវការនាំចេញផលិតផលសំលៀកបំពាក់។ ស្របពេលនេះ ដូចដែលយើងបានធ្វើការអង្កេតមុននេះបន្តិច យើងឃើញថា ក្នុងអំឡុងពេលដែលផលិតផលក្នុងស្រុកសរុបកើនឡើងក្នុងអត្រាដែលគួរអោយចាប់អារម្មណ៍ វិសាលភាពនៃភាពក្រីក្របានធ្លាក់ចុះ។ ជាការពិតណាស់ ប្រសិនយើងក្រលេកមើលភ្លាមៗ កំណែទម្រង់ស្ថេរភាពបានជួយកម្ពុជាក្នុងការសំរេចបាននូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ចដែលនាំមកនូវវិនិយោគ កំណើន និងការកាត់បន្ថយភាពក្រីក្រ។ ទោះបីជាយ៉ាងណាក៏

[41] រាជរដ្ឋាភិបាល (2010), op.cit. តារាងទី ៩ ទំព័រទី ៩៣

ដោយ មានគំនិតដែលថា ខណៈពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការដើម្បីធានានិរន្តភាពនូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនបានបង្អាក់ដោយសារហេតុការចៃដន្យផ្សេងៗ។[42] ជាសំខាន់ ដោយសារវិបត្តិហិរញ្ញវត្ថុ ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច ដែលបានប្រើប្រាស់ដើម្បីរក្សាស្ថេរភាព គឺស្ថិតនៅក្រោមសំពាធ។ ការបើកចំហរ និងសេរីភាពនៃសេដ្ឋកិច្ច មិនត្រូវបានកំនត់ដោយការរឹតបន្តឹងហិរញ្ញវត្ថុ ឬដោយស្ថាប័ន និងបទប្បញ្ញត្តិដែលអាចទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិបានប្រសើរជាងទេ។[43] ដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចអាចធ្វើអោយបាត់ផលប្រយោជន៍ និងសមត្ថភាពរបស់ធនាគារជាតិ ក្នុងការដើរតួនាទីជាអ្នកអោយខ្ចីចុងក្រោយ និង "ការបាត់បង់នូវគោលនយោបាយរូបិយវត្ថុឯករាជ្យ ដែលទាំងអស់នេះ កំរិតនូវសមត្ថភាពក្នុងការឆ្លើយតបទៅនឹងវិបត្តិខាងក្រៅ"។[44]

## គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច កំណើន និងមុខរបរ

វិធីសាស្ត្រតែមួយគត់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (រក្សាស្ថេរភាពតម្លៃ) ដូចដែលអនុវត្តជាមួយកម្មវិធីធ្វើអោយមានស្ថេរភាព នៅតែជាហានិភ័យមួយនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចកម្ពុជា។ ដូចនេះ ទាមទារអោយមានការគិតគូរឡើងវិញ ទៅលើគោលដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការសំរេចបាន នូវគោលដៅអភិវឌ្ឍន៍សហសវត្ស គោលដៅការងារពេញលេញ និងការងារសមរម្យ ដែលទាមទារអោយមានក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរួមបញ្ចូលគ្នាជាមួយគោលដៅចំរុះ ដោយពឹងផ្អែកលើស្ថានភាពជាក់លាក់របស់កម្ពុជា។ ប្រទេសអាស៊ីភាគខាងកើត ក្នុងអំឡុងទសវត្សរ៍ ១៩៧០ និង១៩៨០ បានបង្ហាញថាទស្សនៈចំរុះ ដែលមូលដ្ឋានគ្រឹះនៃម៉ាក្រូសេដ្ឋកិច្ច ត្រូវបានសំរេចជារួមជាមួយនឹងការគាំទ្រគោលនយោបាយទៅលើ ការសន្សំ វិនិយោគ កំណើន និងការបង្កើតការងារ។[45] មានការកើនឡើងនូវការតស៊ូមតិ ពីសំណាក់ក្រុមផ្សេងៗ ដើម្បីកុំអោយចំនុចកណ្តាលនៃការងារ ស្ថិតនៅក្នុងទម្រង់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចដែលការអនុវត្តន៍មុនពេលចាប់ផ្តើមនៃ Washington Consensus[46]។

គោលបំណងការងារក្នុងការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ត្រូវសមស្របជាមួយនិរន្តន៍ភាព និងការសំរេចបានតំរូវការសរុប។ ជាតុសំខាន់មួយនៃតំរូវការសរុប គឺ សមាមាត្រ I/ផលិតផលក្នុងស្រុកសរុបដែលមានចន្លោះពី ២០% ដល់ ២៤% ក្នុងអំឡុង ឆ្នាំ ២០០៣-២០០៩[47] និងជំរុញអោយមាន

---

[42] មើល Jalilian និង Reyes (2010) ដែលតវ៉ាដោយបញ្ចុះបញ្ចូលថាកំណើននៅកម្ពុជាគឺដោយសារតែកាលៈទេសៈអំណោយផល (ដូចជាទីផ្សារធានានៃវិស័យកាត់ដេរក្រោម MFA និង GSP) ដែលជាគោលនយោបាយធ្វើឲ្យមានស្ថេរភាព។

[43] មើល IMF (2009) ផងដែរ

[44] Cf. Jalilian និង Reyes (2010) ទំព័រទី ៣៨

[45] មើល Khan & Muqtada (1997) ; Muqtada (2003)

[46] Bruton (១៩៩៧) អះអាងថាការបន្ត "តម្រូវការការងារជាចីរភាព" ត្រូវតែស្ថិតនៅលើចំណុចសំខាន់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

[47] រាជរដ្ឋាភិបាលកម្ពុជា (2010) ទំព័រទី ២២ និងទំព័រទី ៩៣

កំណើនផលិតផលក្នុងស្រុកសរុប ប្រហែលជា៩%។ ជំហាននៃកំណើនរបស់ប្រទេសកម្ពុជាបែបនេះ អាចនឹងលំបាកក្នុងការរក្សានិរន្តន៍ភាពនៅពេលអនាគត (ពីព្រោះ ICORs នាពេលបច្ចុប្បន្ន អាចនឹងកើនឡើងប្រហែលជា២.៣) ប្រសិនបើ I/ផលិតផលក្នុងស្រុកសរុប មិនកើនឡើង ពី ២៨-៣០% ទេនោះ។ អ្វីដែលជាបញ្ហាសំខាន់គឺថា សមាមាត្រសន្សំជាតិ ក៏ដូចជាសមាមាត្រ I/ផលិតផលក្នុងស្រុកសរុប ដែលត្រូវគាំទ្រដោយប្រភពបរទេស នោះការសន្សំបរទេស គឺ ១២%នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ ២០០៨ ខណៈពេលដែលវិនិយោគទុនបរទេសជិត ៤៧%នៃវិនិយោគទុនសរុបនៃសេដ្ឋកិច្ច។ ការពឹងផ្អែកដ៏លើសលប់នៃ I/ផលិតផលក្នុងស្រុកសរុប លើ FDIs ដែលធ្លាក់ចុះយ៉ាងខ្លាំងក្នុងអំឡុងឆ្នាំ ២០០៩មក អាចប៉ះពាល់ដល់វិនិយោគទុនឯកជនក្នុងស្រុក។ ដូចនេះប្រសិនបើ នៅក្នុងបរិយាកាសបច្ចុប្បន្ននៅនឹងថ្កល់ ឬក៏ថយចុះ នៅពេលខ្លីៗខាងមុខ រាជរដ្ឋាភិបាលកម្ពុជាគួរដាក់ចេញនូវ I/ផលិតផលក្នុងស្រុកសរុប ដែលនឹងថ្កល់ក្នុងអំឡុងឆ្នាំ ២០០៩-២០១៣[47] (សូមមើលរូបភាពទី ៤.២)។

**រូបភាពទី ៤.២៖ ការវិនិយោគសាធារណៈ និងឯកជន (គិតជាភាគរយ GDP)**
**ក្នុងអំឡុងឆ្នាំ ១៩៩៤-២០១៣**




*ប្រភព៖ ដូចមានយោងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នឆ្នាំ ២០០៩-២០១៣ តារាងទី ៨ និងទី ៩ ចាប់តាំងពីឆ្នាំ២០០៩ រហូតមក ជាការប៉ាន់ប្រមាណ និងគម្រោង។*

គួរអោយកត់សំគាល់ផងដែរថា ការមិនកើនឡើងនូវវិនិយោគទុនសាធារណៈ គឺមានសារៈសំខាន់សំរាប់ង្កើនវិនិយោគទាំងក្នុងស្រុក និងFDI។ ការពឹងផ្អែករបស់សេដ្ឋកិច្ចលើធនធានខាងក្រៅ ក៏ដូចជាកត្តាដុល្លារូបនីយកម្មដែលបានបង្កើតឧបសគ្គបន្ថែមទៅលើតួនាទីទូទៅរបស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច។ ដូចនេះ ជំហរសារពើពន្ធមិនអនុញ្ញាតហិរញ្ញប្បទានរូបិយវត្ថុ សំរាប់ឱនភាពថវិកានោះទេ ឬ ក៏កង្វះនូវការគ្រប់គ្រងសមស្របរបស់ធនាគារជាតិទៅលើ អត្រាគោលនយោបាយអាចបង្កើតភាពមិនច្បាស់លាស់នៅក្នុងបរិយាកាសវិនិយោគ។ គោលនយោបាយហិរញ្ញវត្ថុ និងគោលដៅអតិផរណាដោយគ្មានការគ្រប់គ្រងភ្លាមៗទៅលើអត្រាការប្រាក់ អាចមានភាពផុយស្រួយ ជាពិសេសពេលដែលមានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដើម្បីគាំទ្រតម្រូវការសរុប និងការងារ ដែលទាមទារអោយមានកំរិតនៃការពង្រីកការចំណាយ

មួយ និងគោលនយោបាយហិរញ្ញវត្ថុ។ ការកំណត់គោលដៅលើអតិផរណា និងឱនភាពថវិកាមានសារៈសំខាន់ណាស់ ប៉ុន្តែដើម្បីរួមចំនែកទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងមូល កំណើន និង ការងារសំរាប់ស្ថេរភាពទាំងនេះ អាចជួបនូវហានិភ័យ។[48] វិធានសារពើពន្ធមិនតម្រូវអោយរួមបញ្ចូលជាមួយគោលនយោបាយសារពើពន្ធ និងតួនាទីប្រតិសកម្មនោះទេ ដែលវិធាននេះអាចដើរតួនាទីទាំងក្នុងដំណើរការស្ថេរភាព និងកំណើន។[49]

ដើម្បីជំរុញការបង្កើតការងារ គឺទាមទារអោយមានសារពើពន្ធដើម្បីគាំទ្រចំណាយសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាកម្មវិធីសំណាញ់សុវត្ថិភាពសង្គមផងដែរ។ ជាការពិតមានប្រភពផ្សេងៗគ្នាដែលតាមរយៈនេះ ចន្លោះប្រហោងនៃសារពើពន្ធអាចត្រូវបានបង្កើត។ នៅក្នុងប្រទេសកម្ពុជាពេលបច្ចុប្បន្ន ប្រភពដ៏លេចធ្លោគឺ ODAs ពីព្រោះជំរើសដ៏ទៃទៀតដូចជា កម្ចីសាធារណៈ ការបង្កើនចំណូល និង/ឬ ការធ្វើអាទិភាពចំណាយសាធារណៈសារឡើងវិញ អាចផ្តល់ឱកាសដែលមានកំរិតយ៉ាងហោចណាស់ក្នុងរយៈពេលខ្លី។ ដើម្បីបង្កើតនូវការពឹងផ្អែកលើខ្លួនឯងអោយកាន់តែខ្លាំងក្លាជាងនេះ ដើម្បីឆ្លើយតបនឹងការប្រឈមនៃឱនភាពចំណាយ និងដើម្បីសំរេចបានកំរិតចំណាយ គឺទាមទារអោយមានការវិវត្តន៍ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៃសេដ្ឋកិច្ច (សូមពិនិត្យមើលផ្នែកទី ៧)។

ភាពអត់ដំណើរការនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចគឺទាក់ទងនឹង៖ ១. តួនាទីដែលមានកំរិតរបស់ធនាគារជាតិទាក់ទងទៅនឹងគោលនយោបាយហិរញ្ញវត្ថុ ជាពិសេសគឺកង្វះការគ្រប់គ្រងអត្រាគោលនយោបាយ ២. គោលបំណង ទប់ស្កាត់អតិផរណាអោយនៅទាបជាងកំរិត ៥% កំពុងតែអនុវត្ត មិនមែនតាមរយៈ ការគ្រប់គ្រងអត្រាការប្រាក់នោះទេ ប៉ុន្តែតាមរយៈការគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់ដោយការទិញលក់ប្រាក់ដុល្លារ ៣. ដុល្លាររូបនីយកម្មនៃការចំណាយសាធារណៈសេដ្ឋកិច្ចត្រូវបានដាក់កំរិត និង ឱនភាពសារពើពន្ធត្រូវបានដោះស្រាយតាមរយៈការគាំទ្រពីភ្នាក់ងារផ្តល់ជំនួយ ៤. ជាមួយនឹងភាពទន់ខ្សោយរបស់ប្រាក់ដុល្លារពេលថ្មីៗនេះ ជាពិសេសបន្ទាប់ពីភាពអសកម្មនៅក្នុង សហរដ្ឋអាមេរិច គណនីបច្ចុប្បន្នស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងន់ ខណៈដែលមានការកើនឡើងនូវថ្លៃនៃការនាំចូល។ ដូចនេះ ជាឥទ្ធិពលវិបត្តិមិនត្រឹមតែបានបង្ហាញភាពងាយរងគ្រោះរបស់សេដ្ឋកិច្ច និងសក្តានុពលកំណើនរបស់វាទេ តែថែមទាំងភាពងាយរងគ្រោះរបស់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់សេដ្ឋកិច្ចថែមទៀត។ *ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ទាមទារអោយមានការត្រួតពិនិត្យបន្ថែមទៀត ទាំងគោលដៅក៏ដូចជាឧបករណ៍គោលនយោបាយ សំរាប់វិធីសាស្ត្រខ្លាំងក្លាឆ្ពោះទៅកាន់ កំណើនរយៈពេលវែង និងការផ្លាស់ប្តូរដែលមានលំដាប់។*

---

[48] I. Islam (2010)

[49] ចំពោះកិច្ចពិភាក្សាលម្អិតបន្ថែម

## ៥. គោលនយោបាយតាមវិស័យ និងការផ្លាស់ប្តូរតាមលំដាប់

កំណើនឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជាតាំងពីចុងទសវត្សរ៍១៩៩០ ដែលកើនឡើងក្នុងអំឡុងកំណើនសកលលោកក្នុងអំឡុងឆ្នាំ២០០២–២០០៧ នាំមកនូវការផ្លាស់ប្តូរជាក់ស្តែងដល់ការបែងចែកតាមវិស័យនៅក្នុងផលិតផលក្នុងស្រុកសរុប។ ជាពិសេស វិស័យឧស្សាហកម្មកើនឡើងក្នុងកំរិតលឿនដោយសារកំណើនការនាំចេញRMG ដែលនាំអោយការបែងចែកតាមវិស័យកើនឡើង ប្រហែលពី១២.៦% នៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ១៩៩៣ ដល់ប្រហែលជា ២៥% ក្នុងឆ្នាំ២០០៧។ ការបែងចែកនៃវិស័យសេវាកម្មនៅតែមានកំរិតខ្ពស់ប្រហែលជា ៣៩% ក្នុងអំឡុងឆ្នាំ ១៩៩៤-២០០៨។ ដូចដែលយើងសង្ឃឹមក្នុងអំឡុងការផ្លាស់ប្តូរតាមលំដាប់នៃសេដ្ឋកិច្ច វិស័យកសិកម្មបានធ្លាក់ចុះ ពីប្រហែល៤៣% នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ១៩៩៨ មកត្រឹមប្រហែល ២៧% ក្នុងឆ្នាំ ២០០៨ (សូមពិនិត្យមើលរូបភាពទី ២.៥)។

បទពិសោធន៍សេដ្ឋកិច្ចអភិវឌ្ឍន៍ និងភាពលេចធ្លោនៃអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ ខុសគ្នាពីមួយទៅមួយ តែទោះជាយ៉ាងណាក៏ដោយការអនុលោមតាមគំរូអភិវឌ្ឍន៍តាមពេលវេលាបានគូសបង្ហាញនូវភាពចាំបាច់ក្នុងការនាំមកនូវការផ្លាស់ប្តូរតាមលំដាប់ ដើម្បីសំរេចបានលក្ខខណ្ឌជីវភាពរបស់ ប្រជាជន។ ដូចដែលយើងបានដឹង ការផ្លាស់ប្តូរជាគន្លឹះតាមលំដាប់ គឺមានការកើនឡើង នូវវិស័យទំនើបដែលក្នុងនោះឧស្សាហកម្មជាវិស័យឈានមុខគេ។

គំរូអភិវឌ្ឍន៍ Lewisian គាំទ្រយុទ្ធសាស្ត្រនេះ ដូចដែលយើងសង្កេតឃើញនៅក្នុងដំណាក់កាលដំបូងនៃប្រទេសអាស៊ានដែលទទួលបានជោគជ័យ ចំនែកឧស្សាហកម្ម(ជាពិសេសការផលិត) កើនឡើងពី ១០-១៥% ទៅដល់ជិត ៣០% ឬច្រើនជាងនេះនៃផលិតផលក្នុងស្រុកសរុប។ អ្វីដែលសំខាន់ដូចគ្នាទៅលើការផ្លាស់ប្តូរតាមលំដាប់ គឺការផ្លាស់ប្តូរការងារ ពីកសិកម្មដែលមានផលិតភាពទាប ទៅជាវិស័យផលិតដែលមានផលិតភាពខ្ពស់។ យើងអាចនិយាយបានម្យ៉ាងទៀតថា ចំណែកតាមវិស័យនៅក្នុងការផ្លាស់ប្តូរការងារសរុប គឺអនុគ្រោះចំពោះវិស័យផលិតដែលមានផលិតភាពខ្ពស់។ ចំណែកការងារសរុបតាមវិស័យនៅក្នុងសេដ្ឋកិច្ចអាស៊ីខាងកើត កើនឡើងជិត២៥-៣០% និងច្រើនជាងនេះនៅក្នុងករណីខ្លះ។ ការផ្លាស់ប្តូរតាមលំដាប់នេះត្រូវបានកំណត់ដូចកត្តាខាងក្រោម៖

- ផលិតភាពការងារនៅក្នុងវិស័យឧស្សាហកម្មកើនឡើងក្នុងកំណើនខ្ពស់ជាងក្នុងវិស័យកសិកម្ម
- ផលិតភាពកសិកម្មក៏មានការកើនឡើងដែរ ហើយដើរតួយ៉ាងសំខាន់ ក្នុងការសំរេចបានលទ្ធផលលើសតម្រូវការ ការងារ និង ការនាំចេញ ចំនែកតម្លៃបន្ថែមចំពោះពលករម្នាក់ នៅក្នុងវិស័យកសិកម្មកើនខ្ពស់ជាងអត្រាកំណើនកម្លាំងពលកម្ម

➢ ភាពបត់បែនការងារក្នុងការផលិត មានកំរិតខ្ពស់ ដែលអាចស្រូបយកកម្លាំងពលកម្មក្នុងអត្រាខ្ពស់ នៅក្នុងវិស័យទំនើប។[50]

នៅក្នុងប្រទេសកម្ពុជា រូបភាពពីរខាងក្រោមបង្ហាញអត្រាកំណើន វិស័យទូទៅនៃសេដ្ឋកិច្ច និងតម្លៃបន្ថែមសំរាប់ពលករម្នាក់ (តំណាងផលិតភាពពលកម្ម)។

### រូបភាពទី ៥.១៖ គំរូកំណើនតាមវិស័យ (គិតជាភាគរយ) ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨




*ប្រភព៖ គណនាដោយ NIS (2010); សៀវភៅស្ថិតិប្រចាំឆ្នាំរបស់ NIS ឆ្នាំ ២០០៥ ទិន្នន័យគណនីជាតិ របស់ NIS ឆ្នាំ ២០០៨ មានបង្ហោះនៅគេហទំព័រ http://www.nis.gov.kh/index.php/statistics/national-accounts*

### រូបភាពទី ៥.២៖ តម្លៃបន្ថែមក្នុងពលករម្នាក់ ក្នុងអំឡុងឆ្នាំ ១៩៩៣-២០០៨ (គិតជារៀល)




*ប្រភព៖ គណនាដោយ ADB មន្ទនយសេដ្ឋកិច្ចកម្ពុជា*

[50] ជាការពិត ជិត ៣ ភាគ ៤ នៃកម្លាំងពលកម្មបន្ថែមធ្វើទេសន្តប្រវេសន៍ពីជនបទមកកាន់ទីក្រុង គឺបម្រើនៅក្នុងវិស័យកម្មន្តសាល Cf. Bai និង Kim (1985)

យើងសង្កេតឃើញពីរូបភាពទាំងពីរនេះថា វិស័យទាំងបីមានអត្រាកំណើនខ្ពស់ ក្នុងអំឡុងទសវត្សរ៍១៩៩៨-២០០៨។ ការបង្កើតការងារ ក៏មានលទ្ធផលជាក់ស្តែងជាមួយនឹងការកើនឡើងនូវការងារវិស័យឧស្សាហកម្មដែលលឿនជាងវិស័យដទៃទៀត។ នៅក្នុងវិធានការខ្លះ មានការចង្អុលបង្ហាញនូវដំណើរការនៃការផ្លាស់ប្តូរ។ ទោះបីជាយ៉ាងណាក៏ដោយ កំណើនផលិតភាពការងារនៅក្នុងវិស័យទាំងបីគឺមិនស្មើគ្នា ហើយបានធ្លាក់ចុះនៅក្រោយសង្គ្រាម។ សំខាន់ជាងនេះទៅទៀត កំណើនយ៉ាងលឿននៃវិស័យចេញពីមូលដ្ឋានទាបមួយ ទាមទារអោយមានការរក្សាអត្រាកំណើនខ្ពស់ ដើម្បីផ្តល់ឥទ្ធិពលដល់ការផ្លាស់ប្តូរតាមលំដាប់ជាក់ស្តែង។ *ការផ្លាស់ប្តូរយឺតនៅក្នុងចំណែកវិស័យការងារសរុប បង្ហាញភាពមានកំរិតនៃការផ្លាស់ប្តូរមានលំដាប់ក្នុងសេដ្ឋកិច្ចកម្ពុជា។* ការពិចារណាបន្ថែមលើបញ្ហានេះគឺថា ទោះបីជាការងារមានការរីកចំរើននៅគ្រប់វិស័យ វាមានការលំបាកក្នុងការអះអាងថា ការងារនោះផ្តល់ប្រាក់កំរៃខ្ពស់ប៉ុណ្ណា។ យើងអាចនិយាយបានថា ការបង្កើតការងារភាគច្រើន គឺនៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ ដែលមានផលិតភាពទាប និងវិស័យបន្ទាប់បន្សំដែលមានប្រាក់ចំណូលទាប។ ផ្ទុយមកវិញ សូចនាករតំណាងការងារដែលមានផលិតភាព/ប្រាក់ចំណូល គឺជាកំណើននៅក្នុងវិស័យការងារផ្លូវការ ដូចជានៅក្នុងការងារវិស័យសាធារណៈ និងក្នុងវិស័យឯកជនទំនើប។ នៅទីនេះ យើងត្រូវញែកអោយដាច់គ្នារវាង កម្មករនិយោជិតបណ្តែត សាកល្បង និង/ឬ ម៉ៅការ នឹងកម្មករនិយោជិតពេញសិទ្ធិដែលធ្វើការពេញម៉ោង។

ជាសន្និដ្ឋាន តាមរយៈកំណើនយ៉ាងឆាប់រហ័ស សេដ្ឋកិច្ចកម្ពុជាបានលេចចេញការផ្លាស់ប្តូរជារូបរៀងតាមវិស័យនីមួយៗ នៅក្នុងផលិតផលក្នុងស្រុកសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងលក្ខខណ្ឌចំនែកតាមវិស័យនៅក្នុងការងារ ការផ្លាស់ប្តូរតាមលំដាប់នៅមានកំរិតនៅឡើយ។ ភាគច្រើននៃកម្លាំងពលកម្ម គឺនៅក្នុងវិស័យកសិកម្មនិងជនបទ នេះមិនមែនជាការភ្ញាក់ផ្អើលនោះទេ ដែលមានជនក្រីក្រភាគច្រើននៅក្នុងសេដ្ឋកិច្ច។

## ការអភិវឌ្ឍកសិកម្ម និង ជនបទ

ភាគច្រើននៃកម្លាំងពលកម្ម នៅក្នុងប្រទេសកម្ពុជានៅតែពឹងផ្អែកលើវិស័យកសិកម្ម ដែលត្រូវបានកំណត់ ដោយការធ្វើកសិកម្មលើផ្ទៃដីតូច និងការរស់នៅពឹងផ្អែកលើដីមួយចំណែកតូច។ ផលិតផលលេចធ្លោគឺដំណាំស្រូវ ទោះបីជាចំណែករបស់វានៅក្នុងវិស័យដែលតម្លៃបន្ថែម មានការធ្លាក់ចុះក៏ដោយ។[51] ការនេសាទ និងការចិញ្ចឹមសត្វបានរួមចំណែកយ៉ាងសំខាន់ នៅក្នុងផលិតផលក្នុងស្រុកសរុប របស់ប្រទេស។[52] យើងត្រូវកត់សំគាល់ថាជាមួយនឹងកសិកម្មសំរាប់ផ្គត់ផ្គង់គ្រួសារ ក៏មានលេចចេញនូវកសិកម្មជាលក្ខណៈពាណិជ្ជកម្ម និងការកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម ដែលមិនត្រឹមតែរួមចំណែកទៅក្នុងវិស័យនោះទេ ប៉ុន្តែជាប្រភពដ៏សំខាន់មួយនៃការនាំចេញ និងការរកប្រាក់ចំណូលពីបរទេសផងដែរ។

---

[51] Cf. ជួន ណារុន(2010), op cit

[52] Cf. ជួន ណារុន(2010), op cit, ទំព័រទី ៦០

វិស័យសេដ្ឋកិច្ច រួមចំនែកជិត ២៧% ទៅក្នុងផលិតផលក្នុងស្រុកសរុបរបស់ប្រទេស និងជាង ៧២%នៃការងារសរុប។ កសិកម្ម(រួមទាំងរុក្ខាប្រមាញ់) រួមចំនែកយ៉ាងសំខាន់នូវចំណូលក្នុងការនាំចេញ។ នៅក្នុងឆ្នាំ២០០៧ ប្រទេសកម្ពុជាផលិតស្រូវបានជិត ៦លានតោន នេះមិនត្រឹមតែអនុញ្ញាតអោយប្រទេសកម្ពុជា អាចផ្គត់ផ្គង់ទីផ្សារក្នុងស្រុកទេ ថែមទាំងបាននាំចេញក្នុងកំរិតគួរអោយកត់សំគាល់ផងដែរ (ជិត២លានតោន)។[53] ទោះបីជាវិស័យកសិកម្មបានកើនឡើងនៅក្នុងអំឡុងពេលថ្មីនេះ ផលិតភាពក៏នៅមានកំរិតទាបបើប្រៀបធៀប ទៅនឹងប្រទេសអាស៊ីដទៃទៀត (សូមពិនិត្យមើលរូបភាពទី ៥.៣)។

**រូបភាពទី ៥.៣៖ តម្លៃផលិតផលដំណាំក្នុងមួយហិកតា នៅកម្ពុជា និងបណ្តាប្រទេសអាស៊ី**




*ប្រភព៖ UNDP (2010)*

បទពិសោធន៍ពីដំណាក់កាលដំបូង នៃការផ្លាស់ប្តូរតាមលំដាប់នៅក្នុងប្រទេសអាស៊ីខាងកើត[54] បានបង្ហាញយើងថា កំណើន និងផលិតភាពនៅក្នុងវិស័យកសិកម្ម បានជួយប្រទេសទាំងនេះ សំរេចបាននូវភាពលើសតម្រូវការដែលគួរអោយកត់សំគាល់ ផ្តល់ឱកាសការងារកាន់តែច្រើន និងបញ្ឈប់នូវឧបសគ្គចំបងនៃទំនិញនិងប្រាក់ឈ្នួល ដែលអាចកើតចេញពីការកើនឡើងនៃប្រាក់ចំណូល និងប្រាក់កំរៃ។ នៅក្នុងប្រទេសទាំងនេះមានការកើនឡើងនូវការប្រើប្រាស់កម្លាំងការងារក្នុងដីមួយហិកតា ស្របជាមួយនឹងការកើនឡើងនូវលទ្ធផល និងផលិតភាពការងារ។ អ្នកវិភាគចាត់ទុកជោគជ័យទទួលបានដោយសាររចនាសម្ព័ន្ធកសិកម្ម និងក្របខណ្ឌស្ថាប័នត្រូវបានបង្កើត។ ការផ្តោតសំខាន់ពីរយ៉ាងគឺ លើរចនាសម្ព័ន្ធស្មើគ្នានៃផលិតផល (តាមរយៈកំណែទម្រង់ដីធ្លី) និងការប្រើប្រាស់នូវបច្ចេកវិទ្យាដែលពឹងផ្អែកលើកម្លាំងពលកម្ម (ឧទាហរណ៍ ប្រព័ន្ធស្រោចស្រពសហគមន៍ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ) ធ្វើអោយមានការកើនឡើងក្នុងការស្រូបយកកម្លាំងពលកម្មក្នុងវិស័យកសិកម្ម។

[53] Cf. ជួន ណារុន(2010), op cit, ទំព័រទី ៦០

[54] Ishikawa (1981) ចំពោះការស៊ើបអង្កេតដោយមានសំអាង

អត្ថប្រយោជន៍ពិតប្រាកដរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ក្នុងដំណាក់កាលមានការផ្លាស់ប្តូរតាមលំដាប់នេះ ប្រហែលជានៅក្នុងផលិតផលដែលពឹងផ្អែកលើដីធ្លី ការងារ និងការនាំចេញ។ នៅក្នុងកសិកម្ម កម្ពុជាមានសក្តានុពលសំរាប់បង្កើនផលិតភាព និងស្រូបយកកម្លាំងពលកម្ម (ដូចជា ការប្រើប្រាស់ពេញលេញនូវពលកម្ម និងសមត្ថភាព)។ តាមរយៈការអភិវឌ្ឍន៍កសិកម្មខ្នាតតូច និង កសិកម្មពាណិជ្ជកម្មខ្នាតធំ (រួមទាំងរុក្ខាប្រមាញ់ និងដំណាំ) កសិកម្មកម្ពុជាអាចធ្វើអោយមានប្រសិទ្ធភាពនូវផលិតភាព និងការចល័តធនធានសំរាប់កំណើនហិរញ្ញវត្ថុ។ មានឧបសគ្គ និងបញ្ហាមួយចំនួន ដែលទាមទារអោយមានដំណោះស្រាយ ដើម្បីទទួលបានសក្តានុពលទាំងនេះ។ នៅក្នុងស្ថានភាពបច្ចុប្បន្ន ការប្រមូលផលទិន្នផលមួយមុខ ឧទាហរណ៍ស្រូវ គឺនៅតែមានភាពលេចធ្លោ។ ទិន្នផលដំណាំចំរុះ ប្រភេទផ្សេងៗគ្នានៃដំណាំ និងពិពិត្តកម្មឆ្ពោះទៅកាន់ដំណាំដែលមានតម្លៃបន្ថែម អាចសំរេចបាននូវផលិតភាព ក៏ដូចជាការប្រើប្រាស់នូវកម្លាំងពលកម្ម។ នេះអាចទាមទារអោយមានគោលនយោបាយ និង ការចំណាយសាធារណៈលើការពង្រីកប្រព័ន្ធធារាសាស្ត្រ និងការសំរបសំរួលនៃលទ្ធភាពដើម្បីទទួលបាន ធាតុចូលបច្ចេកវិទ្យា និងធនធាន។ គួរតែមានការធានានូវសុវត្ថិភាព ការងារ និងលទ្ធភាពទទួលបានកម្ចី ក៏ដូចជាវគ្គបណ្តុះបណ្តាល និងការពង្រីកសេវាកម្ម។

តាមរយៈការកើនឡើងនូវផលិតភាព និងការប្រើប្រាស់កម្លាំងពលកម្ម កំណើនកសិកម្មអាចត្រូវបានសង្កេតឃើញ មានការកើនឡើងតម្លៃដី និងការងារជាអតិបរមា។ នេះអាចនាំអោយមានកំណើនប្រាក់កំរៃ និងការងារដែលមានប្រាក់កំរៃផងដែរ ដែលប្រទេសអាស៊ីភាគច្រើនចាត់ទុកថាជាដំណាក់កាលដំបូងនៃការផ្លាស់ប្តូរតាមលំដាប់។ កំណើនកសិកម្ម បានបង្កើតអោយមានតម្រូវការនៅក្នុងវិស័យដទៃជាពិសេស ទំនិញកសិកម្ម សហគ្រាសជនបទ ដែលជួយអោយមានការកើនឡើងប្រាក់កំរៃ និងប្រាក់ចំណូលក្នុងចំណោមប្រជាជនជនបទ និងដើម្បីកាត់បន្ថយភាពក្រីក្រ។

ផ្នែកខ្លះនៃកសិកម្មកម្ពុជា មានលក្ខណៈពាណិជ្ជកម្មរួចទៅហើយ ដែលអាចធ្វើអោយមានការកើនឡើងនូវតម្លៃទំនិញ គោលជំហរកសិកម្មក្នុងការនាំចេញ និងសក្តានុពលពាណិជ្ជកម្ម។ ទាំងនេះទាមទារអោយមានរចនាសម្ព័ន្ធ និងយន្តការលើកទឹកចិត្តសមរម្យមួយ ដូចជាជំរុញអោយមានវិនិយោគទុនក្នុងស្រុក វិនិយោគទុនផ្ទាល់ ដែលអាចធ្វើបានក្នុងទម្រង់កសិកម្មខ្នាតធំ ដំណាំ និងឈើ។

ការផ្តល់ និងសំរេចបាននូវជំនាញ ការជំរុញអោយមានបច្ចេកវិទ្យា ការអភិវឌ្ឍន៍ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត មានសារៈសំខាន់ណាស់ក្នុងពាណិជ្ជកម្មនៃកសិកម្ម។ ជាការពិត វិធានការសាធារណៈសមរម្យទាមទារអោយធានាថា កម្ពុជាមិនក្លាយជាប្រទេសដែលមានអសន្តិសុខស្បៀងនៅក្នុងដំណើរការនៃពាណិជ្ជកម្ម។ កម្មវិធីគាំទ្រតម្លៃស្រូវ អង្ករ នាពេលបច្ចុប្បន្ន ដើម្បីធ្វើអោយមានស្ថេរភាពតម្លៃជាជំហានដ៏សំខាន់ឆ្ពោះទៅកាន់ការធានាបាននូវស្ថេរភាពក្នុងចំណូលកសិកម្ម។

ក្នុងអំឡុងពេលមុនវិបត្តិ រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតសំខាន់ផ្សេងគ្នាលើ កសិកម្ម និងការអភិវឌ្ឍន៍ជនបទ។ នេះត្រូវបានសង្កេតឃើញនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

២០០៩-២០១៣ ដែលបានកំណត់ការកាត់បន្ថយភាពក្រីក្រនៅជនបទជាអាទិភាពខ្ពស់បំផុត។ គោលនយោបាយ និងធនធានផ្សេងៗត្រូវបានចាត់ចែងផ្ទាល់ដើម្បីបង្កើនផលិតភាពការងារ និងជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទ និងក្នុងការកាត់បន្ថយគម្លាតជីវភាពរស់នៅតាមជនបទ។ ការសាកល្បងដ៏សំខាន់នឹងមាននៅក្នុងការអនុវត្តនូវគោលនយោបាយផែនការ កម្មវិធីទាំងនេះ និងក្នុងការធានាក្របខណ្ឌស្ថាប័នដែលចាំបាច់សំរាប់ជោគជ័យនៃយុទ្ធសាស្ត្រនេះ។

## ឧស្សាហូបនីយកម្ម និងគោលនយោបាយពាណិជ្ជកម្ម៖ ការពង្រឹងសក្តានុពលបង្កើតការងារ

ក្នុងពេលរៀបចំផែនការអភិវឌ្ឍន៍ឆ្នាំ ២០០៤-២០០៨ សម្រាប់បន្ទយុទ្ធសាស្ត្រចតុកោណ អ្នករៀបចំគោលនយោបាយរបស់កម្ពុជា បានឲ្យឈ្មោះផែនការនោះថាជា *"ជំហានវិវត្តន៍សេដ្ឋកិច្ច"*។[55] តាមទ្រឹស្តីសេដ្ឋកិច្ច និងបទពិសោធន៍ ជាធម្មតាជំហានវិវត្តន៍របស់ប្រទេសនីមួយៗ ពាក់ព័ន្ធនឹងដំណើរចាក់ឬសនៃឧស្សាហូបនីយកម្ម និងការរួមចំណែកចំពោះផលិតផលក្នុងស្រុកសរុប និងការកើនឡើងមុខរបរប្រកបដោយនិរន្តរភាព។ ដំណើរការនេះត្រូវបានកត់ទុកជាបទពិសោធន៍សេដ្ឋកិច្ចរបស់ប្រទេសនៅតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍នាទសវត្សរ៍ទី ៧០ និង ៨០។[56] ផ្ទុយទៅវិញ ក្នុងពេលដដែលនេះក៏មានករណីជាច្រើនដែលការវិវឌ្ឍន៍ ផ្នែកឧស្សាហូបនីយកម្មដ៏ខ្លាំងមួយត្រូវបានបញ្ចប់ "មិនដូចការគិតទុក" ចំណែកផ្នែកកម្មន្តសាល ដែលធ្លាប់រំពឹងថានឹងបង្កើតការងារជាក់លាក់ បែរជាមិនអាចរួមចំណែកនៅក្នុងដំណើរការបង្កើតការងារទៅតាមតម្រូវការទៅវិញ ដូចជាប្រទេសប៉ាគីស្ថាននាទសវត្សរ៍ទី៧០ ជាឧទាហរណ៍ស្រាប់។[57]

បទពិសោធន៍ជោគជ័យនៃឧស្សាហូបនីយកម្មផ្សេងគ្នា និងការវិវឌ្ឍន៍មិនដូចការគិតទុកត្រូវបានយកមកពិភាក្សាយ៉ាងទូលំទូលាយ ហើយត្រូវបានភ្ជាប់ទៅនឹងការតំរង់ការនាំចេញនៃឧស្សាហូបនីយកម្ម។ ជារួម ជោគជ័យបានពីឧស្សាហូបនីយកម្មដែលពឹងផ្អែកលើការនាំចេញ និងពលកម្មរបស់អាស៊ីខាងកើតដែលការវិវត្តមិនដូចការគិតទុកនៅក្នុងប្រទេសប៉ាគីស្ថានក៏ត្រូវបានតភ្ជាប់ជារឿយៗទៅនឹងយុទ្ធសាស្ត្រជំនួសនាំចូលដែលមានកំហុស។ ការបែងចែកជាពីរនេះ មិនមែនជាការធម្មតាទាំងអស់នោះទេ និងមានការពិចារណាពីគោលនយោបាយជាច្រើនផ្សេងទៀតដែលពាក់ព័ន្ធនឹងបទពិសោធន៍ប្រទេសនីមួយៗ។

***"ជំហានវិវត្តន៍សេដ្ឋកិច្ច "*** (ដូចជានៅឆ្នាំ ២០០៤-២០០៨) កម្ពុជាទំនងជាអាចដើរតាមយុទ្ធសាស្ត្រប្រទេសអាស៊ីខាងកើតនៃឧស្សាហូបនីយកម្មដែលផ្អែកលើការនាំចេញ និងពលកម្មខាងក្រោម។ ជាការពិតការកែទម្រង់សេរីភាវូបនីយកម្មដែលចាប់ផ្តើមនៅចុងទសវត្សរ៍ទី ៩០ និងរចនាសម្ព័ន្ធលើកទឹកចិត្តជាច្រើន

---

[55] Cf. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នឆ្នាំ ២០០៦-២០១១ និង ជួន ណារុន (2010), op cit

[56] មើល Edgren និង Muqtada (2010), op cit

[57] មើល ILO/ARTEP (១៩៨៣)

បើកចំហរនូវទស្សនីយភាពនៃយុទ្ធសាស្រ្តនោះ។ ជាការពិតចាប់តាំងពីពេលនោះមក កំណើនឧស្សាហកម្មមានការរីកចំរើនយ៉ាងខ្លាំង និងកើនឡើងជិតដល់១៤% នាពេលថ្មីៗនេះ ហើយចំណែកកំណើននៅក្នុងផលិតផលក្នុងស្រុកសរុបកើនឡើងពីតិចជាង១២% នៅឆ្នាំ១៩៩៣ រហូតដល់២៥% នៅឆ្នាំ ២០០៧។[58] អ្នកចូលរួមចំបងនៅក្នុងកំណើនឧស្សាហកម្មនេះ គឺវិស័យកាត់ដេរ និងវាយនភណ្ឌ។ ផលិតកម្មកាត់ដេរកើនឡើងនៅដំណាក់កាលមួយដ៏អស្ចារ្យ សហគ្រាសនៅក្នុងផ្នែកនេះកើនឡើងពីចំនួន៥៣ រហូតដល់៣៩៨ ហើយការនាំចេញកើនឡើងដល់2.8 កោដិដុល្លារអាមេរិក ក្នុងអំឡុងឆ្នាំ១៩៩៥ ដល់ឆ្នាំ ២០០៧។ ទាំងការងារគ្មានជំនាញ និងពាក់កណ្តាលជំនាញជាច្រើនក៏កើនឡើងជិត៣៥ ម៉ឺននាក់ ដែលភាគច្រើនជាស្រ្តី[59] (មើល រូបភាពទី ៥.៤)។

**រូបភាពទី ៥.៤៖ កំណើនមុខរបរ ការវិនិយោគ និងសហគ្រាសនៅក្នុងវិស័យឧស្សាហកម្មវាយនភណ្ឌក្នុងអំឡុងឆ្នាំ ១៩៩៥-២០០៣**




*ប្រភព៖ ហង់ ជួន ណារុន "សេដ្ឋកិច្ចកម្ពុជា៖ ការធ្វើផែនការណ៍សម្រាប់អនាគតប្រសើរជាងនេះ" ឆ្នាំ ២០០៩*

កំណើនវិស័យកាត់ដេរយ៉ាងឆាប់រហ័សនៅកម្ពុជា ជាលទ្ធផលនៃរចនាសម្ព័ន្ធលើកទឹកចិត្តល្អ ការកែទម្រង់សេរីភាវូបនីយកម្ម ព្រមទាំងការមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រទេសទទួលបានការអនុគ្រោះពន្ធ និងស្ថានភាពផលិតផលរដ្ឋសរុប ដែលផ្តល់ទៅឲ្យប្រទេសនេះដោយសហរដ្ឋអាមេរិកក្នុងអំឡុងទសវត្សទី ៩០។ យុទ្ធសាស្ត្រកំណើនឧស្សាហកម្មបានស្ថិតនៅក្រោមការពិនិត្យពិច័យយ៉ាងម៉ត់ចត់ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចសកលប៉ះពាល់ដល់វិស័យកាត់ដេរយ៉ាងខ្លាំងក្លា។ ហើយក៏ធ្លាប់មានការផ្តោតហួសហេតុទៅលើកញ្ចប់នាំចេញផលិតផល និងនៅក្នុងទីផ្សារនាំចេញ។ លើសពីនេះ កាលៈទេសៈអំណោយផល

---

[58] មើល ជួន ណារុន(២០១០), op cit

[59] NI

ដូចជាប្រទេសទទួលបានការអនុគ្រោះពន្ធ និងស្ថានភាពផលិតផលទុនសរុបលែងមានទៀតហើយ។ ដូច្នេះអ្នកវិភាគជាច្រើនបានចង្អុលបង្ហាញប្រាប់កម្ពុជាថា ដើម្បីក្រោកឡើងវិញ និងគាំទ្រឧស្សាហកម្មកាត់ដេរ មិនត្រូវផ្អែកលើការផ្តល់ឲ្យនិងការចូលចិត្តនោះទេ ប៉ុន្តែត្រូវពិនិត្យឡើងវិញនូវកត្តាជាច្រើនដែលអាចពង្រឹងផលិតភាព និងការប្រកួតប្រជែង។[60] ការសិក្សារបស់ធនាគារពិភពលោក ឬអង្គការអន្តរជាតិខាងការងារ បានផ្តោតទៅលើបញ្ហាមួយចំនួន និងបានសន្និដ្ឋានថា សហគ្រាសមួយចំនួននៅក្នុងឧស្សាហកម្មសំលៀកបំពាក់កម្ពុជាផលិតបានតិចតួច ហើយការប្រកួតប្រជែងនៅមានកម្រិត បើធៀបនឹងស្តង់ដារអន្តរជាតិ ហើយមូលហេតុចំបងនេះគឺបណ្តាលមកពីកង្វះការបណ្តុះបណ្តាល និងការប្រកួតប្រជែងខាងការគ្រប់គ្រងដែលសមស្រប។[61] នៅពេលដែលមានការក្រោកឡើងវិញ ការពង្រីកវិស័យកាត់ដេរ និងការបង្កើនការងារមានវិសាលភាពធំ អ្នកវិភាគជាច្រើនបានលើកជាសំណើថា ការពង្រីកវិស័យឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា និងការក្រោកឡើងវិញដែលមានចីរភាពអាចត្រូវការការពិនិត្យឡើងវិញច្រើនជាងមុនទៅលើឧស្សាហូបនីយកម្ម និងគោលនយោបាយទាំងមូល។ ឧស្សាហកម្មសំលៀកបំពាក់ដែលកើនឡើងតាមរយៈការប្រើគោលនយោបាយជ្រុល និងការផ្លាស់ប្តូរធនធាននៅក្នុងវិស័យនេះ អាចផ្តល់នូវមេរៀនសមស្រប និងមូលដ្ឋានពាណិជ្ជកម្មជាថ្មី និងគោលនយោបាយឧស្សាហូបនីយកម្ម។

យើងត្រូវទទួលស្គាល់ថាកំណើនយ៉ាងលឿននៃឧស្សាហកម្មកាត់ដេរបានផ្តល់នូវលទ្ធផលវិជ្ជមានជាច្រើនសម្រាប់សេដ្ឋកិច្ច ជាពិសេសសម្រាប់បង្កើតនូវឱកាសការងារផ្លូវការមួយចំនួនធំ ព្រមទាំងចំណូលរូបិយប័ណ្ណបរទេស។ នៅក្នុងដំណើរវិវត្តន៍នេះក៏មានចំណុចខ្សោយខ្លះដែរ ដែលអាចឃើញតាមរយៈឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចសកលលោក។ ហើយការកម្រិតមួយចំនួនត្រូវបានចង្អុលបង្ហាញដោយអ្នកវិភាគជាច្រើន។[62] យើងត្រូវរៀបចំឧស្សាហូបនីយកម្មដែលមើលឆ្ពោះទៅមុខ និងគោលនយោបាយពាណិជ្ជកម្មដែលមិនត្រឹមតែដោះស្រាយចំណុចទន់ខ្សោយទាំងនោះទេ ប៉ុន្តែត្រូវគាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងមូលដូចដែលមានប្រកាសនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។ នៅក្នុងបរិបទនេះ ការពិចារណាទៅលើគោលនយោបាយខាងក្រោមអាចជាការយកចិត្តទុកដាក់សមស្រប៖

១. នៅក្នុងកម្រិតគោលនយោបាយមានលក្ខណៈទូលាយ កម្ពុជាត្រូវគិតឡើងវិញពីយុទ្ធសាស្ត្រឧស្សាហូបនីយកម្មរបស់ខ្លួនក្នុងលក្ខខណ្ឌដែលបង្ហាញឲ្យឃើញយ៉ាងពិតប្រាកដ នូវអត្ថប្រយោជន៍ក្នុងការប្រកួតប្រជែង ព្រមទាំងតម្លៃ និងការបង្កើតកត្តាពាក់ព័ន្ធ។ ក្នុងបរិបទនេះការងារផ្អែកលើបច្ចេកវិទ្យា និងឧស្សាហូបនីយកម្មដែលអាស្រ័យលើការនាំចេញ អាចសន្មតបានថាត្រូវបន្តកំណត់ពីអត្ថប្រយោជន៍

[60] មើល ជាឧទាហរណ៍ Jalilian and Reyes (2010); ឈួន ណារុន (2010); WB/ILO (2010, mimeo);

[61] សម្រាប់ការពិនិត្យលម្អិតឡើងវិញ សូមមើល WB/ILO (mimeo) op cit និងមើល USAID (2005)

[62] Cf. Jalilian and Reyes (2010); UNDP (2010); USAID (2005)

ប្រកួតប្រជែងរបស់កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ មិនត្រូវបកស្រាយថាកម្មន្តសាលដែលមានពលកម្មខ្ពស់ជាការកម្រិតកំណើនឧស្សាហកម្មទៅជាទាបជាងមុន ដូចជាវិស័យកាត់ដេរដែលជាយូរមកហើយត្រូវបានកំណត់ដោយផលិតភាព និងប្រសិទ្ធភាពទាប។[63] នៅពេលដែលក្របខណ្ឌគោលនយោបាយនាពេលអនាគតត្រូវការ ការបញ្ជាក់ពីវិធានការលើកទឹកចិត្ត ប្រពលភាពការងារគួរមានច្រើនជាងមុននៅក្នុងផលិតកម្មឧស្សាហកម្ម ដូចជាការស្រូបការងារ ត្រូវមានការពិចារណាថាវិស័យនេះត្រូវពង្រឹងផលិតភាព និងការប្រកួតប្រជែងខាងជំនាញច្រើនជាងមុនដូចម្ដេចខ្លះ។

២. កត្តាចំបងដែលធ្វើអោយផលិតភាពទាប គឺកង្វះការបណ្ដុះបណ្ដាលសមរម្យ ការដឹកនាំដោយភាពជាសហគ្រិន និងជំនាញគ្រប់គ្រងនៅក្នុងវិស័យកាត់ដេរ។ ដោយឡែក កម្មករជំនាញនៅមានកម្រិតនៅឡើយ ហើយជំនាញគ្រប់គ្រងកម្រិតកណ្ដាលនៅក្នុងកន្លែងធ្វើការ បានមកពីជំនាញជនបរទេសនាំចូលមក។ ទាំងនេះបង្កើតជាសំណួរអំពីគោលគំនិតប្រៀបធៀបអត្ថប្រយោជន៍ និងថាតើការប្រើប្រាស់នេះបានយូរប៉ុនណា ជាពិសេសក្នុងលក្ខខណ្ឌសេដ្ឋកិច្ចទូលាយមួយ ដែលសហគ្រាសមានចំណូល និងជំនាញតិច។ លើសពីនោះ ចលនាការងារគ្មានជំនាញ នៅក្នុងសកម្មភាពកសិកម្ម ឬសកម្មភាពដែលគ្មានទម្រង់មិនមែនកសិកម្មនៅជនបទ ការងារដែលមានផលិតភាពតិច និងគ្មានជំនាញក្នុងវិស័យកម្មន្តសាលនឹងមិនអាចជួយអ្វីបានច្រើន ក្នុងការត្រួសត្រាយការផ្លាស់ប្ដូរជារចនាសម្ព័ន្ធនៅក្នុងសេដ្ឋកិច្ចឡើយ។ ការយកចិត្តទុកដាក់យ៉ាងសំខាន់ក្នុងការធ្វើឲ្យប្រសើរ និងការប្រើប្រាស់ជំនាញខ្ពស់ជាងអាចជួយសម្រួលដល់ការពង្រឹងអត្ថប្រយោជន៍ប្រកួតប្រជែងរបស់កម្ពុជា។

៣. ឧស្សាហកម្មកាត់ដេរមួយចំនួន បង្កើតឡើងតាមរយៈធនធាន និងការវិនិយោគទុនបរទេស។[64] ក្នុងខណៈពេលដែលការវិនិយោគនេះជាកាតាលីករ ជំរុញកំណើនក្នុងវិស័យនេះ ការវិនិយោគក្នុងស្រុក និងភាពជាសហគ្រិនហាក់ដូចជាដើរយឺតតាមពីក្រោយ។ ដូចគ្នានេះដែរ ប្រទេសដែលមានវិស័យកាត់ដេរនាំមុខដូចជានៅបង់ក្លាដេស មានកំណើនវិនិយោគឯកជនក្នុងស្រុក និងការប្រើជំនាញយ៉ាងច្រើនក្នុងវិស័យនេះ។ ដើម្បីកាត់បន្ថយការពឹងផ្អែកហួសហេតុលើវិនិយោគិនបរទេស និងអត្រាខ្ពស់នៃភាពងាយរងគ្រោះ ជាការចាំបាច់ត្រូវកសាងរចនាសម្ព័ន្ធលើកទឹកចិត្តដើម្បីគាំទ្រវិនិយោគទុនក្នុងស្រុក ទាំងវិស័យកាត់ដេរ និងគ្រប់អនុវិស័យដែលមានសក្ដានុពលផ្សេងទៀតនាពេលអនាគត។ ដូចច្នេះគួរតែមានការអភិវឌ្ឍន៍បរិយាកាសជាប្រព័ន្ធ និងវប្បធម៌នៃភាពជាសហគ្រិននៅក្នុងប្រទេស។ បន្ថែមពីនេះ រចនាសម្ព័ន្ធលើកទឹកចិត្តសម្រាប់វិនិយោគិនបរទេស និងក្នុងស្រុក ត្រូវការពិនិត្យឡើងវិញក្នុងក្របខណ្ឌមួយដ៏សមស្រប។

---

[63] មើល កត្តាពន្យល់លម្អិតនៅក្នុង Jalilian and Reyes (2010); UNDP (2010); WB/ILO (mimeo, 2010)

[64] សូមមើលយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣

៤. គួរមានការយកចិត្តទុកដាក់ជាពិសេសដើម្បីបង្កើនផលិតភាព និងសក្តានុពលការងារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។ ថ្មីៗនេះ សហគ្រាសខ្នាតតូច និងមធ្យមបានរួមចំណែក ៦៥% នៃផលិតផលក្នុងស្រុកសរុបកម្ពុជា និង ៨៥%នៃការងារក្នុងវិស័យឧស្សាហកម្ម។ សហគ្រាសខ្នាតតូច និងមធ្យមជាច្រើនដែលចាប់កើនឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ សម្រាប់គាំទ្រកំណើនឧស្សាហកម្មនៅក្នុងវិស័យវាយនភណ្ឌ សំណង់ និងសេវាកម្ម ត្រូវបានទទួលរងគ្រោះដោយសារវិបត្តិសេដ្ឋកិច្ចនាពេលថ្មីៗនេះ។ ដើម្បីកាត់បន្ថយផលវិបាក រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំគោលនយោបាយ និងការវិនិយោគសាធារណៈជាក់លាក់ ដូចជា បង្កើនភាពងាយស្រួលក្នុងការទទួលបានប្រាក់កំចី បង្កើនវគ្គបណ្តុះបណ្តាលជំនាញភាពជាសហគ្រិន និងពង្រឹងគុណភាពផលិតផល។

៥. យុទ្ធសាស្ត្រឧស្សាហូបនីយកម្មចាំបាច់ត្រូវតែមានមូលដ្ឋានទូលាយ ទោះបីជាត្រូវផ្អែកលើកម្លាំងពលកម្ម និងការនាំចេញក៏ដោយ។ នេះអាចកើតឡើងបាន ទោះបីប្រទេសត្រូវអនុវត្តតាមអភិក្រម "វិស័យនាំមុខ" មួយក៏ដោយ។ នេះមានន័យថាការអភិវឌ្ឍឧស្សាហកម្មត្រូវតែខុសប្លែកគ្នា ជាពិសេសដើម្បីជៀសវាងការពឹងផ្អែកលើឧស្សាហកម្មមួយ ឬពីរ ដូចដែលមានស្រាប់ថ្មីៗនេះ ដើម្បីទទួលបានចំណូលបានពីការនាំចេញចំបងៗ។ ជាធម្មតា *ការនាំចេញកម្មន្តសាលមិនអាចខុសគ្នាបានទេ លើកលែងតែការផលិតបែបឧស្សាហកម្មត្រូវបានធ្វើឲ្យខុសគ្នា។* លើសពីនេះ ជាប្រវត្តិសាស្ត្រ ការនាំចេញសំលៀកបំពាក់របស់កម្ពុជាមានទីផ្សារលើសលុបទៅកាន់ទិសដៅតែពីរ ឬបីប៉ុណ្ណោះ គឺទីផ្សារសហរដ្ឋអាមេរិក និងអឺរ៉ុប។ ទាំងនេះអាចជាការប្រថុយប្រថាន ដូចដែលបានឃើញស្រាប់នៅក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចពិភពលោកថ្មីៗនេះ ហេតុនេះ កម្ពុជាត្រូវការការស្រាវជ្រាវសម្រាប់ពិពិធកម្មទីផ្សារ។

**តារាងទី ៥.១ ៖ ទីផ្សារសំលៀកបំពាក់កម្ពុជា**

| Market | Value in 2007 (US$'000) | Share of total in 2007 (%) | Value in 2008 (US$'000) | Share of total in 2008 (%) |
|---|---|---|---|---|
| Total | 1,899 | 100 | 2,001 | 100 |
| USA | 1,359 | 72 | 1,405 | 70 |
| EU | 391 | 21 | 404.5 | 20 |
| Canada | 100.5 | 5 | 130.6 | 6.5 |
| Japan | 7 | 0.4 | 7.9 | 0.4 |
| Rest of world | 42.6 | 2 | 53.09 | 2.7 |

*Source: MoC*

៦. កម្ពុជាត្រូវតែប្រុងប្រៀប និង/ឬពង្រឹងស្ថាប័ន និងក្របខណ្ឌគតិយុត្តិពាក់ព័ន្ធឲ្យអនុលោមតាមអន្តរាគមន៍គោលនយោបាយ និងកម្មវិធី។ ទាំងនេះរួមមានតម្រូវការកំណែទម្រង់ហិរញ្ញវត្ថុ កំណែទម្រង់ពន្ធ និងយន្តការពាក់ព័ន្ធនឹងឧស្សាហកម្ម ដើម្បីសម្រួលការអនុវត្តឲ្យបានរលូនជាងមុននៅក្នុងវិស័យ

ឧស្សាហកម្ម និងដើម្បីធានាពីសិទ្ធិចំបងៗនៅកន្លែងធ្វើការ។ ត្រូវកត់ចំណាំថា ការវិនិយោគទុនបរទេស ឬក្នុងស្រុកកើនឡើង និងស្ថិតស្ថេរ មិនត្រឹមតែលើសិទ្ធិចំបងធំៗទេ ប៉ុន្តែក៏ទៅលើវិធីអនុវត្តសន្តិឧស្សាហកម្ម។

ដូចដែលបានរៀបរាប់ខាងលើ អ្នករៀបចំគោលនយោបាយកម្ពុជាកំពុងតែបង្ហាញការកើនឡើងនៃការដឹងឮពីតម្រូវការសម្រាប់ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន ដែលបង្ហាញនូវភាពងាយរងគ្រោះនៃសេដ្ឋកិច្ចដែលបានអង្កេត និងការពឹងផ្អែកលើពិភពខាងក្រៅសម្រាប់ទីផ្សារ និងការវិនិយោគដែលនាំឲ្យមានដំណើរឧស្សាហូបនីយកម្មបច្ចុប្បន្ន។តម្រូវការភ្ជាប់អាទិភាពខ្ពស់ទៅនឹងការកាត់បន្ថយភាពក្រីក្រ តម្រូវការបង្កើតការប្រកួតប្រជែងជំនាញសេដ្ឋកិច្ច និងស្វែងរកការភ្ជាប់ច្រើនជាងនេះ រវាងវិស័យកសិកម្ម ឧស្សាហកម្ម និងនាំចេញ ត្រូវបានឃើញយ៉ាងជាក់ច្បាស់ជាបណ្តើរៗ។ សកម្មភាពស្នើឡើង និង/ឬ ចាប់ផ្តើមខាងក្រោម បកស្រាយអំពីការប្រែប្រួលគំរូអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា។[65]

- ការយកចិត្តទុកច្រើនជាងនេះបានត្រូវកំពុងតែរៀបចំសម្រាប់អភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ហើយការត្រួតពិនិត្យឡើងវិញកំពុងតែអនុវត្ត ដើម្បីកាត់បន្ថយផលសម្រាប់ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ជាពិសេសឆ្ពោះទៅរកផលទុន និងហិរញ្ញវត្ថុ ព្រមទាំងការអភិវឌ្ឍន៍សហគ្រិន ជំនាញ និងបង្កើនគុណភាពផលិតផលតាមរយៈបច្ចេក វិទ្យាសមស្រប[66]

- ក្នុងការធ្វើកំណែទម្រង់ដើម្បីទាក់ទាញការវិនិយោគបរទេស ដូចជាលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ វិធានការត្រូវបានបង្ហាញយ៉ាងច្បាស់សម្រាប់ជំរុញធុរកិច្ចធំៗ និងគាំទ្រសកម្មភាពពាក់ព័ន្ធរបស់សហគ្រាសខ្នាតតូច និងមធ្យម

- ជាផ្នែកនៃដំណើរវិមជ្ឈការ ស្វ័យភាពថ្នាក់ខេត្តច្រើនជាងមុនត្រូវបានគេប្រមើមើលជាមុនថាជំរុញវិនិយោគមូលដ្ឋាន និងធ្វើឃោធូបនីយកម្មធនធាន

- ជំហានជាច្រើនត្រូវបានបង្កើតឡើងដើម្បីដោះស្រាយស្ថានភាពដែលមិនសមហេតុផល ក្នុងនោះ ធនាគារជាច្រើនមានប្រាក់ដំកល់លើសចំនួន ខណៈពេលដែលសហគ្រាសខ្នាតតូច និងមធ្យម និងមីក្រូហិរញ្ញវត្ថុមានផលលំបាកដោយកង្វះទ្រព្យសកម្ម។ យុទ្ធសាស្ត្រ "គ្មានដាក់ទ្រព្យធានា" សម្រាប់បំណុលតូចៗ និងរបស់ MFI ត្រូវបានប្រមើមើលទុកជាមុន។

---

[65] មើល *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នឆ្នាំកម្ម 2009-2013*

[66] នៅក្នុងវេទិកាសន្និដ្ឋានថ្មីៗមួយអំពីមីក្រូហិរញ្ញវត្ថុ សហគ្រាសខ្នាតតូច និងមធ្យម និងការបង្កើតការងារ ដែលមានសហគ្រាសខ្នាតតូច និងមធ្យម ប្រហែល ៤០០ និងធនាគារមួយចំនួនចូលរួម ដើម្បីកត់សម្គាល់ពីផលលំបាកចំបងៗនៃការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម និងដើម្បីរកវិធីដោះស្រាយ។

ដូចករណីខាងលើនេះ វិធានការគោលនយោបាយមីក្រូហិរញ្ញវត្ថុតអាចនឹងជំរុញសហគ្រាសខ្នាតតូច និងមធ្យម និងជ្រួមជ្រែងវិនិយោគទុន និងការអភិវឌ្ឍន៍របស់សហគ្រិនក្នុងស្រុក។ ទាំងនេះអាចជួយបង្កើតនការងារ និងចំណូល ទាំងនៅទីក្រុង និងតាមបណ្តាខេត្តផងដែរ។

## មុខរបរនៅក្នុងវិស័យផ្សេងៗ៖ សំណង់ និងសេវាកម្ម

រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់លើវិស័យសំណង់ ជាពិសេសក្នុងដំណាក់កាលស្តារនីតិសម្បទានិងកសាងសេដ្ឋកិច្ចប្រសើរឡើងវិញ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច និងបង្កើនការងារ។ជាប្រវត្តិសាស្ត្រ វិស័យសំណង់ត្រូវបានឃើញថាជាវិស័យនាំមុខនៅដំណាក់កាលសេដ្ឋកិច្ចដំបូងសម្រាប់ទប់ទល់នឹងភាពអត់ការងារធ្វើយ៉ាងច្រើននាពេលនោះ។ សក្តានុពលនៃវិស័យនេះកើតឡើងពីលទ្ធភាពក្នុងការស្រូបយកកម្លាំងពលកម្មយ៉ាងច្រើន និងត្រូវការវត្ថុធាតុដើមនាំចូលតិចតួច ក៏ដូចជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងកាលពីមុន និងពេលអនាគតនៃវិស័យនេះ។[67] នៅក្នុងបរិបទនេះ វិស័យឧស្សាហកម្មភាគច្រើន ដូចជាវិស័យសំណង់ត្រូវបានកំណត់ដោយ "ទ្វិកនិយម" ជាមួយនឹងបច្ចេកវិទ្យាទំនើប និងបែបបុរាណ (និងការប្រើប្រាស់កម្លាំងពលកម្មមានជំនាញ) សម្រាប់កំណត់ពីទ្វិកនិយម។ ជាទូទៅ វិស័យសំណង់ ត្រូវបានស្គាល់ថាជាវិស័យមានសក្តានុពលស្រូបកម្លាំងពលកម្មច្រើនជាងវិស័យឧស្សាហកម្មបន្ទាប់បន្សំដទៃទៀត។

នៅកម្ពុជា វិស័យសំណង់កើនឡើងយ៉ាងលឿន ជាមធ្យមប្រហែល១៣% ចន្លោះឆ្នាំ១៩៩៤-២០០៧ ហើយឡើងរហូតដល់២០% ក្នុងពេលរីកចម្រើនឆាប់រហ័សចន្លោះឆ្នាំ២០០២-២០០៧ ទាំងកំណើនហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់លំនៅដ្ឋាន ជាពិសេសជុំវិញទីក្រុងភ្នំពេញ និងខេត្តសៀមរាប។[68]

ប៉ុន្តែការកើនឡើងនៃវិស័យនេះថយចុះគួរឲ្យកត់សម្គាល់ តាំងពីឆ្នាំ២០០៨ដោយសារតែវិបត្តិសេដ្ឋកិច្ចសកល។ ដោយអង្កេតជាប្រវត្តិសាស្ត្រឃើញថា ការរីកចម្រើនយ៉ាងរហ័សនៃវិស័យសំណង់ទំនងជាបញ្ចប់ និងថយចុះយ៉ាងរហ័ស ដោយបន្សល់នូវផលវិបាកមិនអំណោយផលលើកម្រិតការងារ។

រហូតមកដល់ការធ្លាក់ចុះសេដ្ឋកិច្ចនាឆ្នាំ ២០០៨ វិស័យសំណង់ដើរតួយ៉ាងសំខាន់ក្នុងកំណើនផលិតផលក្នុងស្រុកសរុប របស់កម្ពុជា។ ផលិតភាពការងារកើនឡើងច្រើនជាង៣% នាទសវត្សរ៍ចុងក្រោយ។[69]ប្រាក់ឈ្នួលកើនឡើងយ៉ាងខ្លាំង ទាំងកម្មករមានជំនាញ និងគ្មានជំនាញ(មើលតារាងទី៥.២)

---

[67] Cf. Edgren and Muqtada (1990)

[68] មើល ជួន ណារុន (2010) ទំព័រទី ៦១

[69] NIS (2010), op cit

ដែលបង្ហាញពីការកើនឡើងដាច់ខាតនៃកម្មករសំណង់តាមក្រុមអាយុ។ យើងអាចកត់ចំណាំបានថាទោះបីជាកម្មករស្ត្រីមានចំនួនស្ទើរតែទ្វេដងក្នុងរយៈពេល១០ឆ្នាំនេះ តែមានស្ត្រីត្រឹមតែ១៣% នៅក្នុងវិស័យនេះ។ ទោះជាយ៉ាងណាក៏ដោយ ការងារជាសរុបនៅក្នុងវិស័យនេះកើនឡើងគួរឲ្យកត់សម្គាល់។

**តារាងទី ៥.២៖ ការងារនៅក្នុងវិស័យសំណង់ (១៩៩៨-២០០៨) បែងចែកតាមក្រុមអាយុ**

| ក្រុមអាយុ | 1998 | 2008 |
|---|---|---|
| 15+ | 44,946 | 140,104 |
| 15 - 24 | 11,579 | 50,438 |
| 24+ | 33,367 | 89,666 |

*ប្រភព៖ ការងារ NIS និងនិន្នាការសេដ្ឋកិច្ច ឆ្នាំ 2010 (ឧបសម្ព័ន្ធ)*

ភាពមិនខ្ជាប់ខ្ជួនរយៈពេលខ្លីនៃកំណើន និងការងារ ក្នុងវិស័យសំណង់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងដំណើរការសេដ្ឋកិច្ច ដូចជាការរីកចម្រើន និងការធ្លាក់ចុះនៃសេដ្ឋកិច្ច និងវិស័យផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ វិស័យទាំងនេះបានផ្តល់នូវសក្តានុពលបង្កើតការងារ ដែលនេះជាបញ្ហាសំខាន់ក្នុងការស្វែងរក ការពង្រឹង ការស្រូបកម្លាំងពលកម្មតាមរយៈវិធានការនានាដែលអាចទទួលបាននូវស្ថេរភាពស្ថិតស្ថេរខ្លះក្នុងវិស័យនេះ។ ដើម្បីទទួលបានការអនុញ្ញាតកិច្ចអន្តរាគមន៍ពីវិស័យសាធារណៈប្រហែលជាអាចជួយណែនាំពីកម្មវិធីហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសនៅតាមទីជនបទដែលកម្លាំងការងារមានការលំបាក ដោយសារភាពមិនរីកចម្រើនទៅមុខ និងទទួលបានចំណូលតិចតួច។

ដូចគ្នានេះដែរ ការលើកទឹកចិត្តអាចជាការជំរុញវិនិយោទុនឯកជនតាមរយៈការពិនិត្យឡើងវិញនូវការនាំចូល និងទិន្នផលដែលមានតម្លៃថ្លៃ ដោយហេតុថាតម្លៃទិន្នផលនៅក្នុងវិស័យនេះកើនឡើងគួរឲ្យកត់សម្គាល់។ ក្នុងលក្ខខណ្ឌធម្មតា រាជរដ្ឋាភិបាលត្រូវតែពិនិត្យឡើងវិញនូវកំណើន និងសក្តានុពលការងារក្នុងវិស័យនេះ និងបង្កើនសមត្ថភាពមូលដ្ឋានសម្រាប់ផលិតកម្មវត្ថុធាតុដើម និងទិន្នផល។[70] បន្ថែមពីនេះ ដូចដែលបានអង្កេតនៅក្នុងប្រទេសអាស៊ីមួយចំនួន គោលនយោបាយក្នុងស្រុកចំណាយតិចរយៈពេលវែងអាចត្រូវបានបង្កើតឡើង ដែលមានឥទ្ធិពល "ស្ថេរ" ភ្ជាប់មកស្រាប់លើវិស័យនេះក្នុងការធ្វើឲ្យការងារមាននិរន្តភាពក្នុងសេដ្ឋកិច្ច។

[70] Cf. UNDP (2009)

## មុខរបរក្នុងវិស័យសេវាកម្ម

វិស័យសេវាកម្មនៅកម្ពុជាមានប្រហែល២/៥ នៃផលិតផលក្នុងស្រុកសរុប និងប្រហែល២០% នៃពលកម្មការងារសរុប។ ដូចនេះមិនមានការទាក់ទងគ្នារវាងចំណែកវិស័យនេះនៅក្នុងផលិតផលក្នុងស្រុកសរុប និងចំណែកនៅក្នុងការងារ ដែលសំដៅលើផលិតភាពទាបជាសរុបនៅក្នុងវិស័យនេះទេ។ កំណើនការងារមានសភាពយឺតជាងកំណើនតម្លៃបន្ថែមនៃវិស័យនេះ។ ជារួម វិស័យនេះកើនឡើងជិត ៨.៦% ចន្លោះឆ្នាំ ១៩៩៤-២០០៧ កំណើនភាគច្រើនបានមកពីការរីកចម្រើននៃសណ្ឋាគារ និងទេសចរណ៍ ការដឹកជញ្ជូន និងការទំនាក់ទំនង ធនាគារ សេវាកម្មហិរញ្ញវត្ថុ និងអចលនវត្ថុ។[71]

ជាធម្មតាទំហំការងារនៃវិស័យសេវាកម្មនៅក្នុងប្រទេសភាគច្រើន មានចំនួនច្រើន ពេលខ្លះច្រើនជាងពីរដងបើប្រៀបទៅនឹងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការងារក្នុងវិស័យនេះភាគច្រើនត្រូវបានកំណត់ដោយការងារខ្លួនឯង ដូចជានៅក្នុងពាណិជ្ជកម្មមិនផ្លូវការ និងសេវាកម្មលក់រាយ។ ការរីកសាយនៃការងារមិនផ្លូវការទាំងនេះនៅក្នុងវិស័យទីបី ជាធម្មតាត្រូវបានបកស្រាយថាជាការឆ្លុះបញ្ចាំងពីកង្វះឱកាសការងារនៅក្នុងវិស័យកម្មន្តសាល និងវិស័យសេវាកម្មទំនើប។[72] នៅក្នុងវិស័យទី ៣ របស់កម្ពុជាស្ថិតនៅក្នុងករណីបង្កើតការងារសមរម្យនៅក្នុងវិស័យសណ្ឋាគារ និងទេសចរណ៍។ កំណើនទេសចរណ៍កើតឡើងយ៉ាងពិសេសចាប់តាំងពីឆ្នាំ ២០០៣។ (មើលរូបភាពទី ៥.៥)

**រូបភាពទី ៥.៥៖ ការវិនិយោគលើសណ្ឋាគារ និងភោជនីយដ្ឋាន (គិតជាលានលុយដុល្លារសហរដ្ឋអាមេរិក)**




*ប្រភព៖ ហង់ ជួនណារុន "សេដ្ឋកិច្ចកម្ពុជា៖ ការធ្វើផែនការណ៍សម្រាប់អនាគតប្រសើរជាងនេះ" 2009*

---

[71] មើល ជួន ណារុន (2010); Morris (2005)

[72] Edgren and Muqtada (1990), op cit

ឧស្សាហកម្មទេសចរណ៍ និងសណ្ឋាគាររងគ្រោះយ៉ាងធ្ងន់ធ្ងរក្នុងពេលវិបត្តិថ្មីៗនេះ និងធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងត្រីមាសទី៣ចុងក្រោយក្នុងឆ្នាំ ២០០៨។[73] ដូចនេះ អនុវិស័យទីបីនេះ បង្ហាញពីការបាត់បង់ការងារ និងធ្វើឲ្យដុនដាបលក្ខខណ្ឌការងារ ដូចជាប្រាក់ឈ្នួល និងទំនាក់ទំនងនៅកន្លែងធ្វើការមានការថយចុះ។

នាពេលអនាគត សក្តានុពលបង្កើតការងារនៅក្នុងវិស័យសេវាកម្មនឹងពឹងផ្អែកយ៉ាងខ្លាំងលើកំណើនទាំងស្រុងនៅក្នុងវិស័យផ្សេងទៀត ក៏ដូចជាគោលនយោបាយ និងការគាំទ្រសាធារណៈលើការអភិវឌ្ឍន៍ និងពិពិធកម្មវិស័យ។ ឧទាហរណ៍ដូចជា សណ្ឋាគារ និងទេសចរណ៍នឹងនៅតែជាអ្នកចូលរួមឈានមុខដល់ផលិតផលក្នុងស្រុកសរុប និងមុខរបរ ប៉ុន្តែពួកគេត្រូវការការជំរុញ ការលើកទឹកចិត្ត និងធនធានជាច្រើនទៀតដើម្បីលើកកម្ពស់ការអនុវត្តឲ្យរួចផុតពីភាពងាយរងគ្រោះ និងការគម្រាមកំហែងពីវិបត្តិ និងពីបរិបទខាងក្រៅ។

ពាក់ព័ន្ធនឹងវិស័យសេវាកម្មមិនផ្លូវការ ទំហំការងារនៅមានចំនួនតិចតួច ហើយសក្តានុពលការងារមានផលិតភាព ស្ថិតនៅក្នុងពាណិជ្ជកម្ម ការដឹកជញ្ជូន ជួសជុល និងអាជីវកម្មលក់រាយ។ ទាំងនេះជាសកម្មភាពសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច និងអាចនាំឲ្យផលិតកម្ម និងចំណូលមានទិន្នផលភាគទុនក្នុងមនុស្សធ្វើការម្នាក់ៗកើនឡើង។ ដើម្បីពង្រឹងផលិតភាពនៅក្នុងវិស័យនេះ វគ្គបណ្តុះបណ្តាល ការទទួលបានឥណទាន និងបច្ចេកវិទ្យាសមស្រប ហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រ និងជំនួនបច្ចេកទេសគួរត្រូវយកមកពិចារណា។

## ៦. គោលនយោបាយទីផ្សារការងារ៖ បញ្ហាមួយចំនួន

វិស័យពីរខាងលើបានសិក្សាពីបញ្ហាគោលនយោបាយជាច្រើនពាក់ព័ន្ធនឹងការបង្កើនតម្រូវការ ការងារនៅក្នុងសេដ្ឋកិច្ច។ ក៏ប៉ុន្តែ ការអនុវត្តការងារពឹងផ្អែកមិនត្រឹមតែទៅលើការបង្កើនតម្រូវការការងារទាំងនោះទេ តែក៏ពឹងផ្អែកថាតើការងារ និងជំនាញអាចផ្គត់ផ្គង់បានកំរិតណា ព្រមទាំងការផ្លាស់ប្តូតម្រូវការផ្គត់ផ្គង់ ត្រូវបានសម្របសម្រួលបានប៉ុណ្ណាដោយគ្មានការប៉ះទង្គិចគ្នា។ បញ្ហាភាគច្រើនត្រូវបានដោះស្រាយតាមរយៈគោលនយោបាយទីផ្សារការងារដែលបានបញ្ជាក់យ៉ាងច្បាស់ ចាត់ថ្នាក់ពីជំនាញក្របខណ្ឌច្បាប់ការងារ ការអភិវឌ្ឍន៍ និងភាពមានការងារ រហូតដល់អន្តរាគមន៍សាធារណៈដាក់លាក់ដើម្បីលើកកម្ពស់ការងារ។

---

[73] CDRI (2010)

## ភាពមានការងារ និងការអភិវឌ្ឍជំនាញ

ដូចប្រទេសកំពុងអភិវឌ្ឍដទៃទៀតដែរ កម្ពុជាជួបប្រទះនូវផលលំបាកមួយចំនួនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមដែលសមស្របមួយ ហើយផលលំបាកដែលសំខាន់ជាងគេនោះគឺជំនាញនៃកម្លាំងពលកម្ម។ ដោយពុំទាន់មានផែនការជំនាញលំអិត និងទិន្នន័យសមស្រប ជាការលំបាកក្នុងការធ្វើសេចក្តីវិនិច្ឆ័យគោលនយោបាយទៅលើវិសាលភាព និងទិសដៅអភិវឌ្ឍន៍ជំនាញ ដែលត្រូវការសម្រាប់ធានាភាពមានការងារធ្វើ។

មានការសិក្សាមួយចំនួនពាក់ព័ន្ធជាមួយនឹងទិដ្ឋភាពជំនាញជាច្រើន ប៉ុន្តែជាទូទៅពាក់ព័ន្ធនឹងទិដ្ឋភាពនៃជំនាញ[74] ដែលចំណុចខ្លះពាក់ព័ន្ធតែនឹងក្រុមមួយចំនួនជាក់លាក់ (ដូចជាយុវជន ស្ត្រី)[75] ខ្លះឆ្លុះ បញ្ចាំងពីការប្រើជំនាញនិងតម្រូវការតាមវិស័យ។[76] តាមរយៈកម្មវិធី STVET[77] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងព្យាយាមវាយតម្លៃពីតម្រូវការវគ្គបណ្តុះបណ្តាលមិនផ្លូវការនៅតាមខេត្តយ៉ាងតិចចំនួន៧ និងសម្រាប់ពាណិជ្ជកម្មដែលបានជ្រើសរើសនៅក្នុងវិស័យផ្លូវការ (ជាពិសេសវិស័យសំណង់ គ្រឿងយន្ត/អ្នកបច្ចេកទេស ព័ត៌មានវិទ្យា និងទេសចរណ៍)។

ទោះបីជាផែនការជំនាញហាក់មិនដូចជាជិតបានលំអិត តែមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការងារ មួយចំនួននៅក្នុងប្រទេស មិនទាន់មានជំនាញច្បាស់លាស់ទេ ដូចជាការចុះឈ្មោះចូលរៀន និងការត្រលប់ចូលសាលាវិញនៅមានកំរិតទាប ជំនាញដែលបានផ្តត់ផ្គង់ ហាក់មិនទាន់ស៊ីសង្វាក់នឹងតម្រូវការក្នុងវិស័យផ្សេងៗគ្នា ស្ថានភាពតំរូវការជំនាញមានលក្ខណៈដោយឡែកក្នុងចំណោមយុវជន និងស្ត្រី។ ការសិក្សារបស់ធនាគារពិភពលោកសន្និដ្ឋានថាជិត "៦៣%នៃយុវជនខ្មែរបានបោះបង់ចោលការសិក្សា មុនពេលបញ្ចប់ការសិក្សា ក្នុងនោះ១២% មិនដែលបានចូលរៀនទេ"។[78]

តែទោះជាយ៉ាងណាក្តី គួរឲ្យកត់សម្គាល់ដែលថាក្រៅពីចំណុចខ្សោយខាងលើ ការអភិវឌ្ឍន៍ធនធានមនុស្ស នៅមានការវិវត្តជាបណ្តើរៗជាពិសេសនៅក្នុងការអប់រំ (ចំណាំ៖ ការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា)ក៏ដូចជាកំណើននៃអ្នកផ្តល់វគ្គបណ្តុះបណ្តាលជាផ្លូវការ និងមិនផ្លូវការ។ ចំនួនសិស្សបញ្ចប់ការសិក្សាកើនឡើងក្នុងអំឡុង ១៥ឆ្នាំចុងក្រោយនេះ ហើយសិស្សដែលបញ្ចប់ការសិក្សាក៏ប្រឈមនឹងភាពគ្មានការងារច្រើនផងដែរ ភាគច្រើនគឺការមិនស៊ីគ្នារវាងជំនាញរបស់សិស្សបញ្ចប់ការសិក្សា និងតម្រូវការ

---

[74] មើល ធនាគារពិភពលោក, ជាឧទាហរណ៍៖ កម្ពុជា- ការផ្តល់ជំនាញដើម្បីសមភាព និងកំណើន, 2010

[75] Cf, ILO (2007), ការសង្ខេបពីគោលនយោបាយស្តីពីការវាយតម្លៃពីជំនាញនៅក្នុងវិស័យកាត់ដេរ និងសេដ្ឋកិច្ចផ្លូវការផ្សេងទៀត

[76] AFD បានបង្កើតការសិក្សាមូលដ្ឋានអំពីការវាយតម្លៃពីជំនាញនៅក្នុងវិស័យកាត់ដេរ និងវិស័យផ្លូវការដទៃទៀត

[77] នេះជាកម្មវិធីចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា គាំទ្រដោយ ADB

[78] WB (2010), op cit

ខាងជំនាញរបស់និយោជក។ ការស្រង់មតិតាមវិស័យបានបង្ហាញនូវក្តីបារម្ភរបស់និយោជក ដូចនៅក្នុងរូបភាពខាងក្រោមដោយផ្អែកលើ។

**រូបភាពទី ៦.១៖ ភាគរយក្រុមហ៊ុនដែលកត់សម្គាល់ឃើញថា ជំនាញមិនស៊ីនឹងតម្រូវការរបស់និយោជក និងសំណើរបស់វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ**




*ប្រភព៖ ធនាគារពិភពលោក*

ដើម្បីពង្រឹងជំនាញ និងបង្វែរកម្លាំងពលកម្មដែលគ្មានជំនាញភាគច្រើន ឲ្យទៅជាទ្រព្យដ៏មានប្រយោជន៍ដែលអាចប្រកួតប្រជែងខាងជំនាញក្នុងទីផ្សារអន្តរជាតិបាន កម្ពុជាត្រូវខិតខំយកចិត្តទុកដាក់បំផុតចំពោះការអភិវឌ្ឍធនធានមនុស្ស។ ដោយធនធាននៅមានកម្រិត នោះអាចនឹងមានភាពប្រឫកប្របល់ និងកិច្ចពិភាក្សាពីវិធីលើកកំពស់ធនធានមនុស្ស និងប្រយោជន៍ខាងតម្លៃ ពាក់ព័ន្ធនៃកម្មវិធីផ្សេងៗ។ ឧទាហរណ៍ដូចជា ត្រូវមានការពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្នពីធនធានរបស់រាជរដ្ឋាភិបាល និងគោលនយោបាយ ព្រមទាំងការលើកទឹកចិត្តដែលសង្កត់ធ្ងន់លើតម្រូវការទីផ្សារការងារ និងការរំពឹងទុករបស់យុវជនអំពីអនាគតទីផ្សារការងារ។ ការរំពឹងទុកនេះនឹងផ្អែកលើការផ្គត់ផ្គង់ជំនាញ និងពិពិដកម្មដែលត្រូវការច្រើនសម្រាប់សេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត ការផ្គត់ផ្គង់ និងតម្រូវការសម្រាប់វិសាលភាពទូលាយនៃការផ្លាស់ប្តូររចនាសម្ព័ន្ធដែលទំនងអាចជាចំណូល និងរចនាសម្ព័ន្ធលើកទឹកចិត្តដែលពាក់ព័ន្ធនឹងការគាំទ្រយោធូបនីយកម្មការងារ។[79]

ក្នុងស្ថានភាពផ្គត់ផ្គង់ និងតម្រូវការជំនាញបច្ចុប្បន្ន បង្ហាញឲ្យឃើញថាអត្រាយុវជនអត់ការងារធ្វើមានកំរិតខ្ពស់ក្នុងចំណោមសិស្សបញ្ចប់ការសិក្សា និងនិស្សិតបញ្ចប់មហាវិទ្យាល័យ (នឹងតំរង់ទិសសិល្បៈ

[79] មើល Godfrey et al. (2010), op cit

សេរី) ខណៈពេលដែលការផ្គត់ផ្គង់ជំនាញបែបបច្ចេកទេស និងវិជ្ជាជីវៈមិនទាន់គ្រប់គ្រាន់។ ដូចគ្នានឹងស្ថានភាពនេះដែរ តាមរយៈក្រសួងការងារ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើកម្មវិធីរួមគ្នាមួយដើម្បីពង្រឹងជំនាញបច្ចេកទេស និងវិជ្ជាជីវៈទាំងនោះតាមផ្នែកជាច្រើន ទាំងនៅទីក្រុង និងនៅជនបទ។ ជាការពិតណាស់ ការបណ្តុះបណ្តាលទាំងនោះត្រូវបានពង្រីកតាមមូលដ្ឋាន ២ យ៉ាងគឺៈ សម្រាប់វិស័យផ្លូវការ និងក្រៅផ្លូវការ។ នៅតាមជនបទ គឺបានផ្តោតទៅលើតម្រូវការជំនាញការងារកសិកម្ម (ធ្វើស្រែ) និងមិនមែនកសិកម្ម (ជួសជុល) ដោយសង្កត់ធ្ងន់ទៅលើការកើនឡើងផលិតភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងទៅលើការធ្វើចំការជាលក្ខណៈពាណិជ្ជកម្មផ្សេងៗ។ ការចូលរួមរបស់ស្ត្រីត្រូវបានលើកកម្ពស់ ទោះបីជាសកម្មភាពរួមគ្នាតម្រូវឲ្យឃ្លាតចេញពីវប្បធម៌ និងរបាំងផ្សេងទៀត ដើម្បីទាញពួកគេចេញពីការងារក្នុងផ្ទះដែលមិនទទួលបានប្រាក់កំរៃ។

នៅពេលដែលវិធាននានាត្រូវបានដាក់ចេញដើម្បីដោះស្រាយភាពមិនស៊ីគ្នានៃជំនាញតាមរយៈការផ្គត់ផ្គង់ (ធនធាន កម្មវិធី និងការលើកទឹកចិត្ត) និងតម្រូវការ (ការកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ) តម្រូវឲ្យមានការយកចិត្តទុកដាក់រួមលើកម្ពុជានីយកម្មនៃជំនាញក្នុងទីផ្សារការងារនៃវិស័យផ្លូវការ ដែលមានស្រាប់។ ថ្មីៗនេះ កម្មករដែលមានជំនាញកម្រិតមធ្យម និងជំនាញគ្រប់គ្រងត្រូវបានបម្រើការងារក្នុងឧស្សាហកម្មផ្នែកផ្លូវការ ដូចជាកាត់ដេរ សំណង់ សណ្ឋាគារ និងទេសចរណ៍។ ការអភិវឌ្ឍជំនាញទាំងនោះត្រូវការ ការយកចិត្តទុកដាក់ជាបន្ទាន់។ ការអភិវឌ្ឍសហគ្រិននិងការកើនឡើងនូវលទ្ធភាពគ្រប់គ្រងកំរិតខ្ពស់របស់សហគ្រិនតូចៗ (បុរស និងស្ត្រី) ហើយការកើនឡើងនៃភ្នាក់ងារបណ្តុះបណ្តាលរបស់រដ្ឋ និងឯកជនអាចចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រីកសក្តានុពលការងារនៃសហគ្រាសខ្នាតតូច និងមធ្យម។

## ទេសន្តប្រវេសន៍ការងារ

ទេសន្តប្រវេសន៍ការងារអន្តរជាតិដែលជាវិធីលើកកម្ពស់ការងារ មិនទាន់ជាឧបករណ៍ចំបងក្នុងក្របខណ្ឌរៀបចំផែនការអភិវឌ្ឍន៍របស់កម្ពុជានៅឡើយទេ។ កម្ពុជាក៏ជាប្រទេសដែលបញ្ជូនពលករទៅក្រៅប្រទេសព្រមទាំងទទួលពលករចូលក្នុងស្រុកផងដែរ (ឧទាហរណ៍ដូចជាពីប្រទេសវៀតណាម)។ មិនដូចប្រទេសនៅអាស៊ីមួយចំនួន ដែលនាំចេញការងារផ្សេង (ដូចជាហ្វីលីពីន ប៉ាគីស្ថាន) កម្ពុជាទើបតែបង្កើតសេចក្តីណែនាំគោលនយោបាយថ្នាក់ជាតិអំពីទេសន្តប្រវេសន៍ទៅបរទេស។[80] ព័ត៌មាន និងស្ថិតិអំពីពលករចេញទៅក្រៅប្រទេសនៅមិនទាន់មានច្បាស់ និងទើបតែចាប់ផ្តើមចងក្រងជាបណ្តើរៗ។ យន្តការ

[80] មើលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ/ILO, គោលនយោបាស្តីពីអន្តោប្រវេសន៍ការងារសម្រាប់កម្ពុជា 2010

សម្រាប់ស្ថាប័នអភិបាលកិច្ចទេសន្តប្រវេសន៍ដែលមានស្រាប់នៅក្នុងប្រទេសដែលនាំចេញការងារនៅអាស៊ីជាច្រើន មានការពាក់ព័ន្ធ ប្រសិនបើកម្ពុជាបន្តកម្មវិធីបញ្ជូនពលករទៅក្រៅប្រទេស។

ចំនួនពលករទេសន្តប្រវេសន៍នៅតែមិនច្បាស់លាស់ ដោយសារតែការធ្វើអន្តោប្រវេសន៍របស់កម្ពុជាជាច្រើនគឺទៅប្រទេសថៃ។ តាមរយៈអនុសារណៈយោគយល់គ្នារវាងប្រទេសថៃ និងកម្ពុជា ពលករប្រហែលជា ១១ម៉ឺននាក់ទទួលបានការងារធ្វើ ទោះបីជាចំនួនជាផ្លូវការដែលចុះបញ្ជីពលករទេសន្តប្រវេសន៍នៅប្រទេសថៃបានបង្ហាញថាមានចំនួនត្រឹមតែ ៨២៣១នាក់ក៏ដោយ។[81] វាហាក់ដូចជាចលនាមនុស្សមានជារូបរាងចំនួនច្រើន ជាពិសេសយុវជន រាប់ចាប់ពីជនក្រីក្រ និងគ្រួសារ និងតំបន់ដែលងាយរងគ្រោះ[82] ដែលមានបំណងឆ្លងដែនដើម្បីគេចចេញពីភាពក្រីក្រ។ ថ្មីៗនេះ ក៏មានទំនោរកើនឡើងសម្រាប់ប្រជាជនខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងកូរ៉េខាងត្បូងផងដែរ។ ទោះបីជាចំនួនពិតប្រាកដនៃពលករពិបាកនឹងកំណត់បាន ប៉ុន្តែស្ថិតិដែលគួរទុកចិត្តជាច្រើនបានមកពីចំនួនប្រាក់បញ្ញើ ដែលមានការកើនឡើងដល់ ៣២៥ លានដុល្លារសហរដ្ឋអាមេរិក ឬ ៣.៥% នៃផលិតផលក្នុងស្រុកសរុប។ លើសពីនេះការកើនឡើងនៃស្ត្រី បានបង្កើតឲ្យមានសមាមាត្រជាក់ស្តែង (ជិត ៤៧%) នៃទេសន្តប្រវេសន៍ទៅប្រទេសថៃ ប៉ុន្តែទិន្នន័យនេះមិនត្រូវបានចងក្រងជាឯកសារពេញលេញនៅឡើយទេ ដោយសារតែទេសន្តប្រវេសន៍ជាស្ត្រីនៅមានការលួចលាក់នៅឡើយ។ មានការរាយការណ៍មកថា ពលករជាស្ត្រីមានការងារធ្វើនៅក្នុងផ្ទះ ហាងលក់ទំនិញ និងវិស័យសេវាកំសាន្តជាដើម។

ថ្មីៗនេះ ក្រសួងការងារបានបង្កើតក្រុមការងារមួយ សម្រាប់ត្រួតពិនិត្យការគ្រប់គ្រងទេសន្តប្រវេសន៍អន្តរជាតិ ដោយផ្តល់នូវសារៈប្រយោជន៍ និងការចូលរួមចំណែកដល់សេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ជំហានដំបូងគឺត្រូវរៀបចំគោលនយោបាយថ្នាក់ជាតិស្តីពីទេសន្តប្រវេសន៍ យន្តការនៃស្ថាប័នដើម្បីលើកកម្ពស់ទេសន្តប្រវេសន៍ និងការពារពលករទេសន្តប្រវេសន៍ ផ្តល់នូវជំនាញ និងវគ្គបណ្តុះបណ្តាលសំខាន់ៗ ដើម្បីអាចប្រែប្រួលទៅតាមតម្រូវការជំនាញដែលផ្លាស់ប្តូរនៃប្រទេសដែលទទួលយកការងារ និងផ្តល់នូវការយកចិត្តទុកដាក់គ្រប់គ្រាន់សម្រាប់បញ្ជូនពលករមកវិញ។

## គោលនយោបាយមុខរបរនិងការងារ

ការរួមបញ្ចូលគោលនយោបាយការងារ គឺជាធាតុបូករួមនៃការបង្កើតការងារ និងយុទ្ធសាស្ត្រការពារកំលាំងពលកម្ម។ ជាធម្មតា មានឧបករណ៍លើកកម្ពស់ និងផ្លូវច្បាប់ជាច្រើន ដែល ១.ជួយសម្រួល

[81] មើលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ/ILO, គោលនយោយបាស្តីពីអន្តោប្រវេសន៍ការងារសម្រាប់កម្ពុជា 2010, ទំព័រទី ១៣

[82] ចំពោះករណីផ្អែកលើការស្រង់មតិដ៏គួរឲ្យចាប់អារម្មណ៍នៃទេសន្តប្រវេសន៍ក្នុងប្រទេសរបស់យុវជននៅកម្ពុជា សូមមើល CDRI "ទេសន្តប្រវេសន៍យុវវ័យ និងនគរូបនីយកម្មនៅកម្ពុជា"

ការប្រព្រឹត្តទៅដោយរលូន នៃទីផ្សារការងារដោយផ្តោតលើមុខរបរនិងការងារ និងការអភិវឌ្ឍជំនាញនៃកម្លាំងពលកម្មដូចជាជំនាញប្រកួតប្រជែង និងជំនាញមានផលិតភាព និង ២.ការពារសិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ។ ទាំងពីរនេះសំដៅលើកកម្ពស់ឲ្យមានការងារគ្រប់គ្រាន់។ បន្ថែមពីនេះ ចំណុចទី ១ ត្រូវការការបង្កើតសេចក្តីណែនាំពីស្ថាប័ន និងកម្មវិធីសម្រាប់លើកកម្ពស់គោលនយោបាយមួយចំនួន រួមទាំងគោលនយោបាយទីផ្សារការងារសកម្ម និងអសកម្ម។ ចំណុចទី ២ ជាធម្មតាផ្អែកលើច្បាប់ស្តីពីការងារដែលបានព្រមព្រៀងគ្នា ដែលផ្តល់នូវសេចក្តីណែនាំផ្អែកច្បាប់សម្រាប់ការពារសិទ្ធិកម្មករ និយោជកជាមូលដ្ឋាន សម្រាប់ការចរចា និងកិច្ចសន្ទនាសង្គម។ គោលនយោបាយការងារដែលបានរៀបចំយ៉ាងល្អ ជាការចាំបាច់បន្ថែមនៅពេលដែលសេដ្ឋកិច្ចស្ថិតនៅលើផ្លូវអន្តរកាល ពាក់ព័ន្ធនឹងគោលការណ៍ឆ្ពោះទៅផ្អែកលើទីផ្សារ ហើយវិស័យឯកជនត្រូវបានជំរុញឲ្យក្រោកឡើងក្នុងនាមជាប្រភពនាំមុខនៃការបង្កើតមុខរបរនិងការងារ។[83]

នៅប្រទេសកម្ពុជា ច្បាប់ស្តីពីការងារដែលអនុម័តនៅឆ្នាំ១៩៩៧ ជាមូលដ្ឋាន ផ្តល់នូវក្របខណ្ឌគតិយុត្តិសម្រាប់ការងារ ដែលមានការបំពេញបន្ថែមដោយប្រកាសជាច្រើនទៀត។ ក្របខណ្ឌគតិយុត្តិផ្តល់នូវសេចក្តីណែនាំខាងផ្លូវច្បាប់សម្រាប់ការពារសិទ្ធិកម្មករនិយោជិត និងនិយោជកនៅកន្លែងធ្វើការដោយឡែក សេចក្តីណែនាំទាំងនេះពាក់ព័ន្ធនឹងសេចក្តីណែនាំអំពីសិទ្ធិកម្មករនិយោជិត ក្នុងការបង្កើតជាសហភាពពាណិជ្ជកម្ម សិទ្ធិការងារ (ដូចជាសិទ្ធិធ្វើកូដកម្ម) ការតវ៉ាជារួម លក្ខខណ្ឌការងារ និងបញ្ញត្តិអំពីការដោះស្រាយវិវាទ។ ដូចដែលបានបញ្ជាក់ខាងដើម ប្រទេសកម្ពុជាស្ថិតនៅក្នុងសម័យអន្តរកាលទៅកាន់សេដ្ឋកិច្ចទីផ្សារ និងការកសាងស្ថាប័នរហូតដល់ការបញ្ចប់កំពុងបន្ត។ ការអនុវត្ត អនុសញ្ញាចរចាររួម(CBAs) និងការដោះស្រាយវិវាទ ត្រូវការពេលវេលានិងការពង្រឹងសមត្ថភាពដើម្បីឲ្យមានដំណើរការយ៉ាងពេញលេញ។ ក៏ប៉ុន្តែ នេះជាការលើកកម្ពស់ក្នុងការកត់សម្គាល់ថា CBAs កំពុងតែមានការកើនឡើង ចាប់ពី៤៥ ក្នុងចន្លោះឆ្នាំ២០០៣-២០០៦ រហូតដល់១៣១ នៅឆ្នាំ ២០០៩។[84] ដូចគ្នានេះដែរ ដើម្បីពង្រឹងការដោះស្រាយវិវាទការងារ នាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាលកំពុងតែតាក់តែងវិធានដោះស្រាយវិវាទការងារ ។[85]

ក្របខណ្ឌគតិយុត្តិការងារដ៏មានប្រសិទ្ធិភាពក៏ត្រូវការ ការពង្រឹង និងកសាងសមត្ថភាពអង្គការនិយោជិត និងនិយោជក ការបង្កើតវគ្គបណ្តុះបណ្តាលជាប្រចាំ ដោយដាក់កម្មវត្ថុទៅនឹងបញ្ហាសំខាន់ៗ

[83] បទពិសោធន៍អន្តរជាតិនៃអន្តរកាលអំពីសេរីភាវូបនីយកម្ម ដូចជានៅប្រទេសចិន និងអឺរ៉ុបខាងកើត និងកណ្តាលក្នុងទសវត្សឆ្នាំ ៩០ គូសបង្ហាញអំពីសារៈប្រយោជន៍តាមដានការជួលពលករ និងលទ្ធផលទេសន្តប្រវេសន៍ការងារតាមរយៈគោលនយោបាយទេសន្តប្រវេសន៍ការងារដែលបញ្ជាក់យ៉ាងច្បាស់។

[84] NIS/ILO, ទំនោរការងារ និងសង្គម, 2010, តារាងទី ៣.២១

[85] NIS/ILO, ទំនោរការងារ និងសង្គម, 2010, តារាងទី ៣.២១

នៃសេដ្ឋកិច្ចជាទូទៅ និងបញ្ហាទីផ្សារការងារ។ តាមរយៈមធ្យោបាយជាច្រើន ដំណើរប្រព្រឹត្តទៅនៃការប្រមូលផ្តុំក្រុមកម្មករប្រហែលជាត្រូវបានរារាំង នេះប្រហែលជាមិនមែនដោយសារកង្វះការចងក្រងជាសហជីពទេ ប៉ុន្តែដោយសារមានការចងសម្ព័ន្ធច្រើនពេក។ សហជីពដែលបានចុះបញ្ជីការមានប្រហែល ១៧២៥ សហព័ន្ធសហជីពចំនួន ៤២ និងសម្ព័ន្ធសហជីពចំនួន ៥។[86] ដូចនេះ វាហាក់ដូចជាមានគំនិត និងទម្ងន់ខុសគ្នាអំពីអាទិភាពថ្នាក់ជាតិ និងប្រយោជន៍កម្មករនិយោជិត។ ម៉្យាងទៀត និយោជកបញ្ចេញសម្លេងរបស់ពួកគេ តាមរយៈសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា(CAMFEBA) ដោយមានវត្តមាននាំមុខដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)។

ជាការពិត មានគំនិតខុសគ្នាជាច្រើនរវាងក្រុមទាំងពីរ ពីបញ្ហាជាច្រើនពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិនៅកន្លែងធ្វើការ។ ឧទាហរណ៍ដូចជា CAMFEBA ប្រហែលជា មិនសូវពេញចិត្តនឹងការតម្លើងថ្លៃឈ្នួលអប្បបរមា និងវិសាលភាពនៃបទបញ្ញត្តិរបបសន្តិសុខសង្គម ដោយសារតែបញ្ហាទាំងអស់នេះអាចបណ្តាលឲ្យកម្ពុជាបាត់បង់ភាពប្រកួតប្រជែងជាលក្ខណៈអន្តរជាតិរបស់ខ្លួន។[87] ម៉្យាងវិញទៀត ក្រុមកម្មករអាចមានបំណងស្នើសុំប្រាក់ឈ្នួលខ្ពស់ជាងនេះទៅតាមផលិតភាព និងលក្ខខណ្ឌការងារប្រសើរជាងមុន។ គួរឲ្យកត់សម្គាល់ដែរថា នៅកម្ពុជាជាពិសេសវិស័យកាត់ដេរ បានទទួលការអះអាងថាមានស្តង់ដារការងារខ្ពស់ជាលក្ខណៈអន្តរជាតិ។[88] ទាំងនេះជាប្រយោជន៍សម្រាប់ការនាំចេញរបស់កម្ពុជា រហូតដល់ពេលថ្មីៗនេះវិបត្តិសេដ្ឋកិច្ចសកលលោកមិនទាន់ប៉ះពាល់ដល់ការនាំចេញសំលៀកបំពាក់នៅឡើយទេ ប៉ុន្តែវិស័យនេះក៏មានចំនុចខ្សោយជាច្រើនផងដែរ ជាពិសេសផលិតភាព ប្រសិទ្ធិភាព និងការប្រកួតប្រជែងខាងជំនាញ។[89] ទាំងក្រុមកម្មករនិយោជិត និងនិយោជកយល់ព្រមពីការគាំទ្រ និងពង្រឹងសក្តានុពលនាំចេញសំលៀកបំពាក់ និងវិស័យដទៃទៀត។ នេះជាការផ្តោតទៅលើក្របខណ្ឌគតិយុត្តិ តាមរយៈការវាយតម្លៃកម្មវត្ថុ និងការបណ្តុះបណ្តាលកម្មករនិយោជិត និងនិយោជក ដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងផលិតភាពសហគ្រាស និងសន្តិសុខការងាររបស់កម្មករ។

ច្បាប់ស្តីពីការងារ និងវិធានការការពារការងារជាច្រើន និងការអនុវត្តវិធានទាំងនេះត្រូវការការពិនិត្យឡើងវិញ ដោយសារតែសេដ្ឋកិច្ចមានការកើនឡើង និងខុសប្លែកគ្នា។ យើងគួរតែសង្កេតឃើញថាក្របខណ្ឌគតិយុត្តិសព្វថ្ងៃ កំណត់ត្រឹមតែចំពោះការងារក្នុងវិស័យផ្លូវការនិងសាធារណៈដែលជាភាគតិចនៃកម្លាំងពលកម្មសរុបប៉ុណ្ណោះ។ ដរាបណា ការអនុវត្តច្បាប់ស្តីពីការងារបានត្រឹមត្រូវ វាអាចរួមចំណែក

---

[86] NIS/ILO, ទំនោរការងារ និងសង្គម, 2010, តារាងទី ៣.២១, ទំព័រទី ៣៦

[87] នេះជាកស្តុតាងនៅពេលដែលអ្នកនិពន្ធបានជួប និងពិភាក្សាជាមួយអ្នកតំណាងក្រុមពលករចំនួន ៥ ផ្សេងៗគ្នា (ខែវិច្ឆិកា ២០១០)

[88] ទាំងនេះត្រូវបានសម្របសម្រួលដោយការអនុវត្តកម្មវិធីការងារប្រសើរជាងមុន សម្របសម្រួលដោយ ILO។ Cf. IILS/ការងារប្រសើរជាងមុន (2009)

[89] CDRI (2010)

ចំពោះការបែងចែកទីផ្សារការងារ និងកាត់បន្ថយសមត្ថភាពស្រូបការងារនៃវិស័យផ្លូវការ។ ការរៀបចំនេះអាចមានទំនោរកើនឡើងក្នុងការផ្តល់ឲ្យអ្នកម៉ៅការបន្ត ធ្វើការផ្នែកផលិតកម្មតាមរយៈវិស័យមិនផ្លូវការ ឬការងារម្តងម្កាល ដែលនេះអាចកាត់បន្ថយកម្រិតមធ្យមនៃប្រាក់ឈ្នួល និងការការពារនៅក្នុងទីផ្សារការងារ ការបែងចែកប្រាក់ឈ្នួល និងសន្តិសុខការងារកាន់តែមិនស្មើគ្នា។ វាក៏ត្រូវការការត្រួតពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នថាកម្មករនិយោជិត ក្នុងវិស័យមិនផ្លូវការអាចមានការការពារ និងលក្ខខណ្ឌការងារប្រសើរជាងនាពេលបច្ចុប្បន្នផងដែរ ។

ក្របខណ្ឌគតិយុត្តិក្នុងវិស័យការងារ ក៏ត្រូវការធានាថា គ្មានការរើសអើង ឬការរំលោភបំពានការងារនៅក្នុងទីផ្សារការងារ។ ជាការពិត កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាការងារស្នូលទាំងអស់របស់ILO។ វាមិន ត្រឹមតែត្រូវពង្រឹងក្របខណ្ឌគតិយុត្តិប៉ុណ្ណោះទេ ថែមទាំងរៀបចំ និងអនុវត្តកម្មវិធីអំពីការមិនរើសអើង និងការការពារ ជាពិសេសកាត់បន្ថយគ្រោះថ្នាក់ការងារនៃការប្រើប្រាស់ពលកម្មកុមារ និងបង្កើនជំនាញ ភាពមានការងាររបស់ស្ត្រីក្នុងទីផ្សារដែលមានផលិតភាពខ្ពស់ និងទីផ្សារការងារដែលមានផលិតភាព។ ជាឧទាហរណ៍ ការប្រើប្រាស់ពលកម្មកុមារបានកើនឡើងក្នុងចន្លោះឆ្នាំ១៩៩៨-២០០៨។ កុមារធ្វើការដែលមានអាយុពី៥ ដល់១៧ឆ្នាំបានកើនឡើងពី៨% ដល់១០%នៃកំលាំងពលកម្ម។[90] ទាំងនេះត្រូវការ ការសិក្សាស្រាវជ្រាវ និងវិធានការសមស្របដើម្បីកាត់បន្ថយពលកម្មកុមារ។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ ដល់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបញ្ឈប់ការជួញដូរកុមារ។

ក្រៅពីក្របខណ្ឌគតិយុត្តិ គោលនយោបាយការងាររបស់រាជរដ្ឋាភិបាល គួរត្រូវមានអភិក្រមពង្រឹងការអភិវឌ្ឍជំនាញនៃកំលាំងពលកម្ម និងជៀសវាងការរើសអើងនៅក្នុងទីផ្សារការងារ។ ក្នុងករណីមានការកើតឡើងដដែលៗ វាត្រូវបានគេអង្កេតយ៉ាងទូលាយថាកម្លាំងពលកម្មនៅមិនទាន់មានជំនាញ មិនបានអប់រំត្រឹមត្រូវ ដូចនេះនាំឲ្យមានគុណភាពអន់ថយ បើធៀបនឹងប្រទេសជិតខាងនៅអាស៊ី ។[91] យើងក៏បានអង្កេតឃើញថា ប្រសិនបើកម្ពុជាអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្អែកលើកំលាំងពលកម្ម និងការនាំចេញ វានឹងផ្តល់អត្ថប្រយោជន៍ប្រៀបធៀបរបស់ខ្លួន ផ្អែកលើការពង្រីកភាពប្រកួតប្រជែងនៃជំនាញ ពិពិធកម្ម និងមិនផ្អែកតែទៅលើតម្លៃការងារទាបនោះទេ។ បច្ចុប្បន្ននេះ វិស័យនាំចេញនាំមុខ ដូចជាវិស័យកាត់ដេរមានវត្តមានមិនស្មើគ្នានៃកំលាំងពលកម្ម ដែលគ្មានជំនាញខាងផលិតកម្ម និងមានតិចតួចក្នុងចំណោមអ្នកគ្រប់គ្រង និងអ្នកចាត់ការផលិតកម្ម។[92] វាក៏ត្រូវកត់សម្គាល់ផងដែរថា ពលករគ្មានជំនាញបង្កើតជា

---

[90] មើល NIS-ILO (2010)

[91] Cf. UNDP (2010), op cit

[92] មើល EIC (2008)

ចំនួនភាគច្រើននៃកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ក៏ដូចជាក្នុងចំណោមពលករទេសន្តប្រវេសន៍ផងដែរ។ ដូច្នេះ ការខិតខំប្រឹងប្រែងផ្តល់កម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញ គួរតែត្រូវបានផ្តល់អាទិភាពខ្ពស់នៅក្នុងការសិក្សា ពីគោលនយោបាយការងារនៅកម្ពុជា។

ក្រៅពីការអន្តរាគមន៍ផ្នែកជំនាញ គោលនយោបាយការងារត្រូវបញ្ជាក់ច្បាស់ពីគោលនយោបាយទីផ្សារការងារសកម្ម(ALMPs) ទោះបីជាធាតុផ្សំផ្សេងៗរបស់វាធ្វើខុសពីវិសាលភាពក៏ដោយ។ សេវាកម្មការងារសាធារណៈដែលជាមូលដ្ឋានសំខាន់នៃ ALMPs កំពុងចាប់ផ្តើមបង្ហាញឲ្យឃើញ និងពង្រីកក្រោមទីភ្នាក់ងារជាតិមុខរបរ (NEA)។ មុខងារសំខាន់២យ៉ាងដែលNEA ត្រូវការ ការគាំទ្រខាងផ្នែកថវិកា និងការកសាងសមត្ថភាព គឺការពង្រីកសេវាកម្មការងារ (តាមរយៈអ៊ិនធឺណេត និងមជ្ឈមណ្ឌលការងារ) និងបង្កើតប្រព័ន្ធពត៌មានទីផ្សារការងារ(LMIS) ដែលចាំបាច់សម្រាប់ការងារតាមដាន និងការអនុវត្តទីផ្សារការងារសម្រាប់វិស័យសេដ្ឋកិច្ច។ NEA ក៏នឹងត្រូវការភ្ជាប់ជាមួយនឹងគំរោងការបណ្តុះបណ្តាលទាំងឯកជន និងសាធារណៈ និងពង្រីកបន្ថែមលើសពីមជ្ឈមណ្ឌលក្នុងក្រុងជាបណ្តើរៗ។ កម្ពុជាក៏មានចំនួនគម្រោងអន្តរាគមន៍ការងារជាច្រើន ដូចជាកម្មវិធីការងាររដ្ឋជាដើម ដែលត្រូវមានការសហការក្នុងគម្រោងពេញលេញនៃALMPs។ ត្រូវមានការយកចិត្តទុកដាក់ពិសេស ចំពោះក្រុមដែលគ្មានផលប្រយោជន៍ជាងគេ ដូចជាស្ត្រី យុវជន និងជនពិការជាដើម។

# ៧. កិច្ចគាំពារសង្គម និងមុខរបរ

គោលនយោបាយគាំពារសង្គម និងគោលនយោបាយឆ្ពោះទៅកាន់គោលដៅការងារពេញលេញត្រូវតែបានឃើញថា ជាគោលនយោបាយសំខាន់ពាក់ព័ន្ធនឹងវិស័យជាច្រើនប្រឆាំងនឹងភាពក្រីក្រ។ បន្ថែមពីនេះ ស្ថាប័នពាក់ព័ន្ធត្រូវការ ការពារលទ្ធផលនៃគោលនយោបាយទាំងនេះ ហើយត្រូវពង្រឹងជាបន្តបន្ទាប់ដើម្បីឲ្យស្របនឹងការវិវត្តនៃសេដ្ឋកិច្ច។ ប្រទេសដែលមានសេដ្ឋកិច្ចឈានមុខ ជាពិសេសប្រទេសនៅអឺរ៉ុប បានផ្តល់ជាឧទាហរណ៍ថាតើ គោលនយោបាយគាំពារសង្គម និងគោលនយោបាយការងារពេញលេញ អាចត្រូវបានរួមបញ្ចូលតាមវិធីណា ដើម្បីអាចបង្កើតបានស្ថាប័នសុខមាលភាពសង្គមបានល្អប្រសើរ ប៉ុន្តែឧទាហរណ៍ទាំងនេះមិនទាន់អាចយកទៅអនុវត្តក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅឡើយទេ។ ទោះបីជាសេដ្ឋកិច្ចក្នុងប្រទេសអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍មានការលូតលាស់យ៉ាងឆាប់តាមរយៈកំណើនពឹងផ្អែកលើពលកម្ម ដែលឈានទៅដល់ការងារជិតពេញលេញក្តី មានការសង្កត់ធ្ងន់លើវិធានការគាំពារសង្គមតិចតួចនៅឡើយ។ ការយកចិត្តទុកដាក់មិនទាន់គ្រប់គ្រាន់ទៅលើវិធានការ ទាំងនោះ បង្ហាញឲ្យឃើញនាពេលវិបត្តិហិរញ្ញវត្ថុអាស៊ីនាឆ្នាំ១៩៩៧ ខណៈដែលសេដ្ឋកិច្ចប្រទេសទាំងនោះជាពិសេសប្រទេសថៃ កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី ជួបប្រទះនូវការធ្លាក់ចុះកំណើនផលិតផលក្នុងស្រុកសរុប

យ៉ាងខ្លាំង ដោយមានផលវិបាកផ្សេងៗអំពីការងារ និងចំណូលនៃកម្លាំងពលកម្ម។[93] បន្ទាប់ពីវិបត្តិ ប្រទេសទាំងនោះ ទើបតែបានចាប់ផ្ដើមពង្រឹងគោលនយោបាយ និងបង្កើតស្ថាប័នគាំពារសង្គម។

សេដ្ឋកិច្ចអាស៊ីភាគច្រើនផ្សេងទៀតត្រូវទទួលបន្ទុកលើភាពក្រីក្រខ្ពស់ កង្វះការងារ និង ការគាំពារសង្គមមានវិសាលភាពតូច។[94] វិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ២០០៨ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជនក្រីក្រ និងជនងាយរងគ្រោះ ហើយបានបង្ហាញឲ្យឃើញពីកិច្ចជាបន្ទាន់ សម្រាប់អ្នករៀបចំគោលនយោបាយថ្នាក់ជាតិ ក្នុងការបង្កើតយន្តការសំណាញ់សុវត្ថិភាពសង្គម ដើម្បីជួយជនក្រីក្រពីវិបត្តិខាងក្នុង និងខាងក្រៅ។[95] រហូតដល់បច្ចុប្បន្ននេះ ប្រទេសភាគច្រើនមិនសូវបានយកចិត្តទុកដាក់ខ្លាំងលើតម្រូវការសម្រាប់បង្កើនការងារ និងយកចិត្តទុកដាក់កាន់តែតិច លើតម្រូវការអភិវឌ្ឍន៍យន្តការគាំពារសង្គម។ ភាពប្រឈមគឺមានភាពជំពេង និងមិនអាចដូរចុះឡើងនោះទេ ក្នុងការអនុវត្តការយកចិត្តទុកដាក់លើគោលនយោបាយទាំងពីរនេះ។ ប៉ុន្តែភាពប្រឈមត្រូវតែដោះស្រាយ ព្រោះថាប្រសិនបើភាពក្រីក្រត្រូវបានទប់ស្កាត់ ផលវិបាកដល់សង្គមផ្សេងទៀត នឹងត្រូវបានដោះស្រាយ។

នៅកម្ពុជា កម្រិត និងវិសាលភាពនៃការគាំពារសង្គមនៅក្នុងវិស័យការងារ នៅមានកម្រិតទាបនៅឡើយ។ នេះជាការលើកឡើងដោយឡែក ទោះបីជាកម្រិតភាពក្រីក្រមានការធ្លាក់ចុះ ប៉ុន្តែក៏នៅតែមានកម្រិតខ្ពស់នៅឡើយ(៣០%) និងថាប្រជាជនដែលងាយរងគ្រោះមានប្រហែល ៨២% (ក្នុងឆ្នាំ ២០០៨)។[96]

ជាគោលការណ៍ រាជរដ្ឋាភិបាលអនុវត្តយ៉ាងពេលលេញក្នុងការផ្ដល់នូវការគាំពារសង្គមទៅដល់ប្រជាជនខ្មែរទាំងអស់ ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ។ ទាំងនេះមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ថា៖

"ប្រជាពលរដ្ឋខ្មែរទាំងអស់មានសិទ្ធិទទួលបានរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍សង្គមដទៃទៀតដូចមានកំណត់ដោយច្បាប់"។

ដូចនេះរាជរដ្ឋាភិបាលបានព្យាយាមផ្ដល់អាទិភាពដល់ការគាំពារសង្គមតាមរយៈយុទ្ធសាស្ត្រចតុកោណ និងកម្មវិធីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។ ដោយផ្ដល់នូវការកម្រិតអំពីចន្លោះ

---

93 ចំពោះព័ត៌មានបន្ថែមអំពីផលប៉ះពាល់ដល់សង្គមនៃហិរញ្ញវត្ថុអាស៊ី, មើល E. Lee (1998)

94 មើលរបាយការណ៍ ILO ស្ដីពីរបបសន្តិសុខសង្គមពិភពលោក 2010-2011

95 ឧទាហរណ៍ដូចជា គោលគំនិតនៃជាន់ការពារសង្គម ដែលបានដាក់ដោយ ILO និងអនុម័តដោយប្រព័ន្ធ UN ថាជាផ្នែកនៃការឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក

96 NIS/ILO (2010), *ibid,* ផ្ដល់នូវការត្រួតពិនិត្យឡើងវិញដោយសង្ខេបអំពីកម្មវិធីរបស់រាជរដ្ឋាភិបាលដែលមានស្រាប់។

ប្រហោងផ្នែកសារពើពន្ធ និងវិសាលភាពកំណត់នៃកំណើនការងារវិស័យផ្លូវការនៅក្នុងវិស័យឯកជន និងសាធារណៈ តើរាជរដ្ឋាភិបាលដឹងថាអាចផ្តល់ឥទ្ធិពលដល់ការអនុវត្តខាងលើយ៉ាងដូចម្តេច?

ស្ថានភាពបច្ចុប្បន្ននៃការគាំពារសង្គមនៅក្នុងប្រទេសអាចឃើញថា៖

១. ជារួម អភិក្រមជាប្រព័ន្ធ និងសម្របសម្រួលដល់របបសន្តិសុខសង្គមនៅមិនទាន់វិវត្តនៅឡើយ។ មូលហេតុជាបឋមគឺថា ចន្លោះប្រហោងផ្នែកសារពើពន្ធ គួរតែពង្រីកដើម្បីយកមកប្រើប្រាស់ក្នុងរបបសន្តិសុខសង្គមជាសាកល និងរបបសោធននិវត្តន៍(ក្នុងឆ្នាំ២០១២)។ ភាពប្រឈមយ៉ាងខ្លាំងក្នុងការពង្រីកកិច្ចគាំពារសង្គមសម្រាប់កម្មករក្នុងវិស័យមិនផ្លូវការ ដែលទំនងជាអាចបង្កើត "ទ្វិកនិយម" នៅក្នុងប្រព័ន្ធគាំពារសង្គម។

២. ចំពោះវិស័យ "ផ្លូវការ" ការអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវបានប្រគល់សិទ្ធិដល់ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម(NSSF) ក្នុងគោលបំណងធានារ៉ាប់រងគ្រោះថ្នាក់ការងារ(ចាប់ផ្តើមនៅឆ្នាំ២០០៧) និងគម្រោងធានារ៉ាប់រងសុខភាព (កំពុងរៀបចំដំណើរការ)។ ចាប់តាំងពីកិច្ចចាប់ផ្តើមនៅឆ្នាំ២០០៧ របបធានារ៉ាប់រងគ្រោះថ្នាក់ការងារ បានគ្របដណ្តប់កម្មករនិយោជិត ជិត៤សែននាក់ភាគច្រើនជាស្ត្រី នៅក្នុងវិស័យកាត់ដេរ ស្បែកជើង សំណង់ សណ្ឋាគារ និងធនាគារ។ បេឡាជាតិរបបសន្តិសុខសង្គម គ្របដណ្តប់ចំពោះសហគ្រាសដែលមានកម្មករនិយោជិត ចំនួន៨នាក់ ឬច្រើនជាងនេះក្នុងដំណាក់កាលដំបូង និងហាក់ឆ្ងាយពីការគ្របដណ្តប់សកល។ មូលនិធិស្រដៀងគ្នាសម្រាប់មន្ត្រីរាជការស៊ីវិល (បេឡាសន្តិសុខសង្គមសំរាប់មន្ត្រីរាជការស៊ីវិល NSSF-C) ត្រូវបានផ្តួចផ្តើមឡើងនៅឆ្នាំ ២០០៨ ដែលសំដៅគ្របដណ្តប់របបសោធននិវត្តន៍ គ្រោះថ្នាក់ការងារ ជនបាត់បង់សម្ថភាពការងារ និងលំហែរមាតុភាព។ របបនេះគ្របដណ្តប់មន្ត្រីរាជការប្រហែល១៨ម៉ឺននាក់ ដែលបច្ចុប្បន្នផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល និងមានគម្រោងប្តូរទៅជាប្រតិបត្តិការផ្អែកលើការចូលរួមភាគទានដោយស្ម័គ្រចិត្តវិញ។ ចំនុចមួយគួរឲ្យកត់សម្គាល់គឺថា ការបង្កើតប្រព័ន្ធគាំពារសង្គម ត្រូវការការកសាងសមត្ថភាព និងធនធាន។

៣. ចំពោះវិស័យមិនផ្លូវការ មានកម្មវិធីជាច្រើន ខុសប្លែកគ្នាទាំងទំហំ និងវិសាលភាព ទាំងនៅក្នុងក្របខណ្ឌថវិការដ្ឋ និងការឧបត្ថម្ភរបស់ម្ចាស់ជំនួយ។ មានកម្មវិធីធានារ៉ាប់រងសុខភាពសម្រាប់ជនក្រីក្របំផុត(ដូចជាមូលនិធិសមធម៌ HEF) និងជនជិតក្រ (ដូចជា កម្មវិធីធានារ៉ាប់រងសុខភាពសហគមន៍ CBHI)ដែលធ្វើប្រតិបត្តិការដោយមានបុព្វលាភតិចតួចពីអ្នកទទួលផល។នៅក្នុងការប៉ាន់ប្រមាណថ្មីៗនេះ មូលនិធិសមធម៌ត្រូវបានរំពឹងថាផ្តល់នូវវិសាលភាពធានារ៉ាប់រងសុខភាពដល់ជនក្រីក្រប្រហែល៦៨%។

៤. ក្រៅពីបញ្ញត្តិធានារ៉ាប់រងសុខភាពសម្រាប់ប្រជាជនមិនផ្លូវការ កម្មវិធីសំណាញ់សុវត្ថិភាពសង្គមមួយចំនួនធំសំដៅលើចំណូល និងការទទួលបានការងាររបស់ជនក្រីក្រ។ មានគម្រោងមិនបង់វិភាគទានជាច្រើនដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិរដ្ឋាភិបាល និង/ឬ ការឧបត្ថម្ភពីម្ចាស់ជំនួយ។ ឧទាហរណ៍ដូចជា[97]

- កម្មវិធីផ្ទេរសាច់ប្រាក់ និង/ឬមិនមែនជាសាច់ប្រាក់ ទៅឲ្យជនក្រីក្រគោលដៅ ជាមួយនឹងលក្ខខណ្ឌចំបងគឺការអប់រំ និងសុខភាព
- កម្មវិធីសំណង់សាធារណៈដែលផ្តល់ប្រាក់ឈ្នួល
- កម្មវិធីផ្តល់តែមប្តូរអាហារ របបស្បៀង ផ្តល់អាហារនៅតាមសាលារៀន កម្មវិធីបន្ថែមអាហារូបត្ថមសម្រាប់ម្តាយ និងទារក
- កម្មវិធីឧបត្ថម្ភធនលើថ្លៃអាហារ ឬថាមពល
- កម្មវិធីលើកលែងការបង់ថ្លៃសេវាសំខាន់ៗ ដូចជាសេវាសុខភាព ការប្រើប្រាស់ ឬការដឹកជញ្ជូនជាដើម

នៅពេលមានពហុតរភាពនៃការគាំទ្រចំណូល/ការងារ គំរោងសាកល្បងបានបង្កើតឡើង សម្រាប់ក្រុមគោលដៅពិសេស ដែលជាទូទៅលទ្ធផលមានការផ្លាស់ប្តូរ និងឆ្លុះបញ្ចាំង ពីក្រុមគោលដៅដែលកំណត់ដោយខុសៗគ្នា។

ដូចនេះ យើងកត់សម្គាល់ថាទាំងកម្លាំងពលកម្មក្នុងវិស័យផ្លូវការ និងមិនផ្លូវការ បានចាប់ផ្តើមនាពេលថ្មីៗនេះ ប៉ុន្តែវិសាលភាពនៃរបបសន្តិសុខសង្គមនៅមានកម្រិត។ កម្មវិធីជាច្រើនត្រូវបានដឹកនាំដោយម្ចាស់ជំនួយ។ ទោះជាយ៉ាងនេះក៏ដោយ ដំណើរការតាក់តែងគោលនយោបាយ និងកសាងស្ថាប័នត្រូវបានចាប់ផ្តើម ហើយកត្តាផ្សេងៗដូចជាការប្តេជ្ញាធ្វើការបន្ត ការប្រមូលធនធាន ការអនុវត្ត និងការកសាងសមត្ថភាព ត្រូវបំពេញតួនាទីរៀងៗខ្លួន ដើម្បីទទួលបានយុទ្ធសាស្ត្រគាំពារសង្គមប្រកបដោយជោគជ័យមួយ។ បញ្ហាប្រឈមធំជាងគេបំផុតនៅក្នុងការគ្របដណ្តប់ជាសកលណាក៏ដោយ ភាគច្រើនទទួលបានមកពីកម្មករនិយោជិតក្នុងវិស័យក្រៅផ្លូវការ ដូចជាវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម នៅតាមជនបទ ឬតាមទីក្រុង។

[97] មើល សុវណ្ណារិទ្ធិ, S (2010)

ថ្មីៗនេះ កម្មករនិយោជិតភាគច្រើនពឹងផ្អែកលើយន្តការមិនផ្លូវការនៃការគ្រប់គ្រងហានិភ័យ ដូចជា វិធានរស់នៅដែលផ្អែកលើសហគមន៍ ឬគ្រួសារ។[98] បណ្តាញសង្គមបែបប្រពៃណីទាំងនោះមានតាំងពីយូរណាស់មកហើយនៅកម្ពុជា សម្រាប់ជួយ និងគាំទ្រគ្នាទៅវិញទៅមក ដែលរាប់ចាប់ពីការជួយផ្តល់អាហារ ការជួលដី និង/ឬជួលសត្វ និងកម្ចីបន្តិចបន្តួចសម្រាប់បង្កើនជីវភាពជាដើម។ ដោយសារអត្រាប្រជាជនភាគច្រើន ជាជនដែលងាយទទួលរងហានិភ័យ ផលប៉ះពាល់នៃវិបត្តិខាងក្រៅ និងខាងក្នុងប្រទេស កាន់តែធ្វើឲ្យពួកគេងាយរងគ្រោះ បន្ថែមទាំងគ្រោះធម្មជាតិ ការឡើងថ្លៃ ឬផលប៉ះពាល់ពីវិបត្តិសកលលោក។ វិបត្តិអាហារឡើងថ្លៃ វិបត្តិប្រេងឡើងថ្លៃនៅឆ្នាំ២០០៨ និងផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលលោកតាមរយៈការបង្អង់ល្បឿនកំណើនចំនូល ដោយទទួលបាន មកវិញនូវភាពងាយរងគ្រោះបន្ថែមដល់ប្រជាជន។ មានការសិក្សាមួយចំនួននៅកម្ពុជាចងក្រងជាឯកសារ អំពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោកលើជនក្រីក្រ និងជនងាយរងគ្រោះ។[99] មានការចង្អុល បង្ហាញទាំងអស់ដោយសំណួមពរថា ចំណូល និងស្ថានភាពការងារកាន់តែអាក្រក់ទៅៗ ហើយភាពក្រីក្រ កាន់តែកើនឡើង។ នេះជាការពិតសម្រាប់ប្រទេសកម្ពុជាក៏ដូចជានៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើនផ្សេងទៀតដែរ ដែលមានការអំពាវនាវឲ្យមានបង្កើតប្រព័ន្ធគាំពារសង្គមដែលមានបង្ហាញយ៉ាងច្បាស់ និង រៀបចំយ៉ាងល្អនៅថ្នាក់ជាតិ។[100]

ត្រឡប់ទៅរកសំនួរដែលបានលើកឡើងខាងលើ ថាតើរាជរដ្ឋាភិបាលអាចធ្វើអ្វីបានដើម្បីឲ្យការអនុវត្តរបស់ខ្លួនមានប្រសិទ្ធភាពក្នុងការកសាងយុទ្ធសាស្រ្តជាតិគាំពារសង្គម ដែលភាពបន្ទាន់បានដៅបញ្ជាក់ដោយផលប៉ះពាល់ធ្ងន់ធ្ងរនៃវិបត្តិថ្មីៗនេះលើជនក្រីក្រ និងជនងាយរងគ្រោះ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) មានសិទ្ធិ "កំណត់វិសាលភាព និងកំណត់ផែនទី និងការវិភាគពីចន្លោះលើសំណាញ់សុវត្ថិភាពសង្គម ដែលមានស្រាប់ និងសម្របសម្រួលការអភិវឌ្ឍន៍ប្រព័ន្ធសុវត្ថិភាពសង្គមដែលរួមបញ្ចូលគ្នាច្រើន"។[101] CARD បានបង្កើតយុទ្ធសាស្រ្តមួយគឺ យុទ្ធសាស្រ្តជាតិគាំពារសង្គម (យ.ជ.គ.ស)។ យ.ជ.គ.ស ត្រូវបានកំណត់ដូចទម្រង់ខាងក្រោមៈ

យុទ្ធសាស្រ្តជាតិគាំពារសង្គម ដែលទើបបានអនុម័តនាពេលថ្មីៗនេះ ត្រូវបានមើលឃើញថាជា លំហាត់កំណត់ពីវិសាលភាព។ ដូចក្នុងរូបភាពបង្ហាញខាងលើ វាជាការកំណត់ផែនទីទូទៅ នៃសំណាញ់សុវត្ថិភាពសង្គម ដែលពឹងផ្អែកលើធាតុផ្សំបន្ទាប់បន្សំ ឬយុទ្ធសាស្រ្តមួយចំនួន។ យុទ្ធសាស្រ្តជាតិគាំពារសង្គម ដែលសំដៅកសាងកិច្ចគាំពារសង្គមជាមូលដ្ឋាន នៅមិនទាន់បង្ហាញឲ្យបានច្បាស់នៅក្នុងយន្តការ

---

[98] ចំពោះចំណាប់អារម្មកាន់តែស៊ីជម្រៅដល់ទម្រង់បែបប្រពៃណីនៃការធានារ៉ាប់រងសង្គម សូមមើល សុវណ្ណារិទ្ធិ (2010), op cit; CDRI

[99] មើលអត្ថបទផ្សេងៗនៅក្នុង CDRI ស្តីពីការត្រួតពិនិត្យឡើងវិញនូវការអភិវឌ្ឍប្រចាំឆ្នាំ 2009-2010 ជាពិសេស Jalilian et al (2010) និង ចាន់ ដារ៉ារ័ត្ន et al (2010) ចំពោះព័ត៌មានផ្អែកលើការស្រង់មតិ អំពីផលប៉ះពាល់នៃវិបត្តិលើកម្មករសំលៀកបំពាក់។

[100] ជាឧទាហរណ៍ យុទ្ធនាការរបស់ ILO ក្នុងការជំរុញការគាំពារសង្គម។

[101] Cf. CARD (2010)

បញ្ចូលគ្នាមួយនៅឡើយ ហើយការគិតបន្ថែមតម្រូវឲ្យមាន ថាតើជាតុផ្សំផ្សេងៗដូចបានបង្ហាញនៅក្នុងរូបភាព ត្រូវបានរួមបញ្ចូលនិងសហការគ្នាបង្កើតជាអភិក្រមសន្ទនិយម( Holistic Approach ) ដែលមិនជាន់គ្នា។ ការផ្តល់ហិរញ្ញប្បទានការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម នៅមិនទាន់ច្បាស់ពេញលេញនៅឡើយ ថាតើក្រសួងពាក់ព័ន្ធផ្សេងៗ នឹងដើរតួក្នុងការអនុវត្តជាតុផ្សំបន្ទាប់បន្សំ ដូចជាកម្មវិធីឧបត្ថម្ភមិនរួមភាគទាន ការងារសំណង់សាធារណៈ ជាដើម។ បច្ចុប្បន្ន យុទ្ធសាស្ត្រជាតិគាំពារសង្គម ឆ្លុះបញ្ចាំងអំពីភាពបន្ទាន់នៃការសិក្សាពីរបបសន្តិសុខសង្គម អះអាងថាការវិនិយោគលើធនធានមនុស្សជាបញ្ហាចំបងចំពោះជនក្រីក្រ និងជនងាយរងគ្រោះ។

**រូបភាពទី ៧.១៖ យុទ្ធសាស្ត្រជាតិគាំពារសង្គមសំរាប់ជនក្រីក្រ និងងាយរងគ្រោះ**




ក្នុងបរិបទនៃការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម យើងសង្កេតឃើញមានកត្តាពីរយ៉ាង។ ទី១ ផ្នែកខ្លះយុទ្ធសាស្ត្រមួយចំនួនមិនអាចអនុវត្តបានដោយរដ្ឋ។ ឧទាហរណ៍ រដ្ឋអាចប្រកាសអំពី "ក្របខណ្ឌគតិយុត្តិដោយគោរពតាម "ការធានារ៉ាប់រងសង្គម" ប៉ុន្តែការអនុវត្តត្រូវផ្អែកលើ ថាតើការងារក្នុងវិស័យផ្លូវការកើនឡើងយ៉ាងដូចម្តេច? ការចរចារ និងកិច្ចសន្ទនាសង្គមរវាងដៃគូរពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច? ដូចគ្នានេះដែរ ចំពោះការចំណាយលើសំណាញ់សុវត្ថិភាពសង្គមដែលមិនរួមភាគទាន យ៉ាងហោច

ណាស់ក៏លើសថវិការជួសម្រាប់រៀបចំកញ្ចប់សកលមួយ។ ដូចនេះ យុទ្ធសាស្ត្រជាតិគាំពារសង្គម ត្រូវតែកសាងដោយផ្អែកលើគោលការណ៍ "សាមគ្គីភាព" និង"ដែលអាចចែកចាយឡើងវិញបាន" ដើម្បី អំពាវនាវឲ្យមានការចូលរួមពីរដ្ឋ និងសង្គមក្នុងការឧបត្ថម្ភជនក្រីក្រ និងជនងាយរងគ្រោះ។ ទីពីរ បន្ថែមពីលើជាតុផ្សំធម្មតានៃការឧបត្ថម្ភសង្គមដែលមិនរួមភាគទាន (រួមមាន ការឲ្យការងារធ្វើតាមរយៈកម្មវិធី សំណង់សាធារណៈ) យុទ្ធសាស្ត្រជាតិគាំពារសង្គម រួមបញ្ចូលនូវ "គោលនយោបាយទីផ្សារការងារ" ក្នុងនាមជាជាតុផ្សំរងនៃយុទ្ធសាស្ត្រ។ ចំណុចដែលមិនច្បាស់ទាំងនេះ សំដៅទៅលើគោលនយោបាយទីផ្សារការងារសកម្មដែលមានលក្ខណៈបែបប្រពៃណី (ឬគោលនយោបាយការងារសកម្ម ហៅនៅប្រទេសចិន) ឬត្រូវរួមបញ្ចូលផងដែរ នូវគោលនយោបាយពលកម្មផ្សេងដែលកំណត់ដោយច្បាប់ការងារ។ វាជាការមានប្រយោជន៍ និងច្នៃប្រឌិតថ្មី ប្រសិនបើយុទ្ធសាស្ត្រជាតិគាំពារសង្គម រួមបញ្ចូលនូវជាតុផ្សំ ALMPs និងរៀបចំកម្មវិធីដើម្បីទាញយកចំណុចរួមរវាងរបបសន្តិសុខសង្គម និង ALMPs។[102]

ទោះជាយ៉ាងណាក្តី ជាការសំខាន់ត្រូវដឹងថា ទោះបីកម្ពុជាមានស្ថាប័នស្ថិតនៅក្រោមបន្ទាត់នៃការអភិវឌ្ឍន៍ដែលមានស្រាប់ និងថវិកាមិនគ្រប់គ្រាន់ ប៉ុន្តែបានផ្តួចផ្តើមបង្កើតក្របខណ្ឌយ៉ាងច្បាស់មួយឆ្ពោះទៅរករបបសន្តិសុខសង្គមសម្រាប់ប្រជាជនទាំងអស់។ ទោះបីជាការផ្តល់ភារកិច្ចមានភាពផ្លាស់ប្តូរ ហើយក្រុមគោលដៅជាជាតុផ្សំបន្ទាប់បន្សំ យុទ្ធសាស្ត្រជាតិគាំពារសង្គម នឹងមានហានិភ័យក្នុងការអាចក្លាយទៅជាកម្មវិធីប្រឞូកប្របល់ដែលគ្មានការសម្របសម្រួល។ យុទ្ធសាស្ត្រអាចបញ្ចូលគ្នាក្នុងករណីដែលជាតុផ្សំទាំងនេះមានអន្តរសកម្ម ហើយចំណុចរួម រវាងជាតុផ្សំត្រូវបានចាប់យកយ៉ាងត្រឹមត្រូវ។ ក្នុងបរិបទនេះ ជាការសំខាន់បំផុតដែលយុទ្ធសាស្ត្រជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារមួយត្រូវបានអនុវត្តក្នុងលក្ខខណ្ឌពលសម្បទាស្មើគ្នា ដោយមូលហេតុដូចខាងក្រោម៖

ដោយសហការនៅក្នុងវិស័យខាងដើម យុទ្ធសាស្ត្រកំណើនការងារ អាចចាំបាច់នៅក្នុងការអនុវត្តរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព។ ដោយឡែកកំណើនការងារវិស័យផ្លូវការដែលមានផលិតភាព មានអត្ថប្រយោជន៍ និងមិនរើសអើង អាចចូលរួមក្នុងការពង្រីក (ការរួមភាគទាន) ការធានារ៉ាប់រងសង្គម ជាហេតុអាចកាត់បន្ថយទម្ងន់លើថវិការដ្ឋាភិបាលសម្រាប់ការឧបត្ថម្ភសង្គម ជាដើម។ ការងារវិស័យផ្លូវការ ដែលពាក់ព័ន្ធនឹងកិច្ចសន្យាការងារ ទំនងជាបើកចំហរផ្លូវសម្រាប់កិច្ចចរចារ និងកិច្ចសន្ទនាសង្គម ជាពិសេសលើបញ្ហាប្រាក់ឈ្នួល ចំណូល និងផលិតភាព។ "ការវិវត្តជាលំដាប់នៃកិច្ចគាំពារសង្គមជាទូទៅ តាមចក្ខុវិស័យរយៈពេលវែងរបស់ យុទ្ធសាស្ត្រជាតិគាំពារសង្គម"[103] អាចបន្តឲ្យមានទិ្វកនិយម ដរាបណាកិច្ចខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីពង្រឹង និងបង្កើនការងារក្នុងវិស័យផ្លូវការ

---

[102] យ.ជ.គ.ស បានផ្តោតទៅលើក្របខណ្ឌកម្មវិធីដើម្បីរួមបញ្ចូល ALMPs ទាំងនោះជាការងារសាធារណៈ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

[103] មើល រូបភាពក្រាហ្វិកនៅក្នុង CARD (2010) រូបភាពទី ៣ ទំព័រទី ១៥

នៅក្នុងសេដ្ឋកិច្ច។ បើមិនដូច្នោះទេ ការងារវិស័យមិនផ្លូវការ នឹងនៅតែបន្តកើនឡើង ដោយមានផលវិបាកដែលនឹងមានការពង្រីកតាមខ្សែទទឹងនៃការឧបត្ថម្ភសង្គមដែលមិនរួមភាគទាន។

នយោបាយបង្កើនការងារអាចជួយបង្កើន និងពង្រឹងយុទ្ធសាស្ត្រជាតិគាំពារសង្គម ហើយគោលនយោបាយគាំពារសង្គម អាចជួយគាំទ្រការងារនិងភាពមានការងារធ្វើដូចគ្នា។ ការឧបត្ថម្ភសាច់ប្រាក់ និងសម្ភារៈដោយមានលក្ខខណ្ឌ ត្រូវបានផ្សារភ្ជាប់រួចស្រេចដើម្បីគាំទ្រការអប់រំ និងសុខភាពរបស់គ្រួសារ ជនទទួលផលដែលក្រីក្រ។ អាចមានការពង្រីកបន្ថែមដើម្បីភ្ជាប់ជាមួយALMPs[104] ដែលអ្នកទទួលផលអាចត្រូវបានផ្តល់ឱកាសឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងកន្លែងធ្វើការ និងអាចផ្តល់ឱកាសទទួលបានការងារធ្វើ។ ម៉្យាងទៀត កម្មវិធីបញ្ញត្តិសង្គមមិនរួមភាគទានផ្សេងៗអាចត្រូវបានរៀបចំសម្រាប់លើកស្ទួយ ALMPs ភាពមានការងារធ្វើ និងកន្លែងធ្វើការ។

ដូចគ្នានេះដែរ ការឧបត្ថម្ភសង្គមសម្រាប់ការផ្តល់ការងារអាចត្រូវបានបង្ហាញយ៉ាងច្បាស់ស្មើគ្នាដើម្បីបង្កើតយុទ្ធសាស្ត្រគាំពារសង្គម និងបង្កើតការងារ។ ច្បាប់បង្កើតការងារនៅជនបទថ្នាក់ជាតិរបស់ប្រទេសឥណ្ឌា(NREG) ផ្តល់ឧទាហរណ៍ថ្មីៗអំពីបទបញ្ញត្តិ ពីរបៀបដែលការងារអាចដើរតួជាវិធានការគាំពារសង្គម។ ច្បាប់ផ្តល់អាណត្តិដល់រដ្ឋ និងស្ថាប័នវិមជ្ឈការដើម្បីផ្តល់រយៈពេល ១០០ថ្ងៃការងារដល់ពលរដ្ឋក្រីក្រគ្មានជំនាញខាងកសិកម្ម/នៅជនបទ ដែលតម្រូវឲ្យអាជ្ញាធរបង់ប្រាក់ឈ្នួលសមមូលដល់កម្មករនិយោជិតចំពោះការងារដែលមិនអាចផ្តល់ឲ្យពួកគេក្នុងអំឡុងពេលនោះ។ នេះជាកម្មវិធីទូទាំងប្រទេសដែលការឧបត្ថម្ភសង្គមបង្វែរភ្ជាប់ទៅនឹងហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីតាមផ្នែកផ្សេងៗ (ដូចជាកសិកម្ម ជំនាញ និងការអប់រំ បរិស្ថានជាដើម)។ ទោះបីជាកម្ពុជាអាចបញ្ជាក់ច្បាស់អំពីការឧបត្ថម្ភសង្គមខ្លះៗ ហើយកសាងម៉ូដែលទូទាំងប្រទេសអំពីការផ្សារភ្ជាប់កិច្ចគាំពារសង្គម និងការងារត្រូវផ្អែកការយល់ស្របពីអ្នកនយោបាយ ធនធាន និងសមត្ថភាពរបស់ស្ថាប័ន។[105] កម្មវិធីច្នៃប្រឌិតផ្សេងៗក៏ស្ថិតនៅក្នុងបរិបទនេះដែរ ដូចជានៅប្រេស៊ីល និងអាហ្វ្រិកខាងត្បូងមានគោលនយោបាយការងារ និងគាំពារសង្គម ហើយកម្មវិធីនេះត្រូវបានបង្ហាញក្នុងលក្ខខណ្ឌសាមញ្ញនៃសុខមាលភាពសង្គមសម្រាប់អ្នកក្រីក្រ។
យ.ជ.គ.សអាចសំដៅលើបទពិសោធន៍ប្រទេសជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលកំពុងព្យាយាមបន្ត ដើម្បីសំរេចបាននូវកម្មវត្ថុទាំងពីរនៃរបបសន្តិសុខសង្គម និងការងារតាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមគ្នា។

---

[104] មើល V. Schmidt (2010), mimeo

[105] ចំពោះ យ.ជ.គ.ស ការសិក្សា និងសំណើជាច្រើនត្រូវបានកំពុងធ្វើឡើងទៅលើកម្មវិធីផ្លាស់ប្តូរសង្គមមិនរួមវិភាគទាន។ មើលឧទាហរណ៍ G. Edmonds (2010) កម្មវិធីការងារសាធារណៈជាផ្នែកនៃយុទ្ធសាស្ត្រការពារសង្គម (mimeo) ដែលផ្តល់សំណើសម្រាប់គម្រោងទូទាំងប្រទេសនៃការងារសាធារណៈ និងចំណីអាហារសម្រាប់កម្មវិធីការងារ។ សូមមើល Vaidya (2010)

ការពិចារណាជាសំខាន់នៅក្នុងការចងក្រង និងប្រមូលបទបញ្ញត្តិនៃអភិក្រមសម្របសម្រួលក្នុងការបង្កើនការងារ និងរបបសន្តិសុខសង្គម ជាវិសាលភាពនៃភាពមានធនធាន។ នៅពេលដែលអភិក្រមច្នៃប្រឌិតថ្មីនឹងត្រូវបានរកឃើញសម្រាប់ការភ្ជាប់យ៉ាងមានអត្ថន័យរបស់រដ្ឋ និងសង្គម ដូចជាអំពាវនាវឲ្យមានគោលការណ៍ "សាមគ្គីភាព" និង "ចែកចាយឡើងវិញ" ជំហានទី១ និងកិច្ចចាប់ផ្តើមប្រហែលជាត្រូវបានមកពីសកម្មភាពសាធារណៈ ជាពិសេសចំណាយសាធារណៈ។ នេះជាបញ្ហាពីរបៀបដែលរាជរដ្ឋាភិបាលត្រូវព្យាយាមពង្រឹង "ចន្លោះប្រហោងផ្នែកសារពើពន្ធ" (មើលផ្នែកទី ៤) និងបែងចែកទៅជាកម្មវិធីពាក់ព័ន្ធទៅវិញទៅមកនៃកិច្ចអន្តរាគមន៍ការងារ និងការឧបត្ថម្ភសង្គមផ្សេងទៀត (មើលរូបភាពទី ១ ក្នុងឧបសម្ព័ន្ធ)។ រូបភាពសង្ខេបអំពី ១. ប្រភពសក្តានុពលនៃការកើនឡើងចន្លោះប្រហោងផ្នែកសារពើពន្ធ (ការកើនឡើងធនធានប្រាក់ចំណេញ ជំនួយអភិវឌ្ឍន៍ផ្លូវការច្រើនជាង ការកើនឡើងដែលអាចមាននៅក្នុងការខ្ចីជាសាធារណៈ និងការផ្តល់អាទិភាពម្តងទៀតនៃចំណាយសាធារណៈ[106] និង ២. ធាតុនៃការឧបត្ថម្ភសង្គម និងអន្តរាគមន៍ការងារដែលត្រលប់មកវិញអាចលើកកម្ពស់កិច្ចគាំពារសង្គម និងការពង្រីកការងារដោយផ្ទាល់ ក៏ដូចជាតាមរយៈការកើនឡើងនៃតម្រូវការប្រមូលផ្តុំ។

# សេចក្តីសន្និដ្ឋាន

ការសិក្សានេះបានអះអាងក្នុងការកំណត់បរិបទ និងចំណុចសំខាន់នៃយុទ្ធសាស្ត្រជាតិស្តីពីមុខរបរ និងការងាររបស់កម្ពុជា។ លើសពីនេះ ការសិក្សានេះផ្តល់នូវរូបរាង និងអភិក្រមដែលអាចមាន ជាតុផ្សំគោលនយោបាយ ដែលត្រូវតែសហការគ្នា សម្រាប់បង្កើតយុទ្ធសាស្ត្រការងារមួយ។ ការសិក្សាអះអាងថា យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារពិតជាមានសារៈសំខាន់ណាស់ ជាពិសេសដោយសារតែកម្ពុជាតាំងចិត្តយ៉ាងពេញលេញក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដែលរួមមានគោលដៅកាត់បន្ថយភាពក្រីក្រ(នៅពាក់កណ្តាលឆ្នាំ២០១៥) និងគោលដៅសម្រេចឲ្យបាន"ការងារពេញលេញ អំណោយផល និងការងារត្រឹមត្រូវ" (គោលដៅ ១ខ)។ ការសិក្សាបានលើកឡើងបន្ថែមថា អាចមានផែនការប្រថុយប្រថានក្នុងការពឹងផ្អែកតែលើកំណើនបញ្ចូនលទ្ធផលខាងលើ ដោយគ្មានការយល់ដឹងពីរបៀបដែលកំណើនអាចនាំឲ្យមានការកាត់បន្ថយភាពក្រីក្រ។ "ភ្នាក់ងារ" ពិសេសមួយ ដូចដែលបានអង្កេតតាមរយៈបទពិសោធន៍អន្តរជាតិ ការយល់ដឹងពីរបៀបដែលកំណើនអាចកើនឡើងពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រជានិរន្ត គឺជាការបង្កើតការងារដែលមានផលិតភាព។ ការសិក្សាក៏ផ្តល់នូវចក្ខុវិស័យខ្លះអំពីភាពប្រឈមនឹងការងារបច្ចុប្បន្ននៅក្នុងសេដ្ឋកិច្ចកម្ពុជា និងឆ្លងកាត់បញ្ហាគោលនយោបាយមួយចំនួនដែលសមស្របទៅនឹងការរៀបចំ និងបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។ ក្នុងចំណោម

---

[106] មើល ធនាគារពិភពលោក ចំពោះការសហការគ្នា

នោះ រួមមានការគិតឡើងវិញនៃក្របខណ្ឌការងារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍ជាអាទិភាពដល់គោលនយោបាយតាមវិស័យ ការធ្វើសមាហរណកម្មគោលនយោបាយទីផ្សារការងារ និងគោលនយោបាយគាំពារសង្គម។ ការសង្ខេបការរកឃើញនេះ បញ្ជាក់ពីការសន្និដ្ឋាននៃកិច្ចពិភាក្សា ដែលមាននៅក្នុងខ្លឹមសារសង្ខេប។ សូមបញ្ជាក់ថា នេះជាការរកឃើញដំបូង ហើយទាមទារឲ្យមានការសិក្សាយ៉ាងល្អិតល្អន់បន្ថែមទៀតលើវិស័យគោលនយោបាយផ្សេងៗដែលបានកំណត់ ដើម្បីបង្កើតជាយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារដ៏ទូលំទូលាយ និងរៀបចំផែនការសកម្មភាពដែលអាចអនុវត្តបាន។

គួរត្រូវការគិតគូរដែរថា ការបង្កើតការងារជាបញ្ហាស្មុគ្រស្មាញ និងការពិបាកដោយសារវាពាក់ព័ន្ធនឹងវិស័យគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន។ ដូចដែលការសិក្សាបានអះអាង នៅពេលដែលយុទ្ធសាស្ត្រជាតិមុខរបរនិងការងារ គោរពតាមអភិក្រមបញ្ចូលគ្នាមួយ យុទ្ធសាស្ត្រនេះ ត្រូវតែបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ម៉្យាងវិញទៀត យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ គួរត្រូវបានបញ្ចូលជាមួយយុទ្ធសាស្ត្រផ្សេងៗដែលមានទំនោរទៅលើកស្ទួយវិស័យការងារនិងមុខរបរ និង/ឬ បង្កភាពងាយស្រួលក្នុងការផ្សារភ្ជាប់ទៅនឹងការបង្កើតការងារដែលមានផលិតភាព។

ភាពសំខាន់ក្នុងការធ្វើសមាហរណកម្មនឹងការបង្កើតការងារដែលមានផលិតភាព ផ្តល់ប្រយោជន៍នៅក្នុងរៀបផែនការរបស់កម្ពុជា ត្រូវបានគូសបញ្ជាក់ដោយការអង្កេតសាមញ្ញៗមួយចំនួន។ អត្រាកំណើនយ៉ាងរហ័សនាទសវត្សរ៍ចុងក្រោយនេះ បានជួយបង្កើនការងារនៅក្នុងសេដ្ឋកិច្ច (ដូចមានចង្អុលបង្ហាញចំនួនកម្លាំងពលកម្មដែលមានការងារ) បញ្ហា"ជនងាយរងគ្រោះ" និង"ជនក្រីក្រដែលប្រកបការងារ" នៅតែស្ថិតក្នុងកម្រិតខ្ពស់មិនអាចទទួលយកបាន។ លើសពីនេះ ទោះបីជាភាពក្រីក្រធ្លាក់ចុះជាទូទៅក៏ដោយ ក៏ការកើតឡើងនេះនៅតែមានកម្រិតខ្ពស់នៅតំបន់ទីជនបទ និងនៅក្នុងកម្លាំងពលកម្មមួយចំនួន ជាពិសេសកម្មករនៅតាមកសិដ្ឋានតូចៗ។ កំណើននេះ អាចនឹងពិបាក "ធ្លាក់ចុះ" ដើម្បីលើកកម្ពស់ចំណូលក្នុងតំបន់ទាំងនោះ ឬប្រភេទក្រុមកំលាំងពលកម្មទាំងនេះ។ គោលនយោបាយដែលមានចេតនា និងអន្តរាគមន៍ ត្រូវការការរៀបចំដើម្បីផ្តល់នូវឱកាសទទួលបានប្រាក់ចំណេញប្រកបដោយចេរភាព។ ការសិក្សានេះអះអាងថា ឱកាសត្រូវបានបង្កើតឡើងយ៉ាងទូលាយ តាមរយៈការធ្វើការងារប្រកបដោយផលិតភាព និងមានប្រាក់ចំណូល។

អត្រាកំណើនជិតដល់ពីរខ្ទង់របស់ប្រទេសកម្ពុជា ដែលត្រូវបានកោតសរសើរដោយសហគមន៍អន្តរជាតិ ត្រូវបានប៉ះទង្គិចយ៉ាងខ្លាំងដោយវិបត្តិសេដ្ឋកិច្ចសកលនាពេលថ្មីៗនេះ។ តាមការព្យាករ អត្រាកំណើនត្រូវបានដើរថយក្រោយវិញ។ សំខាន់ជាងនេះ មានកង្វល់ជាច្រើនថាតើសេដ្ឋកិច្ចអាចត្រឡប់ទៅរកអត្រាកំណើនដូចកាលពីពេលមុនឬអត់។ នេះជាពេលវេលាសម្រាប់អត្តពិគ្រោះអំពីមូលដ្ឋានគ្រឹះ

និង "អ្នកនាំផ្លូវ" នៃកំណើនដោយហេតុថា មជ្ឈជាតុនិយមកើតមានទៅលើយុទ្ធសាស្ត្រកំណើនដែលឈាន ទៅរកការអនុវត្តអាចឋិតថេរបានយូរប៉ុនណា ដោយឡែកសេដ្ឋកិច្ចបើកចំហរ ពឹងផ្អែកលើកាលៈទេសៈ ខាងក្រៅ និងទៅលើវិនិយោគទុនក្រៅប្រទេស រហូតស្ទើរតែធ្វេសប្រហែសដល់ការវិនិយោគក្នុងស្រុក។ អត្តពិគ្រោះនោះកំពុងឆ្លុះបញ្ចាំងជាបណ្តើរៗ ដូចនៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣* ប៉ុន្តែត្រូវការការគិតឡើងវិញពីក្របខណ្ឌគោលនយោបាយទាំងស្រុង ប្រសិនបើកម្ពុជា មានបំណងចង់ធ្វើឲ្យការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ខ្លួន មានប្រសិទ្ធិភាព។ ឧទាហរណ៍ដូចជា ការសិក្សាបានលើកឡើងថា គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបច្ចុប្បន្នផ្តោត យ៉ាងខ្លាំងលើសូចនាករ"ស្ថេរភាព"។ ប៉ុន្តែទន្ទឹមនឹងពេលដែលស្ថេរភាពត្រូវបានរក្សាយ៉ាងទូលាយសេដ្ឋកិច្ច មានកំណើនវិនិយោគក្នុងស្រុកតិចជាងការចង់បាន និងមានការផ្លាស់ប្តូររចនាសម្ព័ន្ធតិចតួច។ ការផ្លាស់ប្តូរ រចនាសម្ព័ន្ធនេះត្រូវបានអង្កេតឃើញតាមរយៈចំណែកតូចនៃសេដ្ឋកិច្ចទំនើបក្នុងការងារសរុប សំដៅលើ ចលនាមិនគ្រប់គ្រាន់នៃការងារពីវិស័យផលិតភាពទាបទៅផលិតភាពខ្ពស់។ ការផ្លាស់ប្តូរនេះអាចត្រូវបាន ពង្រឹង តាមរយៈការតំរង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឡើងវិញ (ដូចជាតាមរយៈការប្រើប្រាស់ដោយ ប្រយ័ត្នប្រយែងនៃសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុទាក់ទងនឹងកំណើនវិនិយោគការងារ) ក៏ដូច ជាតាមរយៈការជ្រើសអាទិភាពលើមាតិកាការងារនៃកំណើនតាមវិស័យ។

ប្រសិនបើយុទ្ធសាស្ត្រនេះអនុវត្តបានត្រឹមត្រូវ គួរត្រូវផ្សព្វផ្សាយឲ្យបានលើសពាក់កណ្តាល ហើយ ជនក្រីក្រដែលប្រកបការងារ និងជនងាយរងគ្រោះអាចនៅតែបន្តត្រូវការចំណូល និងការគាំទ្រពីការងារ។ នៅកម្ពុជា ការគាំទ្រនោះកំពុងត្រូវបានពង្រីកតាមរយៈការឧបត្ថម្ភសង្គមមិនមានភាគទាន និងគម្រោង អន្តរាគមន៍ភាពមានការងារពិសេសមួយចំនួនធំ (ដូចជាការងារសំណង់សាធារណៈ)។ ទាំងនេះជាធម្មតា មានលក្ខណៈបណ្តោះអាសន្ន និងជាកម្មវិធីហិរញ្ញប្បទានភាគច្រើនដោយម្ចាស់ជំនួយ។ ការសិក្សានេះទាម ទារឲ្យមានការពិនិត្យឡើងវិញនូវកម្មវិធី "គាំពារសង្គម" និងកម្មវិធីអន្តរាគមន៍ការងារ ដើម្បីស្វែងរកចំណុច រួម និងដើម្បីបង្កើតកម្មវិធីដែលអាចជាប់លាប់ជាប្រព័ន្ធ និងទូទាំងប្រទេស ដូចជានៅប្រទេសឥណ្ឌា និងប្រទេសដទៃទៀត។ ក្នុងការរៀបចំផែនការដូចជា ក្របខណ្ឌការងារ គោលនយោបាយ និងស្ថាប័ន ក៏ដូចជាបញ្ហានៃចន្លោះប្រហោងផ្នែកសារពើពន្ធ ក៏ត្រូវការការគិតគូរផងដែរ។ ដូចដែលការសិក្សាបាន រក្សាទុក ភាពប្រឈមភាពមានការងារពិតនៅកម្ពុជា មិនចាំបាច់ផ្អែកលើការកាត់បន្ថយអត្រាគ្មានការងារ ធ្វើ(១.៦%)ប៉ុន្តែត្រូវផ្តល់នូវការងារដែលមានផលិតភាព ហើយជនក្រីក្រដែលប្រកបការងារទទួល បានប្រាក់ចំណូលសមរម្យ តាមរយៈការបង្កើនការងារ ក៏ដូចជាតាមរយៈអន្តរាគមន៍តាមគោលដៅ។

ភាពប្រឈមនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ ហាក់ដូចជាកើតឡើងក្នុងការអភិវឌ្ឍក្របខណ្ឌការងារម៉ាក្រូ សេដ្ឋកិច្ច យុទ្ធសាស្ត្រតាមវិស័យដែលសមស្រប និងឆ្លុះបញ្ចាំងពីការប្រើប្រាស់មានប្រសិទ្ធភាព ជាពិសេស

ជីផ្លូ និងការងារ។ កម្មវិធី និងស្ថាប័នអភិវឌ្ឍន៍ផ្សេងៗ ក៏ត្រូវមានការចូលរួមគាំទ្រការងារ និងប្រាក់ចំណូលរបស់ប្រជាជនក្រីក្រដែលប្រកបការងារ។ ការពិភាក្សាអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិលើបញ្ហាទាំងនេះ គឺហួសពីវិសាលភាពនៃការសិក្សានេះ ក៏ប៉ុន្តែ វាបានត្រួតពិនិត្យឡើងវិញនូវគោលនយោបាយជាច្រើនដែលពាក់ព័ន្ធនឹងការបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។ ការស្នើឲ្យមានកំណែទម្រង់ខ្លះ អាចនឹងត្រូវធ្វើ ដើម្បីបញ្ចូលគោលនយោបាយទាំងនោះក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ នេះជាការសំខាន់សម្រាប់ការកំណត់គោលនយោបាយ គឺសម្របសម្រួលភាពកណ្តាលនៃភាពមានការងារធ្វើ និងដើម្បីទទួលស្គាល់ការធ្វើសមាហរណកម្មនៃយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។

ការរៀបចំ និងការបង្កើត យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារដែលពេញលេញមួយ ត្រូវការការស៊ើបអង្កេតយ៉ាងល្អិតល្អន់ ចូលទៅដល់បញ្ហាផ្សេងៗដែលមានបង្ហាញនៅក្នុងការសិក្សា។ ឧទាហរណ៍ដូចជា ការសិក្សាស្រាវជ្រាវត្រូវធ្វើឡើងលើបញ្ហាមួយចំនួន ដែលមានរួមបញ្ចូលនូវ៖

- ការវិភាគលម្អិតចរិកលក្ខណៈនៃភាពប្រឈម ភាពមានការងារ និងទីផ្សារការងារនៅកម្ពុជា។ ក្រៅពីការកម្រិតទិន្នន័យដែលមានស្រាប់ ជាចាំបាច់ត្រូវកត់សម្គាល់អំពីសូចនាករស្តង់ដារសេចក្តីយោងក្នុងការត្រួតពិនិត្យការផ្តល់ការងារ ការអនុវត្តទីផ្សារការងារ ក្នុងលក្ខខណ្ឌគុណភាព និងបរិមាណ។ ទិន្នន័យត្រូវមានគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងពាក់ព័ន្ធនឹងការបង្កើតការផ្តល់ការងារតាមវិស័យ ចលនាក្នុងភាពទន់ភ្លន់នៃការផ្តល់ការងារ ភាពមិនស៊ីគ្នាខាងជំនាញ និងការវាយតម្លៃពីតម្រូវការជំនាញ និន្នាការប្រាក់ឈ្នួល និងចលភាពការងារជាដើម។

- ជាការមានប្រយោជន៍ក្នុងការត្រួតពិនិត្យឡើងវិញ នូវអត្ថប្រយោជន៍ប្រៀបធៀបពិតរបស់កម្ពុជា។ ការសង្កត់ធ្ងន់ទៅលើកំណើនផ្នែកនាំចេញ និងការងារ ដែលត្រូវបានកំណត់យ៉ាងច្រើនចំពោះឧស្សាហកម្មកាត់ដេរ។ នេះអនុញ្ញាតឲ្យមានការអភិវឌ្ឍន៍ និងឧស្សាហូបនីយកម្ម និងគោលនយោបាយពាណិជ្ជកម្មដែលអាចបង្ហាញពីមេរៀនបានពីបទពិសោធន៍ឧស្សាហកម្មសំលៀកបំពាក់។ ការយកចិត្តទុកដាក់ជាពិសេសត្រូវមានចំពោះការប្រកួតប្រជែងខាងជំនាញ ពិពិធកម្មឧស្សាហកម្ម និងនាំចេញ ការអភិវឌ្ឍន៍រចនាសម្ព័ន្ធលើកទឹកចិត្តសម្រាប់ជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈសហគ្រាសខ្នាតតូច និងមធ្យម។

- ភាពក្រីក្រជាបាតុភូតយ៉ាងធំនៅជនបទ ការបែងចែកធនធានគួរត្រូវ យកចិត្តទុកដាក់សម្រាប់វិស័យជនបទ។ ជាឧទាហរណ៍ ការសិក្សាអង្កេតអំពីសារៈសំខាន់នៃវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ក្នុងការធ្វើឲ្យរឹងមាំនូវផលិតភាពជនបទ និងការបង្កើតការងារ។ ដោយឡែក

ការប្រៀបធៀបអត្ថប្រយោជន៍របស់កម្ពុជានៅក្នុងផលិតកម្មដី និងនាំចេញ គួរត្រូវបានពិនិត្យពិច័យយ៉ាងពេញលេញ និងថាអ្វីជាគោលនយោបាយជាក់លាក់ និងអន្តរាគមន៍កម្មវិធីត្រូវការក្នុងការប្រមូលផលដូចជា ប្រៀបធៀបអត្ថប្រយោជន៍ជាដើម។

- គោលនយោបាយការងារមានសារៈសំខាន់លើសលុប សម្រាប់ការប្រព្រឹត្តទៅនៃទីផ្សារការងារ និងជាគន្លឹះសម្រាប់យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ។ ច្បាប់ស្តីពីការងាររបស់កម្ពុជា ជាប្រភពដើមដ៏សំខាន់ តែការអនុវត្តនៅមិនទាន់បានខ្ជាប់ខ្ជួននៅឡើយ។ ស្របមកវិញក្របខណ្ឌគោលនយោបាយទីផ្សារការងារសកម្ម ត្រូវការការអភិវឌ្ឍន៍បន្ថែម រួមទាំងការសម្របសម្រួលខាងស្ថាប័នដែលគាំទ្រការអនុវត្តជាតុផ្សំផ្សេងៗ នៃគោលនយោបាយទីផ្សារការងារសកម្ម ផងដែរ។

ជាចុងបញ្ចប់ ការរៀបចំ និងការបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ ត្រូវការ ការយល់ស្របថ្នាក់ជាតិបែបទូលាយពីដៃគូពាក់ព័ន្ធនានា ជាពិសេសដៃគូសង្គម ដោយហេតុថា គោលនយោបាយជាច្រើនអាចមានការផ្លាស់ប្តូរ និងអាចត្រូវកែតម្រូវ ដូចជាការកែតម្រូវលើក្របខណ្ឌគតិយុត្តិ។ ដោយសារតែក្រសួង និងភ្នាក់ងារមួយចំនួនមានចំណាប់អារម្មណ៍ និងមានទំនួលខុសត្រូវលើការបង្កើនការផ្តល់ការងារ ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីមុខរបរនិងការងារ គួរត្រូវធ្វើឡើងតាមរយៈការបង្កើតវេទិកាអន្តរក្រសួង។

# ឯកសារយោង


AFD/GTZ/DFID/WB, *Pro-poor growth in the 90s: lessons and insights from 14 countries*, 2006.

CARD, *National Social Protection Strategy for the Poor and Vulnerable*, April 2010.

CDRI, *Youth Migration and Urbanisation in Cambodia*, November 2007.

— (2009c), *Cambodia Development Review*, July-September (Phnom Penh: CDRI).

Chan S. & Ear S. (2004), “Towards Understanding Social Protection in Cambodia”, *Cambodia Development Review*, Vol. 8, No 4 (Phnom Penh: CDRI).

Chandarat, K., et al, *Rapid assessment of the impact of the financial crisis in Cambodia*, ILO Asia-Pacific Working Paper, March 2009.

de Zamaróczy, M. & S. Sopanha, S. (2002), *Macroeconomic Adjustment in a Highly Dollarized Economy: The Case of Cambodia*, IMF Working Paper No. 02/92, http://www.imf.org/external/pubs/ft/wp/2002/wp0292.pdf (accessed 7 October 2009).

Edgren, G. & M. Muqtada, “Strategies for Growth and Employment in Asia: Learning From Within” in *Employment Challenges for the 90s*, 1990.

Edmonds, G., *A Public Works Programme as part of Social Protection Strategy: A Background Note*, 2010 (mimeo.)

Ghose J., *Poverty reduction in China and India: Policy Implications of recent trends*, UN DESA Working Paper No. 92, 2010.

Godfrey, M., et al, *A Study of the Cambodian Labour Market: Reference to Poverty Reduction*, Growth and Adjustment to Crisis, CDRI, August 2001.

Hang, Chuon Naron, *Cambodian Economy: Charting the Course of a Brighter Future – A Survey of Progress, Problems and Prospects*, 2009.

ILO. *ILO policy brief on youth employment in Cambodia*, 2007.

—. World Social Security Report 2010–2011, Geneva, 2010.

—. Effects of non-contributory social transfers in developing countries: a compendium, Geneva, 2010.

—; ARTEP, Employment and Structural Change in Pakistan issues for the Eighties, 1983;

Chowdhury, N., “Relative Efficiency of Alternative Techniques in Cotton Weaving Industry of Bangladesh,” *Bangladesh Development Studies*, Vol.IX, No.3; Poot, H., “Recent Industrial Development Trends in Indonesia,” Dept. of Industry, Jakarta, 1987.

IMF (2009a), *Country Report No. 09/47* (Cambodia: 2008 Article IV Consultation – Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion), (Washington, DC: IMF).

62 Cambodia. Toward a National Employment Strategy for Sustained Poverty Reduction

— (2009b), *Country Report No. 9/325* (Cambodia: 2009 Article IV Consultation – Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion), (Washington, DC: IMF).

Ishikawa S., *Labour Absorption in Asian Agriculture*, ILO-ARTEP, Labour Absorption in Agriculture: The East Asian Experience, 1980.

Islam, I., & S. Verick, eds: *From the Great Recession to labour market recovery: Issues, evidence and policy options*, Palgrave 2010.

Islam, R. (ed): *Fighting poverty: The development-employment link*, Lynne Rienner, London, 2006.

Jalilian, H., & G. Reyes, “Cambodia in the Sweep of the Global Financial and Economic Crisis” in *CDRI Annual Development Review 2009–10.*

Kang C., Sok S., Kim S. & Liv D., (2009), *Rapid Assessment on the Impact of the Financial Crisis in Cambodia* (Phnom Penh: CIDS).

Khan, A.R. and M. Muqtada, eds: *Employment expansion and macroeconomic stability under increasing globalization*, McMillan Press Ltd, London and St. Martin’s press, New York, 1997.

Kim S. (2001), “Reciprocity: Informal Patterns of Social Interactions in a Cambodian Village”, MA thesis (Northern Illinois University, Department of Anthropology).

Lee, E., *Employment and Social Protection in Developing Countries: A framework for Policy Integration*, 2010 mimeo.

Majid, N. (2001), “The working poor in developing countries” in *International Labour Review*, Volume 140, September.

Morris, E., *Promoting employment in Cambodia: Analysis and options*, 2007.

Muqtada, M., *Macroeconomic stability, growth and employment: issues and considerations beyond the Washington Consensus*, Employment Paper 2003/48, ILO, Geneva, 2003

—. *The crisis of orthodox macroeconomic policy: the case for a renewed commitment to full employment*, Employment Paper No 53, ILO, Geneva, 2010.

NIS-ILO, *Labour and Social Trends in Cambodia*, 2010.

National Strategic Development Plan 2006–2010,

www.cdc-crdb.gov.kh/cdc/aid_management/nsdp.pdf (accessed 23 October 2009).

Polaski, S., *Harnessing global forces to create decent work in Cambodia*, ILO/IFC Research series 119, 2009.

Ranis, G., "Industrial Sector Labour Absorption", *Economic Development and Cultural Change*, April 1973.

Ravallion, M. *Pro-poor growth: a primer*, World Bank, Washington DC, 2004

Rodrik, D. (2009), "Growth after the Crisis", paper prepared for the Commission on Growth and Development.

Cambodia. Toward a National Employment Strategy for Sustained Poverty Reduction 63

Royal Government of Cambodia, *National Strategic Development Plan Update 2009–2013*, June 2010.

UNDP, *Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction*, 2009.

Vaidya, K., *Appropriate Wage Rate and Estimate of Labour Availability for a Public Works Based Safety Net in Cambodia*, March 2010.

*World Bank, Cambodia: providing skills for equity and growth, Washington DC, 2010.*

## ឧបសម្ព័ន្ធ: រូបភាពទី ១

